សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ROYAL UNIVERSITY OF PHNOM PENH
មហាវិទ្យាល័យសង្គមសាស្ត្រមនុស្សសាស្ត្រ
ដេប៉ាតឺម៉ង់អក្សរសាស្ត្រខ្មែរ

វិធីសាស្ត្រស្រាវជ្រាវ
Research Methods

សំណើស្រាវជ្រាវ

វិធីសាស្ត្រសរសេរសារណា

វិធីសាស្ត្រផ្តល់ឯកសារប្រភព

រៀបរៀងនិងបកប្រែដោយ **នៅ សម្បត្តិ**

ត្រួតពិនិត្យកែលម្អដោយៈ

១. លោក **គីម សុវណ្ណគីរី** ព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រមនុស្សសាស្ត្រ

២. លោក **ឆា សុភម៉េង** ប្រធានដេប៉ាតឺម៉ង់អក្សរសាស្ត្រខ្មែរ

ប្រើប្រាស់ថវិកាកម្មវិធី:(PB:២០១៤)

គ.ស ២០១៤

អារម្ភកថា

នៅក្នុងពិភពអ្នកសិក្សា ការស្រាវជ្រាវពិតជាមានសារៈសំខាន់ណាស់ ជាពិសេសនៅក្នុងវិស័យអប់រំ ព្រោះអ្នកសិក្សានិងមន្ត្រីអប់រំត្រូវមានការស្រាវជ្រាវច្រើន ដើម្បីពង្រឹងចំណេះដឹងរបស់ខ្លួន ហើយការស្រាវជ្រាវពិតជាផ្តល់នូវគុណប្រយោជន៍យ៉ាងច្រើនសម្រាប់អ្នកស្រាវជ្រាវ ក៏ដូចជាអ្នកសរសេរសៀវភៅនិងគ្រូបង្រៀន ។

ការបង្រៀនដែលផ្សារភ្ជាប់ទៅនឹងការសិក្សាស្រាវជ្រាវ ផ្តល់នូវចំណេះដឹងប្រកបដោយគុណភាពនិងផ្សារភ្ជាប់នូវទ្រឹស្តីជាមួយការអនុវត្ត ។ ដូចនេះអ្នកសិក្សាស្រាវជ្រាវមិនអាចកាត់ផ្តាច់បានពីការរៀបចំ ឬនិពន្ធសៀវភៅក៏ដូចជាឯកសារផ្សេងៗបានឡើយ។ សៀវភៅដែលអ្នកសិក្សាអ្នកស្រាវជ្រាវកំពុងកាន់អាននឹងដៃនេះវាគ្រាន់តែជាការរួមចំណែក ឬជាឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរតែប៉ុណ្ណោះ មិនបានឆ្លុះបញ្ចាំងពីការសិក្សាស្រាវជ្រាវស៊ីជម្រៅគ្រប់មហាវិទ្យាល័យ ឬសាកលវិទ្យាល័យនោះទេ។

សៀវភៅវិធីសាស្ត្រស្រាវជ្រាវនេះ កើតចេញពីការខំប្រឹងប្រែងរបស់ខ្ញុំនិងមិត្តភ័ក្រ្ត រួមគ្នារៀបរៀង បកប្រែឯកសារមួយចំនួនដើម្បីឱ្យឆ្លើយតបទៅនឹងកង្វះឯកសារមេរៀន"វិធីសាស្ត្រស្រាវជ្រាវ" របស់និស្សិតផ្នែកបរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ។

ទោះបីយ៉ាងណាក៏ដោយស្នាដៃនេះ នឹងបានចូលរួមចំណែកក្នុងការសិក្សាស្រាវជ្រាវរបស់និស្សិត ដើម្បីពង្រីកចំណេះដឹងរបស់ខ្លួនក្នុងការសិក្សាស្រាវជ្រាវ។ សៀវភៅនេះមានបង្ហាញផងដែរនៅវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ បរិវិស័យ វិធីសាស្ត្រក្នុងការសរសេរសារណា និងការផ្តល់ឯកសារប្រភពជាដើម។

យើងខ្ញុំរង់ចាំការកែតម្រូវក្នុងន័យស្ថាបនាពីនិស្សិត សាស្ត្រាចារ្យលោក លោកស្រីដើម្បីឱ្យស្នាដៃនេះកាន់តែមានខ្លឹមសារល្អថែមទៀត។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤

នៅ សម្បត្តិ

សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទក៏សូមថ្លែងអំណរគុណយ៉ាងកក់ក្ដៅ ចំពោះលោកគ្រូ អ្នកគ្រូដែលបានបង្រៀនចាប់តាំងពីអក្សរ **ក** រហូតដល់សព្វថ្ងៃនេះ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្ដម ឡៅ ឈីវអ៊ីវ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ។សូមថ្លែងអំណរគុណចំពោះ**ឯកឧត្ដម ជេត ជាលី** សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

សូមថ្លែងអំណរគុណចំពោះ លោកបណ្ឌិត ប៉ូច ប៊ុណ្ណាក់ បណ្ឌិតឈិញ ស៊ីថាសាស្ត្រាចារ្យ ផាន់ ចាន់ពៅ ,អ៊ិត សុធា, ខាន់ សារ៉េត និងសាស្ត្រាចារ្យ កៅ សុវណ្ណតារាដែលបានផ្ដល់យោបល់ ផ្ដល់ឯកសារ និងចំណាយពេលវេលាយ៉ាងច្រើនក្នុងការពិនិត្យកែសម្រួលខ្លឹមសារសៀវភៅនេះឱ្យកាន់តែមានខ្លឹមសារល្អថែមទៀត។

ទន្ទឹមនឹងនេះដែរខ្ញុំសូមថ្លែងអំណរគុណ លោកសាកលទ្យាធិការរងព្រឹទ្ធបុរសសាកល-វិទ្យាល័យភូមិន្ទភ្នំពេញ ព្រមទាំងលោកលោកស្រីជាសាស្ត្រាចារ្យ ដែលជាថ្នាក់ដឹកនាំទាំងអស់ដែលបានប្រឹងប្រែងបណ្ដុះបណ្ដាលធនធានមនុស្ស ប្រកបដោយការអភិវឌ្ឍ ក្នុងការលើកស្ទួយវិស័យអប់រំប្រទេសជាតិយើងឱ្យកាន់តែមានភាពរីកចម្រើនថែមទៀត ។

ម្យ៉ាងទៀតសូមថ្លែងអំណរគុណ ចំពោះអ្នកនិពន្ធ និងអ្នកស្រាវជ្រាវទាំងអស់ជាម្ចាស់សៀវភៅម្ចាស់ ឯកសារប្រភពទាំងអស់ដែលបានស្រាវជ្រាវឯកសារ និពន្ធឯកសារទុកឱ្យយើងខ្ញុំធ្វើការស្រាវជ្រាវបន្តនិងយកមកធ្វើជាឯកសារយោងក្នុងការរៀបចំសៀវភៅនេះ។

ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤

មាតិកា

អារម្ភកថា i

សេចក្តីថ្លែងអំណរគុណ ii

ជំពូកទី ១ សេចក្តីផ្តើមនៃ វិធីសាស្ត្រស្រាវជ្រាវ ១

សេចក្តីផ្តើម ១

១.ផលប្រយោជន៍នៃការស្រាវជ្រាវ ១

ក. ផលប្រយោជន៍សម្រាប់គ្រូ ១

ខ. ផលប្រយោជន៍សម្រាប់និស្សិត ១

គ. ផលប្រយោជន៍សម្រាប់បុគ្គលសង្គម ២

ឃ. ផលប្រយោជន៍សម្រាប់អ្នកជំនាញវិជ្ជាជីវៈ ២

២.កម្រិតនៃការសិក្សានិងស្រាវជ្រាវសម្រាប់វិស័យអប់រំ ២

ក. មធ្យមបច្ចេកទេស ២

ខ. ឧត្តមសិក្សា ៣

គ. ក្រោយឧត្តម ៣

ឃ. បណ្ឌិតនិងក្រោយបណ្ឌិត ៤

ឃ. ១. សញ្ញាបត្របណ្ឌិតស្រាវជ្រាវ ៤

ឃ. ២. សញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ ៤

ឃ. ៣. សញ្ញាបត្របណ្ឌិតកិត្តិយស ៤

ង. លក្ខខណ្ឌសម្រាប់បណ្តុះបណ្តាលថ្នាក់បណ្ឌិត ៤

ង. ១. ការបណ្តុះបណ្តាល ៤

ង. ២. រយៈពេលបណ្តុះបណ្តាល ៥

ង. ៣. លក្ខខណ្ឌរបស់និស្សិតសម្រាប់សិក្សា ៥

ជំពូកទី២ វិទ្យាសាស្ត្រនៃវិធីសាស្ត្រស្រាវជ្រាវ ៦

១. លក្ខណៈទូទៅ ៦

២. វិធីសាស្ត្រស្រាវជ្រាវ ៦

ក. ការស្រាវជ្រាវតាមបែបគុណវិស័យ ៦

ខ. ការស្រាវជ្រាវតាមបែបបរិវិស័យ ៧

គ. ការស្រាវជ្រាវតាមបែបបណ្តុំឯកសារ ៨

ឃ. ការស្រាវជ្រាវតាមបែបករណីសិក្សា ៩

ង. ការស្រាវជ្រាវតាមបែបពិសោធន៍ ៩

៣. ទម្រង់នៃការស្រាវជ្រាវ ១០

ក. ការស្រាវជ្រាវសុទ្ធសាធ ១០

ខ. ការស្រាវជ្រាវអនុវត្តន៍ ១០
៤ ផែកធាងនៃការស្រាវជ្រាវ ១១
៥ ដំណាក់កាលនៃដំណើការស្រាវជ្រាវ ១១
ក. ជំហានទី១ ការកំណត់ប្រធានបទ ១១
ខ. ជំហានទី២ ការរៀបចំផែនការ ១២
គ. ជំហានទី៣ ពិនិត្យស្នាដៃពាក់ព័ន្ធ ១២
ឃ. ជំហានទី៤ កំណត់វិធីសាស្ត្រ ១២
ង. ជំហានទី៥ ការកសាងកម្រងសំណួរ ១២
ច. ជំហានទី៦ ការប្រមូលទិន្នន័យ ១៣
ឆ. ជំហានទី៧ ការបញ្ចូលទិន្នន័យ និងវិភាគ ១៣
ជ. ជំហានទី៨ បញ្ចប់របាយការណ៍និងធ្វើបទបង្ហាញ ១៣
៦. ការកំណត់អថេរ និងសម្មតិកម្ម ១៣
ក. អថេរ ១៣
ខ. សម្មតិកម្ម ១៤
គ. របៀបផ្តល់សម្មតិកម្ម ១៥
ឃ. គោលបំណងវត្ថុបំណង ១៥
ឃ. ១. គោលបំណង ១៥
ឃ. ២. វត្ថុបំណង ១៥
ង.ចំណោទបញ្ហានៃការស្រាវជ្រាវ ១៥
ច.លក្ខណៈសម្បត្តិនៃសំណើស្រាវជ្រាវនិងទស្សនៈវិស័យ ១៦
ច. ១. លក្ខណៈសម្បត្តិនៃសំណើ ១៦
ច. ២. ទស្សនៈវិស័យ ១៦
ជំពូកព៣ វិធីសាស្ត្រសម្ភាសន៍និងជ្រើសរើសគំរូតាង ១៧
១. អ្វីជាការសម្ភាស? ១៧
២. ដំណាក់កាលសម្ភាសន៍ ១៧
ក. មុនពេលសម្ភាសន៍ ១៧
ខ. ពេលសម្ភាសន៍ ១៧
គ. ក្រោយពេលសម្ភាសន៍ ១៧
៣. លក្ខណៈសម្បត្តិនៃអ្នកសម្ភាសន៍ ១៧
៤. ប្រភេទសំណួរសម្រាប់សម្ភាសន៍ ១៨
ក. សំណួរបើក ១៨
ខ. សំណួរបិទ ១៨

គ. សំណួរនាំមុខ ១៩
ឃ-សំណួរជជីក ១៩
៥. គំរូតាង ២០
ក. គំរូតាងជាអ្វី? ២០
ខ. ប្រភេទនៃគំរូតាង ២០
ខ. ១. គំរូតាងមនុស្ស ២០
ខ. ២. គំរូតាងទីតាំង ២០
៦. វិធីសាស្ត្រជ្រើសរើសសំណាក ២១
ក. ដោយចៃដន្យ ២១
ខ. ដោយមិនចៃដន្យ ២១
៧. ក្រមសីលធម៌ក្នុងការស្រាវជ្រាវ ២១
ក. អ្វីជាក្រមសីលធម៌ ២១
ខ. ក្រមសីលធម៌ស្តង់ដារ ២២
ជំពូកទី៤ របៀបសរសេរសំណើស្រាវជ្រាវ និងការគ្រប់គ្រងគម្រោង ២៤
១. អ្វីទៅជាសំណើស្រាវជ្រាវ? ២៤
២. គ្រោងឆ្អឹងសំណើស្រាវជ្រាវ ២៤
៣. គំរូគម្រោងសម្រាប់សរសេររបាយការណ៍ស្រាវជ្រាវ ២៩
៤. គំរូសម្រាប់សរសេររបាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់ក្រសួងអប់រំ ... ៣៥
៥. ការគ្រប់គ្រងគម្រោង ៣៨
៦. ការវិភាគទិន្នន័យតាមកម្មវិធីSPSS16 .... ៤០
ក. គោលបំណង ៤០
ខ. យកទិន្នន័យ ៤០
គ. កន្លែងទិន្នន័យ ៤១
ឃ. វិភាគ SPSS16 .... ៤១
ង. កន្លែងសរសេរកូដ ៤១
ច. កន្លែងបង្ហាញលទ្ធផល ៤១
ឆ. កន្លែងផ្ទុកទិន្នន័យ ៤២
ជំពូកទី៥ មគ្គុទេសក្នុងការសរសេរសារណា ៤៥
១. ហេតុអ្វីចាំបាច់សរសេរសារណា ៤៥
២. ការកំណត់ទំហំសារណា ៤៥
៣. គោលការសំខាន់ៗក្នុងការសរសេរសារណា ៤៦
ក. ការប្រើទំហំអក្សរខ្មែរនិងអង់គ្លេស? ៤៦

ក. ១. ទំហំអក្សរខ្មែរ ៤៦
ក. ២. ទំហំអក្សរអង់គ្លេស ៤៧
៤. ការចាប់ផ្ដើមនិពន្ធសារណា ៤៧
៥. ការកំណត់ពេលវេលាស្រាវជ្រាវ ៤៧
៦. ការជ្រើសរើសសាស្ត្រាចារ្យណែនាំនិងប្រធានបទ ៤៩
ក. ការជ្រើសរើសសាស្ត្រាចារ្យណែនាំ ៤៩
ខ. ការជ្រើសរើសប្រធានបទ? ៤៩
គ. ទំនាក់ទំនងរវាងសាស្ត្រាចារ្យណែនាំនិងស្មេរ ៥០
ឃ. តួនាទីរបស់សាស្ត្រាចារ្យណែនាំនិងស្មេរ ៥១
ឃ.១. តួនាទីរបស់សាស្ត្រាចារ្យណែនាំ ៥១
ឃ.២. តួនាទីរបស់ស្មេរ ៥២
៧. ការវាយតម្លៃពេលការពារសារណា ៥៣
ក. គណៈកម្មការវាយតម្លៃ ៥៣
ខ. គោលការណ៍ក្នុងការដាក់ពិន្ទុ ៥៣
៨. ការបរិយាយរចនាសម្ព័ន្ធលម្អិតសារណា ៥៣
ក. ទំព័រក្របមុខ ៥៣
ខ. ចំណងជើងក្នុង ៥៤
គ. សេចក្ដីថ្លែងអំណរគុណ ៥៤
ឃ. ការឧទ្ទិស ៥៤
ង. មូលន័យសង្ខេប ៥៤
ច. ការប្រើប្រាស់អក្សរកាត់ ៥៤
ឆ. មាតិកា ៥៥
៩. ផ្នែកខ្លឹមសារ ៥៥
ក. លំនាំដើម ៥៥
ខ. សេចក្ដីផ្ដើម ៥៥
គ. តួសេចក្ដី ៥៥
គ.១. ផ្នែកទ្រឹស្ដី ៥៥
គ.២. ផ្នែកវិធីសាស្ត្រ ៥៥
គ.៣. ផ្នែកលទ្ធផល ៥៦
ឃ. សេចក្ដីសន្និដ្ឋាន ៥៦
ជំពូកទី ៦ ដំណាក់កាលនៃការស្រាវជ្រាវឯកសារ ៥៧
១. ការរៀបចំនិពន្ធ ៥៧

២. ការរៀបចំឧបករណ៍បច្ចេកទេស ៥៧
៣. ការប្រមូលឯកសារនិងការអង្កេត ៥៧
ក. ការប្រមូលឯកសារ ៥៧
ខ. ការអង្កេត ៥៨
៤. ការកំណត់ប្រភេទឯកសារ ៥៨
ក. ឯកសារជាអក្សរ ៥៨
ខ. ឯកសារជារូបភាព ៥៨
គ. ឯកសារជាសម្លេង ៥៨
៥. ការស្រាវជ្រាវតាមបណ្ណាល័យនិងមជ្ឈមណ្ឌលឯកសារ ៥៨
៦. យុទ្ធសាស្ត្រក្នុងការស្វែងរកឯកសារ ៥៩
៧. ការចម្រាញ់យកខ្លឹមសារឯកសារ ៥៩
៨ វិធីសាស្ត្រស្រាវជ្រាវជាមួយមុខសញ្ញាមនុស្ស ៥៩
ក. ប្រសិទ្ធភាពនៃការពិគ្រោះយោបល់ ៥៩
ខ. ផលប្រយោជន៍នៃការពិគ្រោះយោបល់ ៦០
គ. ការណាត់ជួបមុខសញ្ញាមនុស្ស ៦១
ឃ. ការកត់ត្រាមុខសញ្ញាមនុស្ស ៦១
ង. កិច្ចការដែលត្រូវធ្វើបន្ត ៦១
ជំពូកទី៧ ការរៀបចំខ្លឹមសារស្រាវជ្រាវ ៦១
១. ការតម្រង់ទិសការស្រាវជ្រាវ ៦៣
២. ការរៀបចំប្លង់និងសមាសធាតុសំខាន់ៗនៃគម្រោងស្រាវជ្រាវ ៦៣
៣. ចំណោទបញ្ហា ៦៣
៤. ការតម្រង់ទិសឯកសារ ៦៤
ក. ការស្រាវជ្រាវរកឃើញឯកសារច្រើន ៦៤
ខ. ការស្រាវជ្រាវរកឃើញឯកសារតិច ៦៤
៥. វិធីសាស្ត្រស្រាវជ្រាវ ៦៥
៦. ចំណងជើងបណ្ដោះអាសន្ន ៦៥
៧. រចនាសម្ព័ន្ធទូទៅនៃសាសរណា ៦៥
ក. ទំព័រចាប់ផ្ដើម ៦៦
ខ. ទំព័រខ្លឹមសារ ៦៦
ក. ទំព័រឯកសារយោង ៦៦
ខ. តារាងរូបភាព ៦៧
ជំពូកទី៨ វិធីសាស្ត្រក្នុងការផ្ដល់ឯកសារប្រភព ៦៧

១. អ្វីជាឯកសារប្រភព ៦៧
២. ប្រភេទនៃឯកសារប្រភព ៦៧
ក. ឯកសារបច្ចេកទេស ៦៧
ខ. ឯកសារសំណេរ ៦៨
គ. ចំណាត់ថ្នាក់ឯកសារប្រភព ៦៨
គ.១. ឯកសាររាក់ៗ ៦៨
គ.២. ឯកសារជ្រៅជ្រះ ៦៨
គ.៣. ឯកសារតម្កល់ ៦៩
ឃ.សទិសសន័យនៃពាក្យឯកសារប្រភព ៧០
៣. របៀបផ្តល់ឯកសារយោងតាមសៀវភៅ ៧០
ក. សៀវភៅដែលមានអ្នកនិពន្ធម្នាក់ ៧២
ខ. សៀវភៅដែលមិនមានឈ្មោះអ្នកនិពន្ធនិកន្លែងបោះពុម្ព ៧២
គ. សៀវភៅដែលមានអ្នកនិពន្ធពីរនាក់ ៧២
ឃ. សៀវភៅដែលមានអ្នកនិពន្ធបីនាក់ ៧៣
ង. សៀវភៅដែលមានអ្នកនិពន្ធច្រើនជាងបីនាក់ ៧៣
ច. សៀវភៅឥតមានឈ្មោះអ្នកនិពន្ធ ៧៥
ឆ. សៀវភៅឥតមានឈ្មោះអ្នកនិពន្ធ តែអ្នកនិពន្ធត្រូវបានគេស្គាល់ ៧៦
ជ. សៀវភៅឥតមានឈ្មោះអ្នកនិពន្ធ តែមានឈ្មោះអ្នកបកប្រែ ៧៧
ឈ. អ្នកកែសម្រួលឬអ្នកបកប្រែបន្ថែមលើឈ្មោះអ្នកនិពន្ធ ៧៨
៤. របៀបផ្តល់ឯកសារយោងដែលដកស្រង់តាម អ៊ីនធឺណេត (Internet) ៧៩
៥. សិក្សាឧទាហរណ៍គំរូសំណើស្រាវជ្រាវ ៦០

ជំពូក ១

សេចក្តីផ្តើមនៃវិធីសាស្ត្រស្រាវជ្រាវ

INTRODUCTION TO RESEARCH METHODS

សេចក្តីផ្តើម

ការរស់នៅរបស់មនុស្សក្នុងសង្គម មិនអាចកាត់ផ្តាច់ចេញពីការស្រាវជ្រាវបានឡើយ។ ចម្ងល់ ការចង់ដឹងចង់ឮ ឬការជជែកសួរនាំ គឺជាលំនាំនៃការស្រាវជ្រាវ។ មនុស្សត្រូវការមានទំនាក់ទំនងការអានការទស្សនា សកម្មភាពទាំងអស់នេះជាលំនាំនៃការស្រាវជ្រាវ ដែលជាធម្មតាគេមិនបានគិតដល់ថាវាជាការស្រាវជ្រាវទេ អ្នកខ្លះយល់ថាលុះត្រាតែអានឯកសារឬចុះសម្ភាសន៍ទើបហៅថាជាការស្រាវជ្រាវ។

ស្រាវជ្រាវ គឺកើតឡើងដោយពាក្យ ស្រាវ + ជ្រាវ ។

ស្រាវ[1] គឺក្រសាវទាញមករៀយៗ។ស្រាវសូត្រ ស្រាវខ្សែខ្លែង។ ក្នុងន័យនេះជាការប្រមែប្រមូលនូវរាល់ព័ត៌មានទាំងឡាយណាដែលជាប់ពាក់ព័ន្ធដែលយើងចង់បាន។

ជ្រាវ[2] គឺកកូរ ច្របល់រាវរក ។

ស្រាវជ្រាវ[3] គឺរាវរកឱ្យឃើញពិតរើសើពិនិត្យតាំងពីដើមដល់ចុងឱ្យឃើញសព្វគ្រប់សាកសួរពិនិត្យ សង្កេតដោយពិនិត្យយ៉ាងល្អិត ស្រាវជ្រាវរកទាល់តែឃើញការពិត ស្រាវជ្រាវរាវរកការណ៍កំបាំង។

១.ផលប្រយោជន៍នៃការស្រាវជ្រាវ

ក. ផលប្រយោជន៍សម្រាប់គ្រូ

គ្រូបង្រៀនតែងតែផ្សារភ្ជាប់នូវសកម្មភាពស្រាវជ្រាវ គ្រូត្រូវមានចំណេះដឹងស្រាវជ្រាវយ៉ាងទូលំទូលាយជាទីផុត។ ឧទាហរណ៍ដូចជាតាមវិធីសាស្ត្រកោសល្យរបស់គ្រូបង្រៀនបានចែងថា ដើម្បីបង្រៀនសិស្សក្នុងរយៈពេល១ម៉ោង គ្រូបង្រៀនត្រូវចំណាយពេលក្នុងការស្រាវជ្រាវឯកសារនិងត្រួត ពិនិត្យលើខ្លឹមសារមេរៀនឱ្យបានយ៉ាងតិច២ទៅ៤ម៉ោង។ ការសិក្សាស្រាវជ្រាវបន្ថែមទៀតមានន័យសំដៅពង្រឹងលើខ្លឹមសារ និងការឆ្លើយតបទៅនឹងចំណេះដឹងចំណេះធ្វើ ជាពិសេសភាពទាន់សម័យជាមួយនឹងយុគ្គសម័យសាកលភាវូបនីយ៍កម្ម ពីមួយថ្ងៃទៅមួយថ្ងៃ វិទ្យាសាស្ត្ររីកចម្រើនហើយតម្រូវការមនុស្សរិតតែមានសន្ទុះខ្ពស់ និងមានសភាពខ្លាំងក្លាជាទីបំផុត ដូចនេះអ្នកអប់រំត្រូវមានសកម្មភាពយ៉ាងសកម្ម និងរស់រវើកជាមួយនឹងការសិក្សាស្រាវជ្រាវ ។

---

[1] ជួន ណាត, វចនានុក្រមខ្មែរ ភ្នំពេញ បណ្ណាគារអង្គរ, ១៩៦៧, ១៥៣

[2] ជួន ណាត, វចនានុក្រមខ្មែរ ភ្នំពេញ បណ្ណាគារអង្គរ, ១៩៦៧ , ៣០២

[3] ជួន ណាត, វចនានុក្រមខ្មែរ ភ្នំពេញ បណ្ណាគារអង្គរ, ១៩៦៧,១៥០៩

ខ. ផលប្រយោជន៍សម្រាប់និស្សិត

និស្សិតត្រូវតែមានសកម្មភាពរស់រវើកជាមួយនឹងការស្រាវជ្រាវផងដែរ ។ ការស្រាវជ្រាវជួយឱ្យសិស្សនិស្សិតអាចស្វែងរកនូវព័ត៌មានថ្មីៗទាន់សម័យ ឆ្លើយតបទៅនឹងការសិក្សាសង្គម និងជាពិសេសពិភពលោក។ សិស្សឬនិស្សិតមិនត្រូវចាត់ទុកខ្លួនឯងថាជាពាងទឹកដែលរង់ចាំទទួលការចាក់បំពេញទឹកពីគ្រូបង្រៀននោះទេ តែត្រូវចាត់ទុកខ្លួនឯងថាជា បឹងដែលសម្រាប់ទទួលយកនូវទឹកគ្រប់មជ្ឈដ្ឋាន។ សិស្សនិស្សិតត្រូវឈរនៅទីតាំងមួយដែលអាចមើលឃើញច្បាស់គ្រប់ទិសដៅទាំងអស់មិនមានការឆកល្វែងឬមានអាថិកំបាំងឡើយ។ ចំពោះនិស្សិតការសិក្សានៅកម្រិតឧត្តមវិញ គឺរឹងរិតតែមិនអាចខ្វះការស្រាវជ្រាវឡើយ។ និស្សិតត្រូវស្រាវជ្រាវនូវប្រធានបទណាមួយ ដែលវាជាប់ពាក់ព័ន្ធទៅនឹងការសិក្សារបស់ខ្លួន ហើយធ្វើការការពារនូវស្នាដៃនោះដើម្បីបញ្ចប់ការសិក្សារបស់ខ្លួន។ ការសិក្សាដែលបញ្ចប់ដោយការសិក្សាស្រាវជ្រាវសរសេរសារណានោះគឺជាការសិក្សាប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។

គ. ផលប្រយោជន៍សម្រាប់បុគ្គលសង្គម

សម្រាប់បុគ្គលធម្មតាក៏អ្នកទាំងនោះ តែងតែបានប្រើប្រាស់ការស្រាវជ្រាវជានិច្ចដែលការស្រាវជ្រាវនោះមានលក្ខណៈមិនផ្លូវការដូចការសិក្សានោះទេ ប៉ុន្តែវាជាសកម្មភាពមួយដែលធ្វើឱ្យជីវិតរស់នៅប្រកបដោយសុភមង្គលទំនាក់ទំនងកក់ក្ដៅចូលក្នុងចំណោមសង្គម។

ឧទាហរណ៍

ការសួរនាំអំពីសុខទុក្ខគ្នាការតាមដានព័ត៌មានតាមកាសែតវិទ្យុ និងទូរទស្សន៍ជាដើម ។

ឃ. ផលប្រយោជន៍សម្រាប់អ្នកជំនាញវិជ្ជាជីវៈ

សម្រាប់អ្នកស្រាវជ្រាវជំនាញអាជីពបច្ចុប្បន្ន ជំនាញនេះកំពុងមានប្រជាប្រិយ៍ភាពបំផុត អ្នកស្រាវជ្រាវជំនាញ គឺជាអ្នកបំពេញការងារក្នុងគម្រោងអ្នកស្រាវជ្រាវទាំងនោះជារួមសង្កេតឃើញមានដូចជា៖អ្នកគ្រប់គ្រងគម្រោង (Project Manager) អ្នកគ្រប់គ្រងការស្រាវជ្រាវ (Research Manager)ជំនួយ ការស្រាវជ្រាវ(Research Assistant) អ្នកសម្របសម្រួល (Coordinator) អ្នកអភិបាល (Supervisor) អ្នក សម្ភាសន៍ (DataCollector)ជាដើម។

២. កម្រិតនៃការសិក្សានិងស្រាវជ្រាវសម្រាប់វិស័យអប់រំ

ក. មធ្យមបច្ចេកទេស (Associate's Degree)

សម្រាប់ការសិក្សាថ្នាក់មធ្យមសិក្សាបច្ចេកទេស ឬថ្នាក់បរិញ្ញាបត្ររង គឺតម្រូវឱ្យនិស្សិតសិក្សារយៈពេល២ឆ្នាំស្មើនឹង៤ឆមាស ហើយឆមាសចុងក្រោយនិស្សិតត្រូវតែមានសកម្មភាព

ស្រាវជ្រាវលើប្រធានបទមួយសមស្រប ដែលអត្ថបទស្រាវជ្រាវ (Research paper) នោះគឺពឹងផ្អែកទាំងស្រុងលើប្រភព ឬឯកសារចាស់១០០ភាគរយ។

ខ. ឧត្តមសិក្សា (Bachelor's Degree)

សម្រាប់ការសិក្សាថ្នាក់ឧត្តមសិក្សា គឺនិស្សិតដែលបានបញ្ចប់ត្រូវទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ។ការសិក្សានេះ និស្សិតត្រូវរៀនរយៈពេល៤ឆ្នាំពេញ ស្មើនឹង៨ឆមាសក្នុងនោះឆមាសចុងក្រោយតម្រូវឱ្យនិស្សិតធ្វើការសិក្សាស្រាវជ្រាវ លើប្រធានបទស្រាវជ្រាវជាទម្រង់កូនសារណា (Baby Thesis or MinorThesis) ដែលត្រូវប្រើប្រភពឯកសារចាស់ប្រហែល ៨០ភាគរយនិងគំនិតយោបល់ផ្ទាល់ខ្លួន២០ភាគរយ ។

គ. ក្រោយឧត្តម (Master's Degree)

សម្រាប់ថ្នាក់ក្រោយឧត្តមសិក្សា និស្សិតដែលបានបញ្ចប់ ត្រូវទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬសញ្ញាបត្រអនុបណ្ឌិត។ ការសិក្សានេះតម្រូវឱ្យរៀនរយៈពេល២ឆ្នាំ ស្មើនឹង៤ឆមាសក្នុងនោះឆមាសចុងក្រោយ និស្សិតត្រូវធ្វើការសិក្សាស្រាវជ្រាវ លើប្រធានបទស្រាវជ្រាវជាទម្រង់សារណា (Thesis) ដែលការងារនេះត្រូវប្រើប្រភពឯកសារចាស់ពី៤០-៦០ភាគរយ។ ការសិក្សាកម្រិតនេះមានពីរប្រភេទ៖

- ការបញ្ចប់ការសិក្សាដោយប្រឡង (Master's Non-Thesis)
- ការបញ្ចប់ការសិក្សាដោយស្រាវជ្រាវ (Master's In-Thesis)

ចំពោះការបញ្ចប់ការសិក្សានៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់នេះ បើសិនជានិស្សិតជ្រើសរើសយកការបញ្ចប់ការសិក្សារបស់ខ្លួនដោយការសរសេរសារណា នោះនិស្សិតអាចបន្តការសិក្សារបស់ខ្លួនថ្នាក់ បណ្ឌិតបានដោយងាយស្រួលនិងគ្មានឧបសគ្គ។ ប៉ុន្តែចំពោះនិស្សិតដែលបញ្ចប់ការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ដោយការប្រឡងបញ្ចប់នោះ វាពិតជាមានការលំបាកនិងមានឧបសគ្គយ៉ាងខ្លាំងក្នុងការបន្ត ការសិក្សាទៅថ្នាក់បណ្ឌិតពេលក្រោយទៀត។ មានន័យថានិស្សិតត្រូវធ្វើការសិក្សាស្រាវជ្រាវទៅលើថ្នាក់អនុបណ្ឌិតឡើងវិញ ទើបអាចបន្តការសិក្សាក្នុងកម្រិតបណ្ឌិតបានដោយងាយស្រួល។

ឃ. បណ្ឌិតនិងក្រោយបណ្ឌិត (PhD/Doctoral, Post Doctoral)

និស្សិតតម្រូវឱ្យរៀនផ្នែកទ្រឹស្តីក្នុងរយៈពេលមួយកំណត់ ហើយប្រឡងនូវមុខវិជ្ជាអប្បរិមាដើម្បីជាប់បេក្ខជនបណ្ឌិត ក្រោយមកនិស្សិតតម្រូវឱ្យធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទស្រាវជ្រាវវិទ្យាសាស្ត្រក្នុងរយៈពេលមួយវែង ការស្រាវជ្រាវនេះជាទម្រង់និក្ខេបបទ (Full Thesis or Dissertation) ដែលត្រូវរកនូវរបកគំហើញថ្មីស្ទើរតែ១០០ភាគរយ។ សម្រាប់បរិបទប្រទេស

កម្ពុជាប្រភេទនៃការសិក្សាថ្នាក់បណ្ឌិត ឬការស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិតត្រូវបានចែកចេញជាបីប្រភេទគឺ៖

ឃ.១. សញ្ញាបត្របណ្ឌិតស្រាវជ្រាវ (PhD, Research)

គឺជាប្រភេទសញ្ញាបត្រឧត្តមសិក្សាខ្ពស់បំផុត ដែលត្រូវបានប្រគល់ជូនទៅបុគ្គលណាម្នាក់ដោយផ្អែកលើការទទួលស្គាល់ស្នាដៃឆ្នើម ទាំងខាងវិធីសាស្ត្រស្រាវជ្រាវនិងខាងលទ្ធផលនៃការស្រាវជ្រាវ ដែលអាចបោះពុម្ពក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ព្រមទាំងមានការរួមចំណែកក្នុងការសិក្សាស្រាវជ្រាវសម្រាប់ការបង្កើតចំណេះដឹងនិងការអនុវត្តថ្មី។

ឃ.២. សញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ (PhD,)

គឺជាប្រភេទសញ្ញាបត្រឧត្តមសិក្សាខ្ពស់បំផុត ដែលត្រូវបានប្រគល់ជូនទៅបុគ្គលណាម្នាក់ដែលបានសិក្សាមុខជំនាញដូចជាវេជ្ជសាស្ត្រ ឱសថសាស្ត្រ វិស្វកម្ម អប់រំ ធុរកិច្ច និងវិចិត្រសិល្បៈជាដើម។ បុគ្គលដែលបានទទួលសញ្ញាបត្រប្រភេទនេះ បំពេញកិច្ចការជាក់ស្តែងជាចម្បងមកចងក្រងចំណេះដឹង ដែលបានមកពីការសិក្សា និងបទពិសោធន៍ការងារទៅតាមវិធីសាស្ត្រ។ បុគ្គលទាំងឡាយណាដែលបានទទួលសញ្ញាបត្រប្រភេទនេះ បំណងជាចម្បងគឺការបង្កើនសមត្ថភាពវិជ្ជាជីវៈផ្ទាល់ខ្លួនឱ្យកាន់តែប្រសើរឡើង។ ចំពោះគោរម្យងារជាព្រឹទ្ធាចារ្យសិល្បៈ មានកម្រិតសមមូលនឹងសញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ[4]។

ឃ.៣. សញ្ញាបត្របណ្ឌិតកិត្តិយស

ជាសញ្ញាបត្របណ្ឌិតដែលគ្រឹះស្ថានឧត្តមសិក្សា ប្រគល់ជូនបុគ្គលណាម្នាក់ដោយសារការទទួលស្គាល់ស្នាដៃឆ្នើមកម្រិតខ្ពស់ ដែលមានអត្ថប្រយោជន៍ដល់សង្គមនិងមនុស្សជាតិតាមរយៈសមិទ្ធផលការងារការសរសេរសៀវភៅឬការផ្សព្វផ្សាយការស្រាវជ្រាវជាដើម។

ង. លក្ខខណ្ឌសម្រាប់បណ្តុះបណ្តាលថ្នាក់បណ្ឌិត

លក្ខខណ្ឌនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត សម្រាប់បរិបទប្រទេសកម្ពុជាមានដូចខាងក្រោម៖

ង.១. ការបបណ្តុះបណ្តាល

គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់គោលការណ៍ក្នុងការបណ្តុះបណ្តាលឱ្យបានច្បាស់លាស់គ្រឹះស្ថានឧត្តមសិក្សា ត្រូវរៀបចំកម្មវិធីសិក្សាថ្នាក់បណ្ឌិតឱ្យមានសមាសភាគនៃចំណេះដឹងកម្រិតខ្ពស់។ សមាសភាគនេះមានដូចជា៖

- ការសិក្សាវិធីសាស្ត្រស្រាវជ្រាវ និងវិធីសាស្ត្រនានា នៃការវិភាគទិន្នន័យ។
- ការសិក្សាដែលផ្តល់ចំណេះដឹងខ្ពស់ពាក់ព័ន្ធនិងទ្រឹស្តី និងការអនុវត្តវិជ្ជាជីវៈ

[4] រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ភ្នំពេញ , ២០១០, ២

សក្តិសមនឹងជំនាញ និងកម្រិតសញ្ញាបត្រ។

- សកម្មភាពរៀបចំឡើង ដើម្បីពង្រីកចំណេះដឹងរបស់និស្សិត ក្នុងការស្រាវជ្រាវស្របតាមជំនាញ។

ង.២. រចនាសម្ព័ន្ធនិងរយៈពេលបណ្តុះបណ្តាល

គ្រឹះស្ថានឧត្តមសិក្សាត្រូវមានសេចក្តីប្រកាសឱ្យបានច្បាស់លាស់ អំពីរយៈពេលសិក្សា និងការស្រាវជ្រាវនៃការសិក្សាថ្នាក់បណ្ឌិត។ ការសិក្សាថ្នាក់បណ្ឌិតមានរយៈពេលពី៣ (បី) ទៅ ៦(ប្រាំមួយ)ឆ្នាំសម្រាប់ថ្នាក់បណ្ឌិតពេញម៉ោង និងរហូតដល់៨(ប្រាំបី)ឆ្នាំ សម្រាប់ថ្នាក់បណ្ឌិតមិនពេញម៉ោង។

ង.៣. លក្ខណៈសម្បត្តិរបស់និស្សិតក្នុងការសិក្សាបណ្ឌិត

លក្ខខណ្ឌជាមូលដ្ឋានក្នុងការជ្រើសរើសនិស្សិតមានដូចជា៖

1. ពិន្ទុខ្ពស់ក្នុងការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់។
2. សមត្ថភាពក្នុងការស្រាវជ្រាវ។
3. ចំណេះដឹងភាសាបរទេស។
4. ពិន្ទុប្រឡងចូល និងសេចក្តីស្នើគម្រោងស្រាវជ្រាវរបស់និស្សិត។

ជំពូក២

វិទ្យាសាស្ត្រនៃវិធីសាស្ត្រស្រាវជ្រាវ
SCIENTIFIC OF RESARCH METHODOLOGY

១. លក្ខណៈទូទៅ (Generally)

គេសង្កេតឃើញស្នាដៃស្រាវជ្រាវមួយ ដែលអាចចាត់ទុកថាជាស្នាដៃវិទ្យាសាស្ត្រនិងមានស្តង់ដាលុះត្រាតែស្នាដៃទាំងនោះ បានប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវត្រឹមត្រូវសមស្របហើយឆ្លើយតបទៅនឹងប្រធានបទស្រាវជ្រាវរបស់ខ្លួន។ សម្រាប់វិស័យអប់រំនិងជំនាញអាជីពមានវិធីសាស្ត្រស្រាវជ្រាវជាច្រើន ប៉ុន្តែវិធីសាស្ត្រដែលមានប្រជាប្រិយភាពជាងគេមានដូចជា៖

- ការស្រាវជ្រាវតាមបែប គុណវិស័យ (Qualitative Research Method)
- ការស្រាវជ្រាវតាមបែប បរិវិស័យ (Quantitative Research Method)
- ការស្រាវជ្រាវតាមបែប បណ្ដុំឯកសារ (Document Research Method)
- ការស្រាវជ្រាវតាមបែប ករណីសិក្សា (Case study Research Method)
- ការស្រាវជ្រាវតាមបែប ពិសោធន៍ (Experiment Research Method)

២. វិធីសាស្ត្រស្រាវជ្រាវ (Research Method)

ខាងក្រោមជានិយមន័យនៃវិធីសាស្ត្រស្រាវជ្រាវនីមួយៗ និងរបៀបដែលអ្នកស្រាវជ្រាវធ្វើការអនុវត្តន៍ហើយបានទទួលជោគជ័យ។

ក. ការស្រាវជ្រាវតាមបែបគុណវិស័យ (Qualitative Method Research)

គឺជាវិធីសាស្ត្រស្រាវជ្រាវមួយដែលមានលក្ខណៈពិបាកជាងគេ ក្នុងចំណោមវិធីសាស្ត្រស្រាវជ្រាវនានាខាងលើនេះ តម្រូវឱ្យអ្នកស្រាវជ្រាវធ្វើការសិក្សាទៅលើក្រុមពិភាក្សាហើយធ្វើការវិភាគលើខ្លឹមសារពាក្យសម្តីឃ្លាប្រយោគនៃក្រុមទិសដៅ។

លក្ខណៈ និងរបៀបអនុវត្តន៍

- ប្រមូលឯកសារប្រភពដែលជាប់ពាក់ព័ន្ធ
- រៀបចំឱ្យទៅជាផ្នែកទ្រឹស្តី
- សិក្សាពីក្រុមក្រុមទិសដៅ
- ពិភាក្សាពី៥ទៅ១២ក្រុមពិភាក្សា អាស្រ័យលើទំហំនៃការសិក្សា
- សមាជិកនៃក្រុមពិភាក្សាមានពី៧ទៅ១១នាក់
- សមាជិកពិភាក្សានីមួយៗ ត្រូវមានប្រវត្តិដូចគ្នា ប៉ុន្តែគ្មានទំនាក់ទំនងជិតស្និទ្ធទេ
- ប្រភេទទម្រង់សំណួរប្រើប្រាស់សម្រាប់ពិភាក្សា គឺទម្រង់សំណួរបើកស្ទើតែ១០០%

ឧទាហរណ៍

1. តើលោកគិតយ៉ាងណា ចំពោះការសិក្សារបស់កុមារថ្នាក់តូចពេលបច្ចុប្បន្ននេះ?
2. អ្នកមានមតិយ៉ាងណា ជុំវិញការអប់រំកម្រិតឧត្តមសិក្សា?
3. តើអ្នកមានយោបល់យ៉ាងណា ចំពោះការសិក្សារបស់និស្សិតអក្សរសាស្ត្រខ្មែរ?

- ចំនួនសំណួរ អាចមានពី១០ ទៅ១៧សំណួរ អាស្រ័យលើទំហំនៃការស្រាវជ្រាវ
- បុគ្គលដឹកនាំនឹងការស្រាវជ្រាវរួមមាន ប្រធាន អ្នកសម្របសម្រួល និងអ្នកកត់ត្រា
- សម្ភារៈ ប៊ិច ក្រដាស ម៉ាស៊ីនថតសម្លេង ថតរូប និងថវិកា។ល។
- កត់ត្រាឱ្យបានច្បាស់លាស់ និងធ្វើការវិភាគនូវលទ្ធផល ដែលបានពីរបាយការណ៍នៃកិច្ចពិភាក្សាប្រកបដោយគំនិតច្នៃប្រឌិត និងពឹងផ្អែកលើបច្ចេកទេសវិទ្យាសាស្ត្រធ្វើការឆ្លុះ បញ្ចាំងនិងបទបង្ហាញរបស់ខ្លួនក្នុងជំពូកលទ្ធផល។
- ធ្វើចំណាត់ថ្នាក់ ពាក្យពេចន៍ចម្លើយជាក្រុមរួចធ្វើការវិភាគដោយឈរលើលទ្ធផលនៃការ សង្កេតរួមមានរបៀបឆ្លើយ រូបថត ពាក្យពេចន៍ និងអាកប្បកិរិយាជាដើម។
- រយៈពេលនៃការពិភាក្សាក្រុមពី១ម៉ោងទៅ១: ៣០នាទី

ខ. ការស្រាវជ្រាវតាមបែបបរិស័យ (Quantitative Method Research)

វិធីសាស្ត្រស្រាវជ្រាវនេះ គឺមានលក្ខណៈប្រហាក់ប្រហែលទៅនឹងវិធីសាស្ត្រស្រាវជ្រាវខាងលើដែរ ប៉ុន្តែវិធីសាស្ត្រនេះ តម្រូវឱ្យអ្នកស្រាវជ្រាវធ្វើការសិក្សាវិភាគលើចំនួនក្រុមមនុស្សដោយសម្ភាសន៍មួយទល់មួយជាពិសេសគឺធ្វើការសិក្សាលើចំនួនតួលេខដែលបានសម្ភាសន៍។

លក្ខខណ្ឌ និងរបៀបអនុវត្តន៍

- ប្រមូលឯកសារដែលមានការទាក់ទង
- រៀបចំឱ្យទៅជាលក្ខណៈទ្រឹស្តី
- ធ្វើការសិក្សាលើក្រុមគោលដៅ
- សម្ភាសន៍ស៊ីជម្រៅមួយទល់នឹងមួយម្នាក់ម្តងៗ រហូតដល់គ្រប់នូវចំនួនក្រុមទិសដៅ
- ចំនួនក្រុមទិសដៅអាចមានរយ ពាន់ ទៅម៉ឺននាក់ អាស្រ័យលើទំហំនៃការស្រាវជ្រាវ
- ប្រភេទទម្រង់សំណួរដែលប្រើក្នុងការសម្ភាសន៍ ជាទម្រង់សំណួរបិទស្ទើរតែ១០០%

ឧទាហរណ៍

១. តើអ្នកមានអាយុប៉ុន្មាន?

២. តើអ្នករៀនដល់ថ្នាក់ទីប៉ុន្មាន?

៣. តើអ្នកយល់ស្របយ៉ាងណាចំពោះ...?

ក. មិនយល់ស្របទាល់តែសោះ

ខ. យល់ស្របតិចតួច

គ. យល់ស្របល្មម

ឃ. យល់ស្របខ្លាំង

៤. តើការបោះឆ្នោតតំណាងរាស្ត្រ នៅប្រទេសកម្ពុជា ពីឆ្នាំ១៩៩៣មកមានប៉ុន្មានដង?

ក. ចំនួន៤ដង

ខ. ចំនួន៣ដង

គ. ចំនួន២ដង

- ចំនួនសំណួរអាចពី៥០ ទៅ១០០ ឬច្រើនរយសំណួរអាស្រ័យលើទំហំនៃស្រាវជ្រាវ
- បុគ្គលដឹកនាំការស្រាវជ្រាវ ប្រធាន អ្នកសម្របសម្រួលនិងអ្នកសម្ភាសន៍
- ឧបករណ៍គាំទ្រ: ប៊ិច ក្រដាស ម៉ាស៊ីនថតរូប ម៉ាស៊ីមថតសំលេង ថវិកា។ល។
- រយៈពេលសម្ភាសន៍សម្រាប់ម្នាក់ (ក្រុមទិសដៅម្នាក់) ពី៣០នាទី ទៅ១ម៉ោង
- បញ្ចូលនូវទិន្នន័យរួចវិភាគតាមលទ្ធផលជាក់ស្តែងកម្មវិធី (SPSS)
- ធ្វើការសន្និដ្ឋានដោយផ្អែកលើបច្ចេកទេសត្រឹមត្រូវ

គ. ការស្រាវជ្រាវតាមបែបបណ្ណុំឯកសារ (Documentary Method Research)

វិធីសាស្ត្រស្រាវជ្រាវតាមបែបបណ្ណុំឯកសារ គឺជាវិធីសាស្ត្រស្រាវជ្រាវមួយប្រភេទដែលពឹងផ្អែកទាំងស្រុងលើឯកសារឬប្រភពនៃទិន្នន័យចាស់។ វិធីសាស្ត្រនេះមិនតម្រូវឱ្យអ្នកសិក្សាស្រាវជ្រាវធ្វើការចុះសម្ភាសន៍លើក្រុមទិសដៅនោះទេ ប៉ុន្តែត្រូវសម្ភាសន៍យកប្រភពទិន្នន័យចាស់។

លក្ខខណ្ឌ និងរបៀបអនុវត្តន៍

- ប្រមូលនូវឯកសារដែលជាប់ពាក់ព័ន្ធ
- អានដោយយកចិត្តទុកដាក់
- កត់ចំណាំនូវឃ្លាអត្ថបទដែលជាប់ទាក់ទងនឹងប្រធានបទស្រាវជ្រាវ
- ដកស្រង់នូវចំណុចសំខាន់ៗទាំងនោះ
- រៀបចំកែសម្រួលឱ្យទៅជាឃ្លាថ្មី ប្រយោគថ្មី តែរក្សាន័យដើម
- ធ្វើយ៉ាងណាឱ្យមានលក្ខណៈងាយអាន ងាយយល់ និងមានលក្ខណៈវិទ្យាសាស្ត្រនិងទិន្នន័យច្បាស់លាស់ជាងមុន។
- រៀបចំតាមលំដាប់មានផ្នែកណែនាំផ្នែកទ្រឹស្តី ផ្នែកវិធីសាស្ត្រនិងផ្នែកសន្និដ្ឋានជាដើម
- អាចបញ្ចូលនូវករណីសិក្សា១ឬ ២ករណី
- បុគ្គលស្រាវជ្រាវអាចសរសេរជាក្រុម មានប្រធាន និងសមាជិក

- ឧបករណ៍គាំទ្រ: ប៊ិច ក្រដាស ម៉ាស៊ីនថតរូប ម៉ាស៊ីមថតសំលេង ថវិកា។ល។

ឃ. ការស្រាវជ្រាវតាមបែបករណីសិក្សា (Case study Method Research)

វិធីសាស្ត្រស្រាវជ្រាវតាមបែបករណីសិក្សា ជាវិធីសាស្ត្រស្រាវជ្រាវមួយបែប ដែលមានលក្ខណៈដូចគ្នាទៅនឹងវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យដែរ ប៉ុន្តែវិធីសាស្ត្រនេះមានលក្ខណៈស៊ីជម្រៅជាង ព្រោះក្រុមទិសដៅតម្រូវឱ្យមានតែម្នាក់ឬពីរនាក់ប៉ុណ្ណោះ ហើយអ្នកស្រាវជ្រាវត្រូវស្នាក់នៅជាអចិន្ត្រៃយជាមួយ នឹងកម្មវត្ថុសិក្សា តែម្តង។

លក្ខខណ្ឌ និងរបៀបអនុវត្តន៍

- ប្រមូលនូវឯកសារដែលជាប់ពាក់ព័ន្ធ
- រៀបចំឱ្យទៅជាលក្ខណៈទ្រឹស្តី
- ទទួលការអនុញ្ញាតពីស្ថាប័នសាមី
- ទទួលការអនុញ្ញាតពីកម្មវត្ថុសិក្សាដែលជាក្រុមទិសដៅ
- ត្រូវស្នាក់នៅជាអចិន្ត្រៃយជាមួយក្រុមទិសដៅរយៈពេលយ៉ាងតិច ១ឆ្នាំទៅ២ឆ្នាំ
- អ្នកស្រាវជ្រាវ មានភារៈជាអ្នកស្រាវជ្រាវផង ជាជំនួយការរបស់កម្មវត្ថុសិក្សាផង
- កម្មវត្ថុសិក្សា មានភារៈជាក្រុមទិសដៅផងជាអ្នកណែនាំផង
- ត្រូវកត់ត្រាលម្អិតអំពីចំណុចខ្លាំង ចំណុចខ្សោយ អំពីជោគជ័យ
- កត់ត្រាលម្អិតអំពីជីវិតឯកជន ជីវភាពរស់នៅ ជីវភាពគគ្រួសារជីវភាពការងារ
- ធ្វើការវិភាគ សន្និដ្ឋានប្រកបដោយវិទ្យាសាស្ត្រ ឆ្លើយតបតាមរបាយការណ៍ស្រាវជ្រាវ
- បុគ្គលស្រាវជ្រាវ អាចសរសេរជាលក្ខណៈឯកជន
- ឧបករណ៍គាំទ្រ: ប៊ិច ក្រដាស ម៉ាស៊ីនថតរូប ម៉ាស៊ីមថតសំលេង ថវិកា។ល។

ង. ការស្រាវជ្រាវតាមបែបពិសោធ (Experimental Method Research)

វិធីសាស្ត្រស្រាវជ្រាវតាមបែបខាងលើនេះ គឺជាវិធីសាស្ត្រស្រាវជ្រាវមួយដែលពឹងផ្អែកទាំងស្រុងលើលទ្ធផលនៃការពិសោធរបស់របកគំហើញណាមួយ ។ វិធីសាស្ត្រនេះភាគច្រើនអ្នកស្រាវជ្រាវអនុវត្តន៍ក្នុងការស្រាវជ្រាវលើវិស័យវិទ្យាសាស្ត្រពិត ដែលទាក់ទងទៅនឹងការពិសោធនដូចជាគីមីវិទ្យា រូបវិទ្យា ជីវៈវិទ្យា វេជ្ជសាស្ត្រ។ល។

លក្ខខណ្ឌ និងរបៀបអនុវត្តន៍

- ប្រមូលនូវឯកសារដែលជាប់ពាក់ព័ន្ធ
- រៀបចំឱ្យទៅជាផ្នែកទ្រឹស្តី
- ត្រូវមានការអនុញ្ញាតពីក្រុមប្រឹក្សាវិទ្យាសាស្ត្រជំនាញ
- ត្រូវមានការអនុញ្ញាត នឹងមានការត្រួតពិនិត្យពីប្រធានមន្ទីរពិសោធន៍

- ត្រូវមានក្រុមតាមដាន និងគណៈកម្មការការពារសុវត្ថិភាពនៃលំនាំពិសោធន៍
- ត្រូវមានធនធានពិសោធសំបូរបែបគ្រប់គ្រាន់
- ធ្វើការពិសោធន៍
- កត់ត្រាលម្អិតអំពីលទ្ធផលពិសោធន៍
- រៀបចំរបាយការណ៍វិទ្យាសាស្ត្រ
- ធ្វើការវិភាគ សន្និដ្ឋានតាមលទ្ធផលពិសោធជាក់ស្តែង
- បុគ្គលស្រាវជ្រាវរួមមាន ប្រធាន សមាជិក
- សម្ភារៈ ធនធានពិសោធន៍ ប៊ិច ក្រដាស ម៉ាស៊ីនថត ថវិកា ។ល។

៣. ទម្រង់នៃការស្រាវជ្រាវ (ការស្រាវជ្រាវសុទ្ធសាធ ការស្រាវជ្រាវអនុវត្តន៍)

គេសង្កេតឃើញមានការស្រាវជ្រាវពីរប្រភេទ ដែលតែងតែជួបប្រទះការស្រាវជ្រាវនោះមានដូចខាងក្រោមគឺៈ

ក. ការស្រាវជ្រាវសុទ្ធសាធ

ជាកាសិក្សាស្រាវជ្រាវមួយប្រភេទ ដែលតម្រូវឱ្យអ្នកស្រាវជ្រាវធ្វើការស្រាវជ្រាវគ្រាន់តែប្រមូលនូវទិន្នន័យឬព័ត៌មានដែលខ្លួនចង់បានហើយប្រើព័ត៌មានទាំងនោះ ដើម្បីបំពេញការសិក្សាឬទុកជាឯកសារតម្កល់តែប៉ុណ្ណោះ។

ឧទាហរណ៍

- ការសិក្សាស្រាវជ្រាវអំពី ប្រពៃណីបុណ្យចូលឆ្នាំខ្មែរ។
- ការសិក្សាស្រាវជ្រាវអំពី ប្រពៃណីបុណ្យ អុំទូក។
- ការស្រាវជ្រាវអំពីប្រពៃណីអាពាហ៍ពិពាហ៍ខ្មែរ។

ខ.ការស្រាវជ្រាវអនុវត្តន៍

ការស្រាវជ្រាវអនុវត្តន៍ គឺជាការស្រាវជ្រាវប្រភេទ ដែលតម្រូវឱ្យអ្នកស្រាវជ្រាវមិនគ្រាន់តែសិក្សាស្វែងរកនូវព័ត៌មានដែលខ្លួនចង់បានប៉ុណ្ណោះទេ អ្នកស្រាវជ្រាវថែមទាំងផ្សារភ្ជាប់នូវសកម្មភាពស្រាវជ្រាវរបស់ខ្លួន ជាមួយនឹងគម្រោងផែនការសកម្មភាព ធ្វើអន្តរាគមនិងដោះស្រាយបញ្ហាដែលទទួលបានពីលទ្ធផលស្រាវជ្រាវទៀតផង។

ឧទាហរណ៍១ ស្រាវជ្រាវលើប្រធានបទផលប៉ះពាល់ និងការឆ្លងរីករាលដាលនៃជំងឺអេដស៍។

ឧទាហរណ៍២ ការសិក្សាស្រាវជ្រាវលើប្រធានបទ ផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ ។

ឧទាហរណ៍៣ កស្រាវជ្រាវលើប្រធានបទគុណភាពអប់រំក្នុងមហាវិទ្យាល័យអក្សរសាស្ត្រខ្មែរ។

ឧទាហរណ៍៤ សិក្សាស្រាវជ្រាវលើប្រធានបទអត្រានៃការបោះបង់ការសិក្សារបស់សិស្ស។

- លទ្ធផល

- រៀបចំផែនការសកម្មភាពបន្ត
- ធ្វើយុទ្ធនាការផ្សព្វផ្សាយ
- ផលិតសម្ភារៈ
- មប់រំ បង្ការ ការពារ
- ផ្តល់សេវាជាដើម ។

៤. ផ្នែកធំៗនៃការស្រាវជ្រាវ

1. ផ្នែកវិទ្យាសាស្ត្រពិត គណិតវិទ្យា គីមីវិទ្យា រូបវិទ្យា ជីវៈវិទ្យា វេជ្ជសាស្ត្រ បច្ចេកវិទ្យា។
2. ផ្នែកវិទ្យាសាស្ត្រសង្គម ចិត្តវិទ្យា សង្គមវិទ្យា ទស្សនៈវិជ្ជា អក្សរសាស្ត្រ ប្រវត្តិវិទ្យា។ល។

ការសិក្សាស្រាវជ្រាវគេក៏ចែកទិន្នន័យជាពីរផ្នែកទៀតគឺទិន្នន័យស្លាប់និងទិន្នន័យរស់។

- ទិន្នន័យស្លាប់ គឺជាទិន្នន័យទាំងឡាយណាដែលមានស្រាប់ ឬឯកសារដែលមានស្រាប់ ឬឯកសារចាស់ៗដែលយើងបានស្រាវជ្រាវតាមរយៈការអានជាដើម (Secondary data)។
- ទិន្នន័យរស់ គឺជាប្រភេទទិន្នន័យទាំងឡាយណា ដែលថ្មីបានមកពីការសម្ភាសឬការស្រាវជ្រាវរកឃើញថ្មី ដែលយើងទទួលបានក្នុងពេលកំពុងស្រាវជ្រាវ(Primary Data) ។

៥. ដំណាក់កាលនៃដំណើរការស្រាវជ្រាវ (Stage of Research Process)

ការសិក្សាស្រាវជ្រាវមួយដែលអាចទទួលបាននូវលទ្ធផលជោគជ័យ មានតម្លាភាពនិងមានភាពល្អនទៅបាន លុះត្រាតែការសិក្សាស្រាវជ្រាវនោះ បានអនុវត្តតាមគម្រោងផែនការនិងផែនការសកម្មភាពរបស់ខ្លួន ហើយសមស្របតាមតារាងពេលវេលាលម្អិត ដែលបានរៀបចំជាកំហិត។ មានន័យថាមុននឹងគួរត្រូវគិតឱ្យបានច្បាស់លាស់ គម្រោងផែនការសកម្មភាពជាត្រីវិស័យដ៏គាប់ប្រសើរសម្រាប់ការអនុវត្តន៍គម្រោងស្រាវជ្រាវជាទូទៅមាន៖

ក. ជំហានទី១ “ ការកំណត់ប្រធានបទ ”

- ដាក់ប្រធានបទស្រាវជ្រាវ
- សម្រេចជ្រើសរើសប្រធានបទ
- ធ្វើការសម្រួចប្រធានបទ ឱ្យមានលក្ខណៈតូចចង្អៀត សំដៅមានន័យជាក់លាក់ច្បាស់លាស់ប្រធានបទត្រូវមានមានន័យចំៗ មិនអាចិកំបាំង។
- ចំណងជើងស្រាវជ្រាវមិនដូចចំណងជើងបទចម្រៀង រឿងប្រលោមលោក ទស្សនាវដ្តី កាសែតឬចំណងជើងកំណាព្យទេ។
- ចំណងជើងនៃការស្រាវជ្រាវ ទូលំទូលាយធំហួសមាឌ ធ្វើឱ្យការសិក្សាស្រាវជ្រាវមិនច្បាស់នៅគោលដៅនៃការស្រាវជ្រាវរបស់ខ្លួន។

ឧទាហរណ៍: "ការអប់រំនៅកម្ពុជា"

- ការអប់រំក្រៅប្រព័ន្ធនៅកម្ពុជា
- អត្រានៃការបោះបង់ការសិក្សារបស់សិស្សនៅអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា
- ការគ្រោះថ្នាក់ចរាចរនៅប្រទេសកម្ពុជា
- ភាពក្រីក្រនៅប្រទេសកម្ពុជា
- អំពើហិង្សាក្នុងគ្រួសារនៅប្រទេសកម្ពុជា

ខ. ជំហានទី២ "ការរៀបចំផែនការ"

- រៀបចំនូវគម្រោងផែនការសកម្មភាពស្រាវជ្រាវទាំងមូល
- បញ្ជាក់អំពីសកម្មភាពលម្អិត
- បញ្ជាក់អំពីរយៈពេលចាប់ផ្ដើម និងពេលបញ្ចប់
- រៀបចំនូវគម្រោងផែនការ ថវិកាច្បាស់លាស់
- បង្ហាញអំពីផលប្រយោជន៍ និងសារៈប្រយោជន៍នៃការស្រាវជ្រាវ
- បង្ហាញប្រាប់អំពីមូលហេតុនៃការសិក្សាស្រាវជ្រាវ
- ព្យាករណ៍អំពីយថាហេតុ និងដំណោះស្រាយបម្រុង

គ. ជំហានទី៣ "ពិនិត្យស្នាដៃពាក់ព័ន្ធ"

- ប្រមូលឯកសារពិនិត្យលើស្នាដៃពាក់ព័ន្ធជាពិសេសស្នាដៃដែលទើបស្រាវជ្រាវថ្មីៗ
- អានដោយយកចិត្តទុកដាក់យកតែចំណុចសំខាន់ៗ ដែលគាំទ្រស្នាដៃរបស់ខ្លួន

ឃ. ជំហានទី៤ "ការកំណត់វិធីសាស្ត្រ"

- ត្រូវជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវដែលសមស្របទៅនឹងប្រធានបទ
- អ្នកស្រាវជ្រាវត្រូវបង្ហាញនូវចំណោទបញ្ហានៃការស្រាវជ្រាវ
- *កំណត់នូវអថេរ និងសម្មតិកម្មវិទ្យាសាស្ត្រ*
- កំណត់ព្រំដែននៃការស្រាវជ្រាវដើម្បីបញ្ជាក់នូវវិសាលភាពនៃការស្រាវជ្រាវ

ង. ជំហានទី៥ "ការកសាងកម្រងសំណួរ"

- ត្រូវផលិតកម្រងសំណួរតាមលក្ខណៈបច្ចេកទេស ជាពិសេសពិភាក្សាជាមួយអ្នកជំនាញ កម្រងសំណួរសម្រាប់សម្ភាសន៍ត្រូវឆ្លើយតបទៅនឹងប្រធានបទ។
- របៀបផលិតសំណួរត្រូវមាន(សំណួរបើក សំណួរបិទ ជជីក នាំមុខ)
- អ្នកសិក្សាស្រាវជ្រាវគប្បីយល់ឱ្យបានច្បាស់នៅប្រភេទសំណួរ អ្វីជាប្រភេទ សំណួរ

លើក សំណួរបិទ សំណួរនាំមុខ សំណួរជជីក ហើយសំណួរនីមួយៗត្រូវប្រាកដថាពិតជាមានលក្ខណៈបច្ចេកទេស។

ច. ជំហានទី៦ "ការចុះប្រមូលទិន្នន័យ"

- ត្រូវមានការសម្ភាសសាកល្បង
- រៀបចំពិនិត្យសំណួរឡើងវិញ(អាចមានការប្រជុំជាមួយអ្នកចុះសម្ភាសន៍)
- ធ្វើការបណ្តុះបណ្តាលអំពីខ្លឹមសារសំណួរ និងរបៀបសម្ភាសន៍ម្តងទៀត
- ធ្វើការសម្ភាសសាកល្បងម្តងទៀត
- ធ្វើការសម្ភាសជាផ្លូវការតាមគម្រោងផែនការ
- ធ្វើការពិនិត្យនូវសុវត្ថិភាពទិន្នន័យ(ទិន្នន័យត្រឹមត្រូវដែរឬទេ)

ឆ. ជំហានទី៧ "ការបញ្ចូលទិន្នន័យ និងវិភាគ"

- ធ្វើកាសំអាតទិន្នន័យឱ្យបានត្រឹមត្រូវ
- បញ្ចូលទិន្នន័យនិងវិភាគតាមកម្មវិធីដែលបានកំណត់(SPSS)
- ចាប់ផ្តើមសរសេររបាយការណ៍
- ធ្វើការសន្និដ្ឋានដោយឈរលើលក្ខណៈវិទ្យាសាស្ត្រ

ជ. ជំហានទី៨ "បញ្ចប់របាយការណ៍ និងធ្វើបទបង្ហាញ"

- ពិនិត្យខ្លឹមសារព្រាងលើកទី១
- ពិនិត្យខ្លឹមសារបញ្ចប់
- រៀបចំបោះពុម្ព និងធ្វើបទបង្ហាញ

៦. ការកំណត់អថេរនិងសម្មតិកម្ម (Variable and Hypothesis)

នៅក្នុងការសិក្សាស្រាវជ្រាវ អ្នកស្រាវជ្រាវត្រូវធ្វើការកំណត់នូវអថេរនិងសម្មតិកម្មរបស់ខ្លួនឱ្យបានច្បាស់លាស់ការកំណត់អថេរត្រូវចែកជាពីរគឺ អថេរអាស្រ័យ និងអថេរមិនអា ស្រ័យ

ក. អថេរ

- អថេរអាស្រ័យ (Dependent Variable: DV) គឺជាលក្ខណៈប្រែប្រួល។
- អថេរមិនអាស្រ័យ (Independent Variable: IV) គឺជាកត្តាឬដើមហេតុដែលនាំឱ្យប្រែប្រួល ។

ឧទាហរណ៍១ ប្រធានបទ "អំពើហិង្សាក្នុងគ្រួសារ"

- DV.អថេរអាស្រ័យ
  - ការប្រើអំពើហិង្សាក្នុងគ្រួសារ

- IV.អថេរមិនអាស្រ័យ
  - មូលហេតុបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារបណ្តាលមកពីភាព ក្រីក្រភាពអវិជ្ជា ដោយសាការផឹកស្រា និងដោយសារអំណាចនិងការគ្រប់គ្រង។

ឧទាហរណ៍២ ប្រធានបទ "ការប្រើប្រាស់គ្រឿងញៀន"

- DV.អថេរអាស្រ័យ
  - ការប្រើប្រាស់គ្រឿងញៀន
- IV.អថេរមិនអាស្រ័យ
  - ចង់សាកល្បង អត់ការងារធ្វើ មិត្តភ័ក្តិអូសទាញ លង់ខ្លួនញៀនហើយ។ល។

ឧទាហរណ៍៣ "ជក់បារីនិងជំងឺមហារីក"

- DV.អថេរអាស្រ័យ
  - ជម្ងឺមហារីក
- IV.អថេរមិនអាស្រ័យ
  - មូលហេតុបណ្តាលឱ្យមានជម្ងឺ បញ្ហាសុខភាពការញៀន។ល។

ឧទាហរណ៍៤ ប្រធានបទ "គ្រោះថ្នាក់ចរាចរ"

- DV. អថេរអាស្រ័យ
  - ការគ្រោះថ្នាក់ចរាចរ
- IV. អថេរមិនអាស្រ័យ
  - មូលហេតុបណ្តាលមកពីយានយន្តច្រើន ផ្លូវតូច ស្រវឹងស្រា មិនគោរពច្បាប់។

ខ. សម្មតិកម្ម

សម្មតិកម្មវិទ្យាសាស្ត្រក្នុងការសិក្សាស្រាវជ្រាវ គឺជាការប៉ាន់ប្រមាណ ឬជាការទស្សន៍ទាយដោយបណ្តោះអាសន្នហើយការទស្សន៍ទាយនេះ សម្រាប់ផ្ទៀងផ្ទាត់នូវលទ្ធផលនៃការស្រាវជ្រាវថាតើវាឆ្លើយតបទៅនឹងការស្រាវជ្រាវបានប៉ុន្មាន%។ ជាធម្មតាការទស្សន៍ទាយមិនអាចពិតប្រាកដបាន១០០ភាគរយគ្រប់ការទស្សន៍ទាយនោះទេ ប៉ុន្តែគ្រប់ការទស្សន៍ទាយត្រូវតែធ្វើយ៉ាងណាឱ្យមានលក្ខណៈវិទ្យាសាស្ត្រនិងអាចទទួលយកបាន។

បើការទស្សន៍ទាយមានបញ្ហា មិនឆ្លើយតបទាំងស្រុងនោះ អ្នកស្រាវជ្រាវត្រូវប្រឈមមុខនឹង៖

- បន្ថែមការស្រាវជ្រាវថែមទៀត
- ខាតបង់ពេលវេលា
- ខាតបង់ថវិកា

គ. របៀបផ្តល់សម្មតិកម្ម

ប្រធានបទទី១ "អំពើហិង្សាក្នុងគ្រួសារ"

- ស្ត្រីដែលរស់នៅជាមួយប្តីផឹកស្រា លេងល្បែងប្រហែលជាមានអំពើហិង្សាខ្ពស់ជាងស្ត្រីដែលរស់នៅជាមួយប្តីមិនផឹកស្រា និងមិនលេងល្បែងស៊ីសង។

- ស្ត្រីដែលរស់នៅក្នុងស្ថានភាពគ្រួសារក្រីក្រ ប្រហែលជាមានអំពើហិង្សាខ្ពស់ជាងស្ត្រីដែលរស់នៅក្នុងជីវភាពធូរធារ។

ប្រធានបទទី២"ការប្រើប្រាស់គ្រឿងញៀន"

- សិស្សដែលតែងគេចសាលា ប្រហែលជាប្រឈមមុខនឹងការប្រើគ្រឿងញៀន ខ្ពស់ជាងសិស្សដែលមិនគេចសាលា។

- យុវជនដែលមិនមានការងារធ្វើ ទំនងជាប្រឈមទៅនឹងការប្រើប្រាស់គ្រឿងញៀនខ្ពស់ជាងយុវជនដែលមានការការងារធ្វើ។

ប្រធានបទទី ៣ "ជក់បារីនិងជំងឺមហារីក"

- អ្នកដែលចូលជក់បារីជាប្រចាំទំនងជាប្រឈមមុខនឹងជម្ងឺមហារីកខ្ពស់ជាងអ្នកមិនជក់។

- អ្នកជក់បារីប្រហែលជាប្រឈមនឹងបញ្ហាសុខភាព ខ្ពស់ជាងអ្នកដែមមិនជក់បារី។

ប្រធានបទទី៤ "គ្រោះថ្នាក់ចរាចរ"

- អ្នកដែលស្រវឹងស្រាហើយបើកបរ ប្រឈមមុខនឹងគ្រោះថ្នាក់ច្រើនជាង អ្នកបើកបរមិនផឹកស្រា។

- អ្នកបើកបរមិនគោរពច្បាប់ប្រឈមមុខនឹងគ្រោះថ្នាក់ ច្រើនជាងអ្នកបើកបរគោរពច្បាប់

ឃ. គោលបំណង វត្ថុបំណង (Goal and Objectives)

ឃ.១. គោលបំណង

គឺជាការឆ្លុះបង្ហាញប្រាប់នូវបំណងប្រាថ្នា និងទិសដៅក្នុងការសិក្សាស្រាវជ្រាវរបស់យើងទៅលើប្រធានបទដែលយើងសិក្សាស្រាវជ្រាវ។

ឃ.២. វត្ថុបំណង

គឺជាការបង្ហាញលើចំណុចសិក្សាផ្សេងៗ ដើម្បីគាំទ្រឱ្យសម្រេចគោលបំណងខាងលើ។ ឧទាហរណ៍

- គោលបំណង រកឱ្យឃើញពីផលប៉ះពាល់ដល់ការសិក្សារបស់កុមារ។
- វត្ថុបំណង សិក្សាលើ ស្ថានភាព ជីវភាព ឱពុកម្តាយ របស់កុមារ។

ង. ចំណោទបញ្ហាការស្រាវជ្រាវ (Research Problems)

ចំណោទបញ្ហាគឺជាចំណុចនានានៃការចោទសួរជុំវិញការស្រាវជ្រាវ ទៅលើអ្នកស្រាវជ្រាវផ្ទាល់។

ឧទាហរណ៍ប្រធានបទទី១

- តើការស្រាវជ្រាវនេះបានជោគជ័យឬទេ? តើមានឧបសគ្គអ្វីខ្លះ?
- ហេតុអ្វីបានជាកុមាររៀនខ្សោយ? តើមានវិធីសាស្ត្រអាចជួយកុមារបានដែរឬទេ?

ច. លក្ខណៈសម្បត្តិនៃសំណើស្រាវជ្រាវនិងទស្សនៈវិស័យ

យើងសង្កេតឃើញថា គំរូលក្ខណៈសម្បត្តិនៃសំណើស្រាវជ្រាវនីមួយៗមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ខាងក្រោមនេះជាគំរូការអនុវត្តន៍លក្ខណៈសម្បត្តិនៃសំណើស្រាវជ្រាវដែលបានជួបប្រទះក្នុងការសរសេរសារណាកន្លងមកមានដូចខាងក្រោម៖

ច.១. លក្ខណសម្បត្តិនៃសំណើស្រាវជ្រាវ

១. មាតិកា

២. សេចក្តីថ្លែងអំណរគុណ

៣. ឧទ្ទិសកថា

៤. សេចក្តីប្រកាស

៥. សេចក្តីបញ្ជាក់

៦. ពាក្យគន្លឹះ

៧. មូលន័យសង្ខេប

៨. អារម្ភកថា

៩. សេចក្តីផ្តើម

១០. លទ្ធផល

១១. សេចក្តីសន្និដ្ឋាន

១២. សំណូមពរ

១៣. ឯកសារយោង

១៤. ឧបសម្ព័ន្ធ

ច.២.ទស្សនៈវិស័យៈគប្បីគិតថា

- តើខ្លួនជានរណា?
- ស្រាវជ្រាវអំពីអ្វី?
- រកឃើញអ្វី? - គិតឃើញយ៉ាងណា?

ជំពូក៣

វិធីសាស្ត្រសម្ភាសន៍និងការជ្រើសរើសគំរូតាង

១.អ្វីជាការសម្ភាស?

ការសិក្សាស្រាវជ្រាវមួយធម្មតា មិនអាចខ្វះការប្រមូលទិន្នន័យឬសម្ភាសន៍បានឡើយ។ ការសម្ភាសគឺមានគោលបំណងចង់ទទួលបានទិន្នន័យថ្មី និងទិន្នន័យចាស់ គឺត្រូវពឹងអាស្រ័យលើការសម្ភាស។ ការសម្ភាសជាសកម្មភាពជជែកសន្ទនាគ្នាក្នុងបរិយាកាសរីករាយដោយគោរពនិងរក្សាការសម្ងាត់ឱ្យគ្នាទៅវិញទៅមក ។ ទិន្នន័យដែលប្រមូលបានចែកចេញជាពីរគឺ៖

- ទិន្នន័យដំបូង (PrimaryData) គឺសំគាល់រាល់ទិន្នន័យដែលរកឃើញបានថ្មីបានដោយការសម្ភាសថ្មី។
- ទិន្នន័យមានស្រាប់ (Secondary Data) សំគាល់រាល់ទិន្នន័យឬឯកសារដែលមានស្រាប់។

២. ដំណាក់កាលសម្ភាសន៍ (Stages of Interview)

ក. មុនសម្ភាសន៍

មុនពេលសម្ភាសន៍ គឺជាដំណាក់កាលមួយដែលត្រូវជួបជុំបុគ្គលពាក់ព័ន្ធរួមមានដូចជា ប្រធានគម្រោង អ្នកជំនួយការ អ្នកសម្ភាសន៍ដើម្បីពិភាក្សាទៅលើរបៀបសម្ភាសន៍និងខ្លឹមសារគម្រងសំណួររួចធ្វើការសម្ភាសន៍សាកល្បងជាមុនសិន សំដៅប្រយោជន៍ក្នុងការសិក្សាលើខ្លឹមសារសំណួរថាតើអាចទទួលយកបានដែរឬទេ? ។

ខ. ពេលសម្ភាសន៍

ជាដំណាក់កាលមួយដែលត្រូវចុះសម្ភាសន៍ផ្លូវការ ដោយមានការត្រួតពិនិត្យយ៉ាងត្រឹមត្រូវពីក្រុមអ្នកជំនាញមានដូចជា ប្រធានក្រុម និងក្រុមការងារពាក់ព័ន្ធមួយចំនួនទៀត។

គ. ក្រោយសម្ភាសន៍

ជាដំណាក់កាលមួយដែលត្រូវជួបប្រជុំឡើងវិញ ជាមួយបុគ្គលជាប់ពាក់ព័ន្ធទាំងអស់ដើម្បីពិនិត្យមើលរបាយការណ៍ និងដោះស្រាយបញ្ហាផ្សេងៗដែលនៅសេសសល់។

៣. លក្ខណៈសម្បត្តិនៃអ្នកសម្ភាសន៍ (Qualification of Interviewer)

អ្នកសម្ភាសន៍ក៏ដូចជាអ្នកដែលត្រូវចុះប្រមូលទិន្នន័យដែរ គឺត្រូវមានអត្តចរិតថ្លៃថ្នូសម្ដីសមរម្យនិងពោរពេញដោយលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ពាក់កាតសំគាល់ខ្លួនពេលចុះធ្វើការងារ
- បង្ហាញអំពីអត្តសញ្ញាណរបស់ខ្លួន(មកពីក្រសួងណា? អង្គការឬ ស្ថាប័នឈ្មោះអ្វី?)
- បង្ហាញប្រាប់ពីគោលបំណងក្នុងការស្រាវជ្រាវរបស់ខ្លួន
- ប្រកាន់ខ្ជាប់នូវសីលធម៌ល្អ និងអាកប្បកិរិយាសមរម្យ

- ទំនាក់ទំនងល្អ ទឹកមុខញញឹមរួសរាយរាក់ទាក់
- គោរពសិទ្ធិឯកជនរក្សាការសម្ងាត់
- សំលៀកបំពាក់សមរម្យតាមកាលៈទេសៈ
- មិនសើចភ្លាកភ្លាយ ចំអក ឬប្រមាថពេលឮព័ត៌មានអស់សំណើចណាមួយ
- មិនបើកសម្លេងពេទ៏ ឬទទួលទូរស័ព្ទ និងអាយកូម
- ត្រូវមានអនាម័យល្អគ្រប់ពេលវេលា
- មិនភូតភរ មិនបង្កទំនាស់ជាមួយក្រុមឬជាមួយអ្នកផ្តល់ការសម្ភាស
- ត្រូវឈរលើស្មារតីសហការ
- ត្រូវស្តាប់តាមការណែនាំរបស់ប្រធានក្រុម

៤. ប្រភេទសំណួរសម្រាប់សម្ភាសន៍ (សំណួរបើក បិទ នាំមុខ និងសំណួរជជីក)

ក្នុងការស្រាវជ្រាវសរសេរសារណាមួយ ដើម្បីឱ្យស្នាដៃរបស់ខ្លួនមានគុណភាពហើយទទួលបានលទ្ធផលល្អ ស្មេរឬអ្នកស្រាវជ្រាវត្រូវតែធ្វើការចុះសម្ភាសន៍ ឬពិគ្រោះយោបល់ជាមួយអ្នកជំនាញ។ អ្នកស្រាវជ្រាវត្រូវរៀបចំសំណួរឱ្យបានគ្រប់គ្រាន់និងត្រូវតាមប្រភេទឱ្យបានច្បាស់លាស់ ។ ក្រុមអ្នកសម្ភាសន៍ត្រូវស្គាល់ឱ្យច្បាស់មួយណាជាសំណួរបើក ជាសំណួរបិទ ណាមួយជាសំណួរនាំមុខ និងសំណួរបែបណាជាប្រភេទសំណួរជជីក។ល។

ក. សំណួរបើក (Open-ended questions)

សំណួរបើកជាប្រភេទសំណួរម្យ៉ាងដែលហាក់បីដូចជា អ្នកឆ្លើយមានភាពងាយស្រួល ពីព្រោះអ្នកឆ្លើយមានចម្លើយច្រើន ឬមានជម្រើសក្នុងការឆ្លើយច្រើន។ សំណួរបើកជាប្រភេទសំណួរដែលអ្នកឆ្លើយបានឆ្លើយចេញពីគំនិត និងចេញពីការយល់ឃើញរបស់គេជាក់ស្តែងផងដែរ។ ក្នុងការសម្ភាសអ្នកសម្ភាសន៍ត្រូវត្រៀមខ្លួនជានិច្ចនៅសម្ភារៈទាំងឡាយដើម្បីកត់ត្រាទៅលើចម្លើយរបស់អ្នកឆ្លើយ។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះៗ អំពីសំណួរបើកមានដូចជាៈ

ឧទាហរណ៍

- តើអ្នកយល់យ៉ាងណាចំពោះសកម្មភាពយាយនួន ...?
- តើអ្នកយល់យ៉ាងណាចំពោះ...?
- តើការរកស៊ីរបស់គ្រួសារអ្នកយ៉ាងម៉េចដែរឆ្នាំនេះ?
- តើអ្នកយល់យ៉ាងណាចំពោះវិស័យអប់រំនៅកម្ពុជានាពេលបច្ចុប្បន្ន?
- តាមយោបល់អ្នក ដើម្បីឱ្យប្រពៃណីខ្មែរគង់វង្ស ត្រូវធ្វើដូចម្តេច?

ខ. សំណួរបិទ (Close-ended questions)

សំណួរបិទជាប្រភេទសំណួរម្យ៉ាងដែលអ្នកឆ្លើយគ្មានជម្រើសច្រើនទេ ពោលគឺអ្នកឆ្លើយមានចម្លើយតែមួយគឺ បាទ/ចាស ឬ មែន និងទេ។

ឧទាហរណ៍

- តើអ្នកមានអាយុប៉ុន្មានឆ្នាំ?
- តើផ្ទះនេះជារបស់អ្នកណា?
- តើអ្នករៀបការតាំងពីឆ្នាំណា?
- ឆ្នាំ១៩៩៣មកដល់ឆ្នាំនេះតើព្រះរាជាណាចក្រកម្ពុជាមានការបោះឆ្នោតប៉ុន្មានដង?
- តើពិធីបុណ្យចូលឆ្នាំមានប៉ុន្មានថ្ងៃ?

គ. សំណួរនាំមុខ (Leading questions)

សំណួរនាំមុខ ជាប្រភេទសំណួរម្យ៉ាងដែលមានលក្ខណៈហាក់បីដូចជានាំអ្នកឆ្លើយឱ្យផ្តល់ចម្លើយតាមអ្នកសួរ។ ខាងក្រោមនេះជាគំរូខ្លះៗនៃសំណួរនាំមុខមានដូចជា៖

- អ្នកធ្លាប់ទៅលេងអង្គរវត្តច្រើនដងហើយមែនទេ?
- តើអ្នកចូលចិត្តហូបម្ហូបខ្មែរជាង ម្ហូបចិនមែនទេ?
- បើសិនជាអ្នកមិនធ្លាប់ទៅលេងអង្គរវត្ត អ្នកពិតជាចង់ទៅលេងណាស់មែនទេ?
- សម្លរនេះឆ្ងាញ់ណាស់មែនទេ?
- តើអ្នកទៅដើរលេងនៅថ្ងៃឈប់សម្រាកស្អែកមែនទេ?

ឃ. សំណួរជជីក (Probe questions)

អ្នកសិក្សាស្រាវជ្រាវជាពិសេសអ្នកយកព័ត៌មានតែងតែប្រើសំណួរជជីក ដើម្បីឱ្យបានចម្លើយជាក់លាក់បន្ថែមទៀតពីអ្នកឆ្លើយ។ ក្នុងដំណាក់កាលប្រើប្រាស់សំណួរជជីកនេះតម្រូវឱ្យអ្នកធ្វើការសម្ភាសមានការយកចិត្តទុកដាក់ទៅលើអ្នកឆ្លើយ ឬយកចិត្តទុកដាក់ស្តាប់ទៅលើអ្នកឆ្លើយ ដើម្បីបានសួរសំណួរជជីកបន្ថែម។ ជាទូទៅគេប្រើប្រាស់សំណួរជជីក នៅពេលអ្នកឆ្លើយបាននឹងកំពុងឆ្លើយប្រាប់អ្នកពីបញ្ហាអ្វីមួយ។ នេះជាគំរូខ្លះៗនៃប្រភេទសំណួរជជីកមានដូចខាងក្រោម៖

ឧទាហរណ៍

- សូមលោក/ លោកស្រី ជួយបញ្ជាក់បន្ថែម អំពីបញ្ហា....បន្តិចទៀត?
- សូមលោក/ លោកស្រី ជួយប្រាប់ខ្ញុំឱ្យបានលម្អិតថែមទៀតអំពីបញ្ហា...?
- តើហេតុអ្វីបានជាអ្នកមានយោបល់ដូចខាងលើនេះ...?
- យោបល់របស់លោកល្អណាស់។ តើមានចំណុចអ្វីដែលប្រសើរជាងនេះទៀតទេ?

៥. គំរូតាង (Sample Size)

ក. គំរូតាងជាអ្វី?

គម្រូតាងគឺជាសំណាក ដែលអ្នកសិក្សាស្រាវជ្រាវប្រើប្រាស់ជាកម្មវត្ថុសិក្សាដើម្បីធ្វើការសិក្សាវិភាគសកល។ ជាការពិតណាស់ថាវាគ្មានការសិក្សាស្រាវជ្រាវណា ដែលមានលទ្ធផលសុក្រិតជាងការសិក្សាស្រាវជ្រាវលើគំរូតាងដែលជាទិសដៅរបស់ខ្លួននោះទេ ប៉ុន្តែការធ្វើយ៉ាងនេះបណ្តាលឱ្យអ្នកសិក្សាស្រាវជ្រាវខាតពេលវេលានិងខាតបង់ថវិកា។

ដូចនេះអ្នកស្រាវជ្រាវអាចប្រើតែសំណាក ដើម្បីធ្វើការវិភាគសម្រាប់ស្ថិតិសកលក្នុងការសិក្សារបស់ខ្លួនក៏បានដែរ ឱ្យតែការកំណត់សំណាកនោះ ពិតជាមានលក្ខណៈវិទ្យាសាស្ត្រនិងបច្ចេកទេសត្រឹមត្រូវ។

ខ. ប្រភេទនៃគំរូតាំង

ខ.១. គំរូតាងមនុស្ស ឬកម្មវត្ថុសិក្សា (Target Group)

- ភេទ
- អាយុ
- មុខរបរ
- ជាតិសាសន៍
- សាសនា
- វប្បធម៌

ខ.២. គំរូតាងទីតាំង (Target Areas)

- ថ្នាក់ជាតិ
- ថ្នាក់អន្តរជាតិ
- ថ្នាក់ខេត្ត
- ថ្នាក់ក្រុង
- ថ្នាក់ភូមិ
- តំបន់ភ្នំ
- តំបន់លិចទឹក
- តំបន់សមុទ្ទ
- តំបន់ដាច់ស្រយាល
- តំបន់អាស៊ី

៦. វិធីសាស្ត្រជ្រើសរើសសំណាក (Sampling)

ក. ដោយចៃដន្យ (Probability Random Sampling)

វិធីសាស្ត្រជ្រើសរើសគំរូតាងដោយចៃដន្យ គឺជាវិធីជ្រើសរើសសំណាកដោយផ្តល់ក្រុមទិសដៅវិធីជ្រើសរើសដូចជា៖

- សរសេរឈ្មោះដាក់ក្នុងប្រអប់រួចចាប់យក
- រាប់តាមចំនួនលេខ
- បោះគ្រាប់ឡុកឡាក់

ឧទាហរណ៍: ការសិក្សាអំពីរសជាតិផ្លែក្រូច (ជូរឬផ្អែម?)

<u>កញ្ចើក្រូច</u>

0000000
0000000
0000000
0000000

ឧទាហរណ៍: ការសិក្សាលើផលប៉ះពាល់ដល់ការសិក្សារបស់កុមារអនាថា

- ជ្រើសរើសកុមារដែលមានអាយុក្រោម១២ឆ្នាំ
- កុមារដែលរៀនថ្នាក់ទី៦
- កុមារចំនួន១០០នាក់ ស្រី៥០នាក់ និងប្រុស ៥០នាក់
- កុមារដែលនៅស្ទឹងមានជ័យ (តំបន់រើសសំរាម)

ខ. ដោយមិនចៃដន្យ (Non-Probability Random Sampling)

វិធីនេះអ្នកស្រាវជ្រាវបានប្រើប្រាស់ការជ្រើសរើសដោយងាយស្រួល ឬបានន័យថាអ្នកស្រាវជ្រាវប្រើប្រាស់ក្រុមទិសដៅសម្រាប់សិក្សា ដោយបានដឹងរួចជាស្រេចហើយទើបសម្រេចជ្រើសរើសយកមកសិក្សាទាំងអស់តែម្តង។

ឧទាហរណ៍

ការសិក្សាលើផលប៉ះពាល់ផ្លូវចិត្ត របស់ស្ត្រីដែលរងគ្រោះដោយការជួញដូរផ្លូវភេទ។

- ជ្រើសរើសក្រុមទិសដៅស្រីក្នុងមណ្ឌលណាមួយ
- ក្រុមទិសដៅទាំងស្រុង
- តំបន់ទិសដៅតែមួយ ឬពីរប៉ុណ្ណោះ

៧. ក្រមសីលធម៌ក្នុងការស្រាវជ្រាវ

ក. តើក្រមសីលធម៌ជាអ្វី?

ដើម្បីឱ្យក្រសួងអង្គការស្ថាប័ន ឬអង្គភាពមួយដំណើរការការងារបានល្អស្ថាប័ន អង្គការ អង្គភាពទាំងនោះតែងតែមាននូវក្រមសីលធម៌របស់ខ្លួន ហើយក្រមសីលធម៌នេះជាបទវិន័យសម្រាប់ស្ថាប័ន ឬអង្គការនីមួយៗអនុវត្តន៍ការងាររបស់ខ្លួន។ ដូចនេះយើងអាចនិយាយបានថា ក្រមសីលធម៌ ជាក្បួនច្បាប់វិន័យ ដែលបានតាក់តែងឡើងដោយគណៈកម្មការនៃក្រុមប្រឹក្សាភិបាល ប្រកបដោយវិទ្យាសាស្ត្រសម្រាប់ដាក់ជាបទបញ្ជាឱ្យអ្នកដែលជាប់ពាក់ព័ន្ធ គោរពនិងប្រតិបត្តិតាម។ ចំពោះបុគ្គលដែលល្មើសនឹងបទវិន័យខាងលើត្រូវប្រឈមមុខនឹង៖

- ការស្តីបន្ទោស
- ការព្រមាន
- ការពិន័យ
- ការផ្អាក
- ការបញ្ឈប់
- ការឃាត់ឬឃុំខ្លួនជាដើម។

ខ. ក្រមសីលធម៌ស្តង់ដារ

- ត្រូវប្រកាន់ខ្ជាប់នូវការប្រមូលទិន្នន័យត្រឹមត្រូវ
- មិនប្រឌិតឬលួចបន្លំ កែច្នៃទិន្នន័យ
- ការដកស្រង់ខ្លឹមសារដោយមិនបង្ហាញប្រាប់នូវឯកសារប្រភពជាអំពើមិនសមរម្យ
- ការលួចចម្លងស្នាដៃទាំងស្រុងជាកំហុសឆ្គងដ៏ធ្ងន់ធ្ងរ
- គោរពសិទ្ធិឯកជននិងរក្សាការសម្ងាត់
- ចូលរួមចំណែកក្នុងការរក្សា ការពារសុវត្ថិភាពនៃកម្មវត្ថុសិក្សាស្រាវជ្រាវ
- បញ្ឈប់ជាបន្ទាន់ បើការស្រាវជ្រាវ ប៉ះពាល់ដល់ផលប្រយោជន៍ មនុស្ស សត្វ និងរុក្ខជាតិ
- មិនភូតភរមិនបោកបញ្ឆោតឬអាចិកំបាំងនិងមិនកេងចំណេញ
- មិនប្រើលទ្ធផលនៃការសិក្សាស្រាវជ្រាវក្នុងគោលបំណងផ្សេងៗឡើយ
- ទទួលស្គាល់ជានិច្ច នូវកិច្ចសហការពីអ្នកជំនាញ
- បង្ហាញប្រាប់ពីម្ចាស់ជំនួយហិរញ្ញវត្ថុ
- ប្រកាន់ខ្ជាប់នូវគោលបំណងស្រាវជ្រាវច្បាស់លាស់
- មិនមានចេតនា បំភ័ន្ត ឬធ្វើឱ្យសាធារណជនយល់ច្រឡំ
- ផ្តើមគម្រោងស្រាវជ្រាវជាមួយនឹង ផលប្រយោជន៍មនុស្សលោកទូទៅ
- ទំនាស់ជាប្រការដែលត្រូវចៀសវាង

- សីលធម៌វិជ្ជាជីវៈជាមគ្គុទេសន៍
- មិនត្រូវចាត់ទុកថា វាជាការពិសោធដោយចៃដន្យឡើយ
- ត្រូវយល់ថាជាការពិសោធ ដោយមានគម្រោងផែនការច្បាស់លាស់ ។

ជំពូក៣
វិធីសាស្ត្រស្រាវជ្រាវ

បញ្ជាក់ប្រាប់អំពីវិធីសាស្ត្រស្រាវជ្រាវ(គុណវិស័យ បរិវិស័យ)

៣.១. កំណត់អថេរនិងសម្មតិកម្ម

៣.២. ការជ្រើសរើសទីកន្លែង (ទីកន្លែងដែលអ្នកស្រាវជ្រាវធ្វើការស្រាវជ្រាវ)

៣.៣. ការជ្រើសរើសសំណាក

.ជាការជ្រើសរើសចំនួនតំណាងចូលរួមសម្ភាសន៍ ឬចូលរួមពិសោធន៍

.ការជ្រើសរើសសំណាកមានវិធីសាស្ត្រច្រើនដូចជា (ចាប់ឆ្នោត Random, ដោយគោលបំណង Popasive, តាមបែបប្រព័ន្ធ Systematic random selection និងការសាកសួរអ្នកដែលមានបញ្ហាដូចគ្នាចេញពីអ្នកដែលយើងបានសម្ភាសន៍ Snoop)

៣.៤. ដំណើរការនៃការស្រាវជ្រាវ

គឺជាមធ្យោបាយដែលអ្នកស្រាវជ្រាវប្រើប្រាស់ក្នុងការស្រាវជ្រាវ ដើម្បីសម្រេចនៅស្នាដៃដែលខ្លួនចង់បាន។ ការស្រាវជ្រាវទាំងនោះមានដូចជា តាមបែបគុណវិស័យ និងបរិវិស័យ។

៣.៥. កម្រងសំណួរ

- បើការសិក្សាស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ ប្រភេទសំណួរស្ទើរតែ១០០%ជាប្រភេទសំណួរបិទ។
- បើការសិក្សាស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រគុណវិស័យ ប្រភេទសំណួរស្ទើរតែ១០០%ជាប្រភេទសំណួរបើក។

ចំណាំៈ ជាធម្មតាការស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវពីរយ៉ាងតិច។

ជំពូក៤
លទ្ធផលរំពឹងទុក

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ អ្នកស្រាវជ្រាវរំពឹងទុកថា មានការចូលរួមពីស្ថាប័នពាក់ព័ន្ធ ពីអ្នកផ្តល់ការសម្ភាសន៍។ល។

ជំពូក៥
ផែនការសកម្មភាពនិងផែនការថវិកា

៥.១ ផែនការសកម្មភាព (Activities Plan)

នៅក្នុងផែនការសកម្មភាព ត្រូវបង្ហាញប្រាប់ពីការចាប់ផ្តើមនិងរយៈពេលនៃការបញ្ចប់នៃការស្រាវជ្រាវទាំងមូល ខាងក្រោមនេះជាគំរូផែនការសកម្មភាព។

ល.រ	សកម្មភាព	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
១	កំណត់ប្រធានបទ	✓										
២	ជ្រើសរើសសាស្ត្រាចារ្យណែនាំ		✓									
៣	ស្វែងរកឯកសារពាក់ព័ន្ធ			✓								
៤	រៀបចំទ្រឹស្តីឱ្យត្រូវនឹងប្រធានបទ				✓							
៥	រៀបចំកម្រងសំណួរចុះស្រាវជ្រាវ					✓						
៦	សម្ភាសន៍សាកល្បង						✓					
៧	កែសម្រួលកម្រងសំណួរសោជាថ្មី							✓				
៨	សម្ភាសន៍ផ្លូវការឬប្រមូលទិន្នន័យ								✓			
៩	បញ្ចូលនិងវិភាគទិន្នន័យ									✓		
១០	បកស្រាយទិន្នន័យ										✓	
១១	រៀបចំលទ្ធផលនៃការស្រាវជ្រាវ											✓
១២	ការពារលទ្ធផល											✓

៥.២ ផែនការថវិកា(Budget Plan)

ផែនការថវិការអ្នកស្រាវជ្រាវត្រូវធ្វើតារាងបញ្ជីលម្អិត អំពីចំណាយក្នុងរយៈពេលស្រាវជ្រាវសរសេរសារណាទាំងមូល។

ល.រ	ធនធានប្រើប្រាស់	តម្លៃ១ឯកតា	ចំណាយសរុប	ផ្សេងៗ
១	សម្ភារៈ	៥០ ដុល្លា	៥០ ដុល្លា	
២	វត្ថុអនុស្សាវរីយ៍	០.៥ ដុល្លា	៦០ ដុល្លា	
៣	ប្រធានផ្នែកប្រមូលទិន្នន័យ	១០ ដុល្លា	១០០ ដុល្លា	
៤	អ្នកប្រមូលទិន្នន័យ ៥នាក់	៨ ដុល្លា	៣៦០ ដុល្លា	
៥	អ្នកបញ្ចូលទិន្នន័យ ២នាក់	៨ ដុល្លា	៤៨ ដុល្លា	
៦	អ្នកវិភាគទិន្នន័យ	១០ ដុល្លា	៣០ ដុល្លា	
	សរុប = ៦៣៨ ដុល្លា			

៥.៣ ឯកសារយោង

៥.៤ ឧបសម្ព័ន្ធ

៣. គំរូគម្រោងសម្រាប់សរសេរបាយការណ៍ស្រាវជ្រាវ និងសារណា

- ទំព័រចំណងជើង
- សេចក្តីថ្លែងអំណរគុណ
- ឧទ្ទិសកថា
- សេចក្តីប្រកាស
- សេចក្តីបញ្ជាក់
- ពាក្យគន្លឹះ
- អារម្ភកថា
- មូលន័យសង្ខេប
- មាតិកា

ជំពូកទី១
ផ្នែកសេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅចំណុចនេះត្រូវសរសេរយ៉ាងតិច១ទំព័រ យ៉ាងច្រើន២ទំព័រ) ដែលក្នុងនោះត្រូវមានចំនួនបីកថាខណ្ឌ។

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ត្រូវលើកឡើងពីភាពចាំបាច់និងលក្ខណៈអន់ថយមួយចំនួន(អសកម្ម) បន្ទាប់មកទើបចោទសួរទៅលើបញ្ហាដែលត្រូវដោះស្រាយ តែត្រូវឱ្យស៊ីគ្នាទៅនឹងប្រធានបទ។

១.៣ គោលបំណងនៃការស្រាវជ្រាវ

បង្ហាញពីការរីកចម្រើនដល់កត្តាចាំបាច់មួយចំនួន ដែលមានការទាក់ទងទៅនឹងប្រធានបទដោយផ្តោតការយកចិត្តទុកដាក់លើបញ្ហាទាំងអស់ ដែលបានចោទសួរនៅក្នុងចំណោទបញ្ហានៃការស្រាវជ្រាវ។

១.៤ សារៈសំខាន់នៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវយល់ឃើញថា ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ មានសារៈសំខាន់ ដោយពុំទាន់មានអ្នកស្រាវជ្រាវណាបានស្រាវជ្រាវស៊ីជម្រៅទៅលើប្រធានបទនេះ។

១.៥ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ដែនកំណត់នៃការសិក្សាស្រាវជ្រាវ គឺផ្តោតទៅលើពេលវេលា ឯកសារ និងកត្តាអ្វីខ្លះដែលមិនអាចទៅរួច ហើយចន្លោះពីឆ្នាំណាដល់ឆ្នាំណា? ឬនៅក្នុងឆ្នាំណាមួយ?

វិសាលភាពនៃការសិក្សាស្រាវជ្រាវ គឺនិយាយទៅលើប្រធានបទដែលលើកយកមកសិក្សា តើវាគ្របដណ្តប់ទៅលើផ្នែកណាខ្លះ? ឬកម្រិតត្រឹមណា?

ឧទាហរណ៍ ប្រសិទ្ធភាពនៃការគ្រប់គ្រងព័ត៌មានវិទ្យានៅកម្ពុជា តែដើម្បីឱ្យការសិក្សាបានគ្រប់ជ្រុងជ្រោយ វិសាលភាពគេជ្រើសរើសយកតែអង្គភាព ឬនាយកដ្ឋានជំនាញណាមួយនៅក្នុងក្រសួងណាមួយតែប៉ុណ្ណោះ)។

១.៦ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវតត្រូវចែកចេញជា៦ជំពូក ដូចមានខាងក្រោម៖

ជំពូក១សេចក្តីផ្តើម ត្រូវបង្ហាញពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង សារៈសំខាន់ដែនកំណត់និងវិសាលភាព និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូក២ រំលឹកទ្រឹស្តី

ត្រូវលើកឡើងពីទ្រឹស្តីដែលពាក់ព័ន្ធ ឬសំដីរបស់អ្នកប្រាជ្ញ និងបទពិសោធផ្សេងៗ...។

ជំពូក២ វិធីសាស្ត្រស្រាវជ្រាវ

ត្រូវបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវដែលអ្នកស្រាវជ្រាវលើកយកមកសិក្សា និងបញ្ជាក់ពីវិធីសាស្ត្រវិភាគបង្ហាញពីអត្ថប្រយោជន៍នៃប្រធានបទ និងរៀបរាប់ឱ្យបានច្បាស់លាស់អំពីប្រភេទទិន្នន័យ ព្រមទាំងរូបមន្ត ឬស្ថិតិមួយចំនួន។

ជំពូក៤ លទ្ធផលនៃការស្រាវជ្រាវ

លើកឡើងពីស្ថានភាពទូទៅរបស់អង្គភាព ប្រវត្តិអង្គភាព បេសកកម្ម ទស្សនវិស័យ គោលនយោបាយ រចនាសម្ព័ន្ធចាត់តាំង (តួនាទី ភារកិច្ច)។

ជំពូកទី៥ វិភាគលើលទ្ធផលនៃការស្រាវជ្រាវ

វិភាគលើចំណុចទាំងអស់ដែលបានអនុវត្តន៍ជាក់ស្តែង (គឺគ្រប់ចំណុចទាំងអស់ដែលមាននៅក្នុងជំពូកទី៣) គឺរកឱ្យឃើញនៅចំណុចខ្វះខាតដើម្បីធ្វើការកែលម្អ។

ជំពូកទី៦ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ដែលបានសិក្សា និងផ្តល់ជាអនុសាសន៍ទៅលើចំណុចដែលត្រូវធ្វើការកែរលម្អ។

ជំពូក២
រំលឹកទ្រឹស្តី

២.១ និយមន័យ ទ្រឹស្តីដែលមានការពាក់ព័ន្ធទៅនិងប្រធានបទ

២.២ លើកឡើងពីសម្តីរបស់អ្នកប្រាជ្ញ

២.៣ លើកឡើងពីបទពិសោធន៍ដែលអ្នកស្រាវជ្រាវបានជួបប្រទះ

ជំពូក៣

វិធីសាស្ត្រស្រាវជ្រាវ

៣.១ ប្រភេទនិងប្រភពទិន្នន័យ

៣.២ សំណាកគំរូ

៣.៣ ដំណើការជ្រើសរើសសំណាក

៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ

៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ

ជំពូក៤

លទ្ធផលនៃការស្រាវជ្រាវ

៤.១ ស្ថានភាពទូទៅ

លើកឡើងពីស្ថានភាពរបស់អង្គការ ស្ថាប័ន្ន បេសកកម្ម ទស្សនវិស័យ ។

៤.១.២ ប្រវត្តិរបស់អង្គការ

៤.១.៣ គោលនយោបាយនិងបេសកកម្ម

៤.២ ការងារគ្រប់គ្រង (លទ្ធផលការងារជាក់ស្តែងដែលអង្គភាព បាននិងកំពុងតែអនុវត្តន៍ និងបានអនុវត្តន៍ពេលកន្លងមក)។

៤.៣ ការងារបច្ចេកទេស

បកស្រាយយកបញ្ហាដែលមានការទាក់ទងទៅនិងប្រធានបទ ពិសេសអាស្រ័យទៅលើស្ថានភាពជាក់ស្តែង...។

ជំពូក៥

វិភាគលើលទ្ធផលនៃការស្រាវជ្រាវ

៥.១ វិភាគលើបញ្ហាដែលបានរកឃើញ

៥.២ វិភាគទៅលើកម្រងសំណួរ

ការវិភាគនេះត្រូវពឹងផ្អែកទាំងស្រុងទៅលើ ទៅលើទិន្នន័យណាមួយ បើមានកម្រងសំណួរត្រូវយកមកវិភាគ (កម្រងសំណួរត្រូវតែស៊ីគ្នាជាមួយប្រធានបទ)។

ជំពូក៦

សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍

៦.១ សេចក្តីសន្និដ្ឋាន

ត្រូវសន្និដ្ឋានឱ្យបានគ្រប់ជ្រុងជ្រោយទាំងចំណុចខ្លាំង ចំណុចខ្សោយ និងសរុបដោយសង្ខេប។សេចក្តីសន្និដ្ឋានយ៉ាងច្រើនបំផុតពីរទំព័រ។

៦.២ ការផ្តល់អនុសាសន៍

ត្រូវផ្តល់អនុសាសន៍ទៅលើចំណុចអវិជ្ជមាន គឺចំណុចដែលត្រូវធ្វើការកែលម្អ។

ឯកសារពិគ្រោះ:

ឧបសម្ព័ន្ធ (ត្រូវរៀបតាមលំដាប់លំដោយឱ្យបានត្រឹមត្រូវ)។

ឧបសម្ព័ន្ធ A អាចជាកម្រងសំណួរស្រាវជ្រាវ

ឧបសម្ព័ន្ធ B ឯកសារពាក់ព័ន្ធមួយចំនួនដែលយើងមិនអាចរៀបរាប់ឬបកស្រាយអស់

ឧបសម្ព័ន្ធ C ដូចជារចនាសម្ព័ន្ធ ឬតារាងផ្សេងៗ..

ឧបសម្ព័ន្ធ ...

៤. គំរូសម្រាប់សរសេររបាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់ក្រសួងអប់រំ

១. ទម្រង់នៃការសរសេររបាយការណ៍ស្រាវជ្រាវ

- ក្របទី១
- ក្របទី២
- សេចក្តីថ្លែងអំណរគុណ
- អំណះអំណាង
- មាតិកា

ជំពូក១

សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ក្នុងនោះត្រូវមានចំនួនបីកថាខណ្ឌ

កថាខណ្ឌទី១៖ ត្រូវលើកឡើងពីលក្ខណៈទូទៅនៃប្រធានបទ

កថាខណ្ឌទី២៖ ត្រូវលើកឡើងពីលក្ខណៈពិសេសនៃប្រធានបទ

កថាខណ្ឌទី៣៖ត្រូវលើកពីដំណោះស្រាយ(តើការស្រាវជ្រាវនេះចូលរួមដោះស្រាយលើបញ្ហាអ្វីខ្លះ?)

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ត្រូវលើកឡើងពីភាពចាំបាច់ និងលក្ខណៈអន់ថយមួយចំនួន(អសកម្ម) បន្ទាប់មកទើបចោទសួរ ទៅលើបញ្ហាដែលត្រូវដោះស្រាវ តែត្រូវឱ្យស៊ីគ្នាទៅនឹងប្រធានបទ។

១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងត្រូវលើកឡើងពីការស្រាវជ្រាវនេះ គឺមានបំណងឱ្យមានភាពរីកចម្រើនដល់កត្តាចាំបាច់មួយចំនួន ដែលមានការទាក់ទងទៅនឹងប្រធានបទ ដោយបានផ្តោតការយកចិត្តទុកដាក់លើបញ្ហាទាំងអស់ដែលបានចោទសួរ នៅក្នុងចំណោទបញ្ហានៃការស្រាវជ្រាវ។ ចំពោះគោលបំណងនៃការស្រាវជ្រាវ៖ គោលបំណងរួមគឺសំដៅលើប្រធានបទ រីឯគោលបំណងដោយឡែកសំដៅលើចំណោទបញ្ហាដែលបានចោទសួរ ។ បន្ទាប់មកធ្វើការវិភាគរក (ចំណុចខ្លាំងនិងចំណុចខ្សោយ..)ដើម្បីធ្វើការកែលម្អទៅលើចំណុចខ្វះខាត ព្រមទាំងធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អ(គឺចំណុចខ្សោយ)។

១.៤ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

វិសាលភាពនៃការស្រាវជ្រាវ គឺនិយាយពីប្រធានបទដែលលើកយកមកសិក្សា តើវាគ្របដណ្តប់ លើផ្នែកណាខ្លះ? ឬកម្រិតត្រឹមណា? (ឧ. ប្រសិទ្ធភាពនៃការគ្រប់គ្រងព័ត៌មានវិទ្យានៅកម្ពុជាតែដើម្បី ឱ្យការសិក្សាបានគ្រប់ជ្រុងជ្រោយ វិសាលភាពគេជ្រើសរើសយកអង្គភាពឬនាយកដ្ឋានជំនាញណាមួយនៅក្នុងក្រសួងណាមួយ?) ។

រីឯដែនកំណត់នៃការសិក្សាស្រាវជ្រាវ គឺផ្តោតទៅលើពេលវេលា ឯកសារ និងកត្តាអ្វីខ្លះដែលមិនអាចទៅរួច ហើយចន្លោះពីឆ្នាំណាដល់ឆ្នាំណា? ឬនៅក្នុងឆ្នាំណាមួយ?

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

- វិធីសាស្ត្រដែលបានយកមកប្រើប្រាស់ក្នុងការសរសេរសារណា (មានវិធីសាស្ត្របែបពិណ៌នាបែបវិភាគ បែបពន្យល់ បែបអនុមាណរួម បែបអនុមាណញែក និងបែបរុករកជាដើម ហើយនៅក្នុងការសរសេរតិចបំផុតត្រូវប្រើឱ្យបានពីរវិធីសាស្ត្រ)។
- វិធីសាស្ត្រប្រមូលទិន្នន័យៈ របៀបប្រមូលទិន្នន័យដើម្បីសរសេរមានពីរបែប គឺបែបបរិមាណនិងបែបគុណភាព។
    - ទិន្នន័យទី១ៈ (បានមកពីណាខ្លះ?)ក្នុងនោះមានការសាកសួរ ការសម្ភាសន៍ ការសង្កេត។
    - ទិន្នន័យទី២ៈ(បានមកពីណាខ្លះ?) គឺឯកសារដែលមានស្រាប់។
- វិធីសាស្ត្រវិភាគទិន្នន័យទិន្នន័យដែលប្រមូលបាន ត្រូវធ្វើការវិភាគតាមបែបគុណភាពឬបរិមាណដោយពឹងផ្អែកលើគណិតវិទ្យា និងស្ថិតិ ឬប្រូបាប៊ីលីតេ ? ហើយយកមករៀបចំនៅក្នុងម៉ាស៊ីនកុំព្យូទ័រតាម SPSS or Excel for windows ហើយរាល់ការវិភាគយើងត្រូវពឹងផ្អែកទាំងស្រុងទៅលើទិន្នន័យណាមួយ? តើទិន្នន័យទី១ ឬទិន្នន័យទី២ ឬទិន្នន័យទាំងពីរ?

១.៦ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវចែកចេញជា៥ជំពូកដូចខាងក្រោមៈ

ជំពូក១ៈ សេចក្តីផ្តើម

ត្រូវបង្ហាញពីលំនាំនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវគោលបំណងនៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្រាវជ្រាវ។

ជំពូក២៖ រំលឹកទ្រឹស្តី

ត្រូវលើកឡើងពីទ្រឹស្តីដែលពាក់ព័ន្ធ ទស្សនទាន ឬសំដីរបស់អ្នកប្រាជ្ញ និងបទពិសោធន៍ផ្សេងទៀត។

ជំពូក៣៖ លទ្ធផលនៃការសិក្សាស្រាវជ្រាវ

លើកឡើងពីស្ថានភាពទូទៅរបស់អង្គភាពដូចជាប្រវត្តិរបស់អង្គភាព បេសកកម្មទស្សនវិស័យ គោលនយោបាយ រចនាសម្ព័ន្ធចាត់តាំង (តួនាទីនិងភារកិច្ច) និងបន្ទាប់មកត្រូវលើឡើងឱ្យបានពីរ ឬបី ចំណុចទៅលើការងារបច្ចេកទេសរបស់អង្គភាព។

ជំពូក៤៖ ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយ

វិភាគទៅលើចំណុចទាំងអស់ដែលបានអនុវត្តជាក់ស្តែង (គឺគ្រប់ចំណុចទាំងអស់ដែលមាននៅក្នុងជំពូកទី៣) គឺក្នុងគោលបំណងវិភាគឱ្យឃើញនូវចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើការកែលម្អ។

ជំពូក៥៖ សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍

ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អ។

ជំពូក២
រំលឹកទ្រឹស្តី

២.១. និយមន័យនិងទ្រឹស្តីដែលមានការពាក់ព័ន្ធដល់ប្រធានបទ

២.២. លើកឡើងអំពីទស្សនទានឬសំដីរបស់អ្នកប្រាជ្ញ

២.៣. លើកឡើងពីបទពិសោធន៍

ជំពូក៣

លទ្ធផលនៃការសិក្សាស្រាវជ្រាវ

៣.១. ស្ថានភាពទូទៅរបស់.................

៣.១.១. ប្រវត្តិរបស់.........................

៣.១.២. រចនាសម្ព័ន្ធគ្រប់គ្រង(តួនាទីនិងភារកិច្ច)

៣.១.៣. គោលនយោបាយ បេសកកម្មនិងទស្សនវិស័យ

៣.២. ការងារគ្រប់គ្រង

លទ្ធផលការងារជាក់ស្តែងដែលអង្គភាពបាននិងកំពុងអនុវត្ត និងបានអនុវត្តកន្លងមក។

៣.៣. ការងារបច្ចេកទេស

លទ្ធផលការងារជាក់ស្តែងដែលអង្គភាពបាននិងកំពុងអនុវត្ត និងបានអនុវត្តក្នុងរយៈពេលកន្លងមក។

ចំណុចទាំងប៉ុន្មានដែលបានលើកឡើងនៅក្នុងជំពូលទី៣នេះ គ្រាន់តែជាឧទាហរណ៍តែប៉ុណ្ណោះ ដូច្នេះរាល់បញ្ហាដែលលើកយកមកបង្ហាញឬបកស្រាយនៅទីនេះ ត្រូវតែយកបញ្ហាណាដែលមានការទាក់ទងទៅ និងប្រធានបទនៃការស្រាវជ្រាវ ពិសេសគឺអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនិងទំហំរបស់ប្រធាន បទស្រាវជ្រាវ។

ជំពូក៤

ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយ

៤.១ វិភាគលើចំណុចខ្លាំង

ត្រូវវិភាគទៅលើចំណុចខ្លាំងទាំងប៉ុន្មាន ដែលបានលើកឡើងនៅក្នុងជំពូកទី៣

៤.២ វិភាគលើចំណុចខ្សោយ

ត្រូវវិភាគទៅលើចំណុចខ្លាំងទាំងប៉ុន្មាន ដែលបានលើកឡើងនៅក្នុងជំពូកទី៣

ជំពូក៥

សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន

ត្រូវសន្និដ្ឋានឱ្យបានគ្រប់ជ្រុងជ្រោយទាំងចំណុចខ្លាំង ចំណុចខ្សោយ និងសរុបដោយសង្ខេប (ការសន្និដ្ឋានយ៉ាងច្រើនបំផុតបីកថាខណ្ឌមិនឱ្យលើសពីពីរទំព័រ)។

៥.២ អនុសាសន៍

ត្រូវផ្តល់អនុសាសន៍ទៅលើចំណុចខ្សោយគឺចំណុចដែលត្រូវធ្វើការកែលម្អ។

.ឯកសារពិគ្រោះ

ត្រូវដាក់ឈ្មោះអ្នកនិពន្ធ ឈ្មោះសៀវភៅ ឈ្មោះទីក្រុង និងឆ្នាំបោះពុម្ព។ចំពោះអនុក្រឹត្យ ប្រកាសឬបាយការណ៍... ត្រូវដាក់ឈ្មោះដូចជារដ្ឋាភិបាល ក្រសួង នាយកដ្ឋាន បន្ទាប់មកទើបដាក់ ចំណងជើង លេខ ..និងថ្ងៃ ខែ ឆ្នាំ(មិនអនុញ្ញាតឱ្យដាក់លេខទំព័រឡើយ)។

៥.៣ ការកំណត់ទំព័រ ទំហំអក្សរ និងគ្រួបនៃសារណា(សូមមើលឧបសម្ព័ន្ធ)

៥. ការគ្រប់គ្រងគម្រោង

ដើម្បីអនុវត្តគម្រោងនិងការគ្រប់គ្រងគម្រោងឱ្យមានប្រសិទ្ធភាព ហើយមានតម្លាភាពអ្នកអនុវត្តន៍គម្រោងនិងបុគ្គលជាប់ពាក់ព័ន្ធគប្បីត្រួតពិនិត្យលើសកម្មភាពរបស់គម្រោង ផែនការរបស់គម្រោង និងផែនការថវិកាដោយធ្វើការវាយតម្លៃនិងពិនិត្យលម្អិតលើរបាយការណ៍មួយទៀតដូចជារបាយការណ៍ប្រចាំខែ បីខែ ៦ខែ ប្រចាំឆ្នាំជាដើម។

ឧទាហរណ៍

- តើឆ្លើយតបទៅនិងផែនការគម្រោងឬទេ?
- អាចបញ្ចប់គម្រោងទាន់ពេលវេលាឬទេ?
- ការអនុវត្តដោយប្រសិទ្ធភាពលើផែនការថវិកាដែរឬទេ?
- ដំណោះស្រាយបញ្ហាដោយប្រសិទ្ធភាព
- ផ្សារភ្ជាប់នូវរបាយការណ៍វិទ្យាសាស្ត្រ

ចំណែកឯការវាយតម្លៃគឺ

- ឆ្លងកាត់នូវការពិសោធ
- ត្រូវមានការពិភាក្សា
- មានកម្មវត្ថុច្បាស់លាស់

ដំណាក់កាលនៃការគ្រប់គ្រង និងការវាយតម្លៃគម្រោង

- ❖ សិក្សាលើបញ្ហា (Problems)
  - ទទួលយកបញ្ហា
  - ពិភាក្សាលើបញ្ហា
  - ដោះស្រាយបញ្ហា
- ❖ ពិនិត្យលើគោលដៅ (Goals)
  - ពិនិត្យលើគោលដៅរបស់ខ្លួនឱ្យបានច្បាស់លាស់
  - គោលដៅជាត្រីវិស័យ
- ❖ ដាក់ផែនការសកម្មភាព (Activities Plan)
  - កំណត់ផែនការសកម្មភាព
  - រៀបចំយុទ្ធសាស្ត្រក្នុងការអនុវត្តសកម្មភាព
- ❖ អនុវត្តន៍សកម្មភាព (Working)
  - អនុវត្តន៍សកម្មភាពការងារតាមគម្រោងផែនការ
  - សកម្មភាពការងារជាលទ្ធផល
- ❖ ត្រួតពិនិត្យ និងវាយតម្លៃ (Monitoring and Evaluation)

- ត្រួតពិនិត្យលើលទ្ធផលការងារ
- ធ្វើការវាយតម្លៃលើសកម្មភាពការងារ
- ការវាយតម្លៃអាចជាប្រចាំខែប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ប្រចាំ២ឆ្នាំឬប្រចាំ៣ ឆ្នាំទៅ៥ឆ្នាំជាដើម។

៦. ការវិភាគទិន្នន័យតាមកម្មវិធី SPSS

Introduction to Statistical Package for the Social Sciences (SPSS)

នៅក្នុងពិភពអ្នកស្រាវជ្រាវ គេសង្កេតឃើញមានកម្មវិធីវិភាគជាច្រើនដែលគេតែងតែយកមកធ្វើការវិភាគទិន្នន័យរបស់ខ្លួន ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវមានភាពជឿទុកចិត្ត អ្នកខ្លះវិភាគទិន្នន័យតាមកម្មវិធី SPSS14 ក្រុមអ្នកស្រាវជ្រាវខ្លះវិភាគទិន្នន័យរបស់ខ្លួនតាមកម្មវិធី SPSS16 និងមានការវិភាគតាមរបៀបផ្សេងៗទៀត។ ជាទូទៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រសង្គមអ្នកស្រាវជ្រាវតែងប្រើវិធីសាស្ត្រ SPSS16 ការស្រាវជ្រាវវិភាគតាមកម្មវិធីនេះមានច្រើនដូច ជាជំរឿនឆ្នាំ១៩៩៨ ការបោះឆ្នោតជាដើម។

ក.គោលបំណងនិងកម្មវត្ថុសិក្សា Goal and Objectives

គោលបំណង៖

យល់ដឹងពីចំណេះដឹងបឋមពីរបៀបប្រើប្រាស់ឧបករណ៍វិភាគទិន្នន័យតាម SPSS,Goal: Basic knowledge about using SPSS as a tool:

.យល់ដឹងពីចំណុចពិសេសៗរបស់កម្មវិធីវិភាគទិន្នន័យ SPSS: Understand basic SPSS features

.ចេះអនុវត្តជាមួយទិន្នន័យដែលមាននៅក្នុងកម្មវិធីSPSS:Workingwith SPSS data files: របៀបបើក, របៀបដាក់ទិន្នន័យចូលគ្នាពីក្នុង file 2ផ្សេងគ្នាcreate, open, merge, split, transform data files បង្កើតfilesSPSS, របៀបបំបែកទិន្នន័យ, និងរបៀបបំលែងទិន្នន័យ.

.ចេះពីរបៀបបំលែងអថេរនិងការបង្កើតអថេរ៖ដាក់កូដសារជាថ្មី, បូកពិន្ទុសរុប, និងរាប់ទិន្នន័យ Variable transformation and variable creation: Recode, Compute, Count, etc.

.តួនាទីសំខាន់ផ្សេងៗមួយចំនួនទៀត៖

ជ្រើសរើសករណី (cases) បែងចែកករណី cases និងថ្លឹងថ្លែងករណី cases Other important functions: Select cases, sort cases, weight cases.

ខ.យល់ដឹងពីចំណុចពិសេសៗរបស់កម្មវិធីវិភាគទិន្នន័យSPSS Understanding SPSS features

. កន្លែងទិន្នន័យ Data editor

.ផ្ទុកទិន្នន័យសម្រាប់វិភាគទិន្នន័យ stores data for analysis

. ទិន្នន័យត្រូវបានវិភាគដោយ Data are analyzed by

-ចំណុចនិងវិធីសាស្ត្រដែលត្រូវវិភាគ Point and click method

-សរសេរពាក្យលំដាប់ Syntax commands

-សរសេរកូដ Scripts

.លទ្ធផលគឺបង្ហាញនៅក្នុងកន្លែងផ្ទុកលទ្ធផល Results are displayed in the output viewer

គ.កន្លែងកែទិន្នន័យ SPSS Data Editor

.កន្លែងបង្ហាញទិន្នន័យData view

.កន្លែងទំនេរសៗក្នុងតារាងគឺសម្រាប់បញ្ចូលនិងកែរទិន្នន័យA spread sheet like method for enteringand editing data

. ជួរដេកនីមួយៗគឺសម្រាប់ករណីមួយ (case) ឬ សម្រាប់ការសង្កេតមួយEach row is for one case or for one observation

.ជួរឈរនីមួយៗបង្ហាញនូវអថេរមួយ សំណួរមួយពីការសិក្សា Each column represents 1 variableor1question from a survey

.តារាងគឺមានចំណុះសម្រាប់តម្លៃមួយៗ Cells contain individual values

.តារាងទំនេរស្មើនឹងប្រព័ន្ធដែលបានបំពេញអថេរ Blank cells = system missing for numeric variables

ឃ.កម្មវិធីSPSS Data Editor, cont.

.កន្លែងបង្ហាញនូវអថេរ Variable view:

ជួរដេក=អថេរ,ជួរឈរ=តម្លៃរបស់អថេរ តម្លៃអថេររួមបញ្ចូលដោយឈ្មោះអថេរ, ប្រភេទទិន្នន័យ(ចំនួនឬអក្សរ)ទទឹង (ចន្លោះទំហំ), កន្ទុយក្បៀស, ឈ្មោះពេញនៃអថេរ(អាចសរសេរវែងតាមការដែលចង់សរសេរ), កំណត់កូដ ឬដាក់តម្លៃឱ្យអថេរ, ភ្លេច ឬគ្មានអថេរ, ទីតាំងអថេរ (ឆ្វេង, ស្តាំ ឬកណ្តាល) និងការវាស់វែង។

Rows = variables; columns = properties of variables. Properties include variable names, data types [numeric (number) or string (text)], width,decimals, labels(longer description of variable names), values (and value labels), missing(userdefined missingvalues), columns(column width), alignmen t(leftrightcenter) and measure (measurement: scale or dinal(left, right, center) and measure (measurement: scale, ordinal, and nominal)

• ទិន្នន័យ អថេរ និងតម្លៃរបស់វាអាចបញ្ចូល ឬកែប្រែ នៅក្នុងកន្លែងដែលបង្ហាញនូវអថេរ Data, variables, and their properties can be entered or modified under "variable view screen"

ង. SPSS Syntax Window កន្លែងសរសេរកូដ

•អ្នកអាចសរសេរការបង្គាប់បញ្ជាសម្រាប់ការវិភាគទិន្នន័យ នៅក្នុងកន្លែងសរសេរកូដ You can write SPSS commands in syntax window

•អ្នកក៏អាចដាក់បញ្ចូលអ្វីពីការប្រតិបត្តិការងារ របស់អ្នកទៅក្នុងកន្លែងសរសេរកូដបានដែរ។You can paste your operation into syntax window

•You should keep and save syntax file for your record អ្នកគួរទុកនិងរក្សាទុកនូវការសរសេរកូដ សម្រាប់របាយការណ៍របស់អ្នក។

ច. កន្លែងបង្ហាញលទ្ធផល SPSS Out put Viewer

.តារាង និងក្រាហ្វិច គឺបានបង្ហាញនៅចន្លោះផ្នែកខាងស្តាំនៃកន្លែងបង្ហាញលទ្ធផល Tables and figures are shown in the right pane.

.អ្នកអាចមានការបង្គាប់បញ្ជាដែលបានបង្ហាញនៅក្នុងលទ្ធផល You can have the commands displayed in the output.

នៅផ្នែកខាងឆ្វេង គឺជាគម្រោងដែលបង្ហាញនូវមាតិកាហើយអ្នកអាចចុច(click) ទៅលើវាដើម្បីបង្ហាញលទ្ធផល The left pane is the outline pane displaying the contents. You can click on an itemto display its result.

.អ្នកអាចចំលងតារាងនិងក្រាហ្វិចហើយដាក់ចូលទៅក្នុងកន្លែងផ្សេងៗទៀត You can copy tables and graphs and paste into other applications.

.អ្នកអាចធ្វើការកែតារាង និងក្រាហ្វិច You can edit the look of a table or graph

ឆ.កន្លែងផ្ទុកឯកសារSPSS Data files

•ទិន្នន័យត្រូវតែជា SPSS data file Data must be SPSS data file, with

•You can read other data formats into SPSS, such as

អ្នកអាចដាក់ទម្រង់ផ្សេងៗនៃទិន្នន័យទៅក្នុង SPSS ដូចជា៖

-ទិន្នន័យជាតារាង Excel data files

-ទិន្នន័យជាអត្ថបទText data files

-Dbase data files

-Access data files …

•Example of reading excel data into SPSS (Class)ឧទាហរណ៍នៃការដាក់ទិន្នន័យពីក្នុង excel ទៅ SPSS

ចូលទៅក្នុង SPSS → បើកOpen → ទិន្នន័យ Data ... OrFile Read → Text Data specify data type as excel → identify the file name→ open the file and follow the instruction

ដាក់បញ្ចូលទិន្នន័យ៖ បន្ថែមអថេរ Merging Data: Adding Variables

Data files must have unique case IDs and sorted: ទិន្នន័យត្រូវតែមានចំនួន case IDs និងលេខលំដាប់ដូចគ្នាចូលSPSS→Open data: (census98_add vars 1.sav) Data Merge files add variables

-Select the data to add →(census98 add vars 2.sav) ជ្រើសរើសទិន្នន័យដែលត្រូវដាក់បញ្ចូល

-Click លើពាក្យ"match cases on key variables in sorted files,"

-Select and move ID into Key variables Box (key variables can be more than one)ជ្រើសរើសនិងប្តូរទីតាំង ID ចូលក្នុងប្រអប់ Key variables (key variables អាចលើសពីមួយ)

-Three options: ជម្រើស៣.Both files provide cases: cases from both files are added if there are different cases (non-matched IDs) •Non-activedata setiskeyed table: Only cases fromactive dataset is keyed table: Only cases from active dataset will be kept in the merged file.

•Active dataset is keyed table: Only cases from non-active dataset will be kept in the merged file

→ OK

ដាក់បញ្ចូលទិន្នន័យបន្ថែមចំនួនមនុស្ស Cases Merging Data: Adding Cases

•Variables are matched (by name and properties) អថេរត្រូវផ្គូរផ្គង (ដោយឈ្មោះ និង តម្លៃ)

•បើកSPSS → Open working data file (census98_add cases 1.sav) បើក ទិន្នន័យដែលកំពុងធ្វើការ → Data → Merge files → add cases

.ជ្រើសរើសSelect census98_add cases 2.sav as the data to be added (If the data are not open, click browse to located → Click Continue បន្ត

. បង្កើតការសម្រេចចិត្តអំពីចំនួនអថេរដែលមិនមានគូMake decisions about any unpaired variables(vars that are not the same in both files

• យកពាក្យ Addcases: exists in onlyonefile

•literate and literacy: variable names are different ឈ្មោះអថេរត្រូវតែផ្សេងគ្នា → rename → Click ចុច OK

Split file បំបែក file

•នៅពេលដែលយើងវិភាគទិន្នន័យ គឺយើងធ្វើការបំបែក fileទៅជាក្រុមតូចផ្សេងៗគ្នា។ ឧទាហរណ៍ក្រុមប្រុសនិងក្រុមស្រី។When the analysis is to perform separately for different sub groups, ex. Male versus female groups

•លទ្ធផលអាចមើលឃើញបន្ទាប់ពីវិភាគទិន្នន័យរួច The result can only be seen after running a subsequent analysis

បំលែងទិន្នន័យTransform data file

Aggregating ការផ្តុំ We can aggregate groups of cases in the working data file into single cases and creates a new, aggregated file or creates new variables in the working data file that contain aggregated data.យើងអាចផ្តុំក្រុមមនុស្សcases នៅក្នុងទិន្នន័យដែលកំពុងដំណើរការចូលទៅក្នុងcaseតែមួយហើយបង្កើតcase ថ្មី ។ ការផ្តុំ ឬបង្កើតអថេរថ្មីនៅក្នុងទិន្នន័យដែល កំពុងដំណើរការ ដែលមានចំណុះនូវទិន្នន័យដែលបានផ្តុំរួច។

Transforming variables បំលែងអថេរ: Recode ដាក់កូដថ្មី

•To regroup cases into new categories or change the existing categoriesដើម្បីបង្កើតក្រុមឡើងវិញចូលក្នុងcategories ថ្មី ឬប្តូរក្រុមcategories

•បើកSPSS → យកពាក្យTransform → យកពាក្យ Recode into different variable:

1.Select & move Ageto Numeric Var, then click Out put Var Box ជ្រើសរើសនិងប្តូរអថេរអាយុទៅក្នុងអថេរលេខ Numeric បន្ទាប់មកចុចលើប្រអប់ Output Var

2.Type Age-catin the Output Var Name, then click Change វាយពាក្យអាយុដើម្បីបញ្ជាក់ឈ្មោះនៅក្នុង Output Varបន្ទាប់មកចុចពាក្យផ្លាស់ប្តូរ

3.Click Old and New Values to regroup ageចុចពាក្យOld and New Valuesដើម្បីដាក់ក្រុមអាយុថ្មី

4.Under Old Value, type values or range of values to be regroupedនៅពីក្រោមពាក្យ old and វាយតម្លៃ លេខឬចន្លោះតម្លៃនៃអាយុដែលត្រូវបានដាក់ថ្មី។

5.Under New Values, type new values given to old values, Click Add នៅពីក្រោមពាក្យ New Values វាយតម្លៃលេខដែលយើងបានដាក់ឱ្យសម្រាប់តម្លៃលេខចាស់,បន្ទាប់មកចុចពាក្យ Add

6.Repeat 4, 5, and 6 till all old values to be regrouped are entered ធ្វើដូចគ្នាដដែលនូវចំណុចទី៤, ៥, ៦ រហូតគ្រប់តម្លៃ old values ទាំងអស់ដែលបានដាក់ក្រុមថ្មីត្រូវបានដាក់បញ្ចូល

7.Continue, then OK ចុចពាក្យបន្តបន្ទាប់មកចុចពាក្យយល់ព្រម

Transforming variables បំលែងអថេរ: Compute គិតលេខ

Used to create a new var by calculating it from existing var. ប្រើប្រាស់ដើម្បីបង្កើតអថេរថ្មីដោយការបូកបញ្ចូលគ្នាពីអថេរមានស្រាប់។

Ex. Compute YOB in census data Type YOB as new var គិតរកឆ្នាំកំណើតរបស់ប្រជាជននៅក្នុងទិន្នន័យជំរឿន១៩៩៨ ដោយវាយពាក្យ YOB ជាអថេរថ្មី

.1998 age វាយ ១៩៩៨ អាយុ Then OK ចុចពាក្យយល់ព្រម

ជំពូកទី ៥

វិធីសាស្ត្រសរសេរសារណា
HOW TO WRITE THESIS

១. ហេតុអ្វីចាំបាច់សរសេរសារណា

ការសិក្សានៅកម្រិតឧត្តមសិក្សាចាប់ពីបរិញ្ញាបត្រឡើងទៅ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានចែកចេញជាពីរគឺ ការបញ្ចប់ការសិក្សារបស់និស្សិតដោយការប្រឡងនិងការបញ្ចប់ការសិក្សារបស់និស្សិតដោយការសរសេរសារណា។ ក្នុងករណីនិស្សិតបញ្ចប់ការសិក្សាដោយសរសេរសារណា សាកលវិទ្យាល័យតម្រូវឱ្យនិស្សិតសរសេរសារណាទៅតាមជំនាញដែលខ្លួនបានសិក្សារៀងៗខ្លួន។ សម្រាប់បច្ចុប្បន្ននេះភាគច្រើននិស្សិតជ្រើសរើសការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ខ្លួនដោយការប្រឡងបញ្ចប់។ ពាក្យសារណាជាភាសាអង់គ្លេស(Thesis) និងនិក្ខេបបទជាភាសាអង់គ្លេស (Dissertation) មានន័យដូចតទៅ៖

សារណា(Thesis)គឺជាការបង្ហាញនូវការផលិតស្នាដៃរបស់និស្សិតពីការសិក្សាស្រាវជ្រាវ និងពីអ្នកជំនាញរបស់ខ្លួនសម្រាប់ជាកិត្តិយស និងជាការទទួលស្គាល់ទៅលើកម្រិតសិក្សាថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ តាមគោលការណ៍របស់គ្រឹះស្ថានបណ្ដុះបណ្ដាលការនិពន្ធសារណានេះ ជាកម្រងឯកសារស្រាវជ្រាវជាទម្រង់និងតាមគំរូជាក់លាក់ដែលកំណត់ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងក្រសួងអប់រំ យុវជន និងកីឡា។

និក្ខេបបទ (Dissertation) គឺជាការផលិតស្នាដៃចេញអំពីការស្រាវជ្រាវរបស់និស្សិតក្នុងកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬបណ្ឌិត។ និក្ខេបបទវាមានលក្ខណៈប្លែកជាងសារណាច្រើន ជាពិសេសមានភាពស៊ីជម្រៅជាងទូលំទូលាយជាង និងមានលក្ខណៈពេញលេញផ្នែកខាងវិជ្ជាជីវៈហើយបានធ្វើឱ្យបេក្ខជនបណ្ឌិតប្រព្រឹត្តកម្ម លើមុខវិជ្ជាច្បាស់លាស់ថែមទៀតផង។

២. ការកំណត់ទំហំសារណា

បេក្ខជនឬស្មេរសារណាភាគច្រើន តែងតែពិចារណាឬព្រួយទៅលើកម្រាស់នៃស្នាដៃរបស់ខ្លួន ដោយអ្នកនិពន្ធតែងតែខ្លាចស្នាដៃរបស់ខ្លួនមានចំនួនស្តើង(តិចទំព័រ)ការនិពន្ធសារណាមិនតម្រូវខំប្រឹងឱ្យតែបានច្រើនទំព័រនោះទេ ប៉ុន្តែត្រូវគិតថា តើការស្រាវជ្រាវរបស់យើងវាបានឆ្លើយតបទៅនឹងប្រធានបទ ឬទេ?ទាំងនេះ ជាចំណុចដែលសំខាន់សម្រាប់ស្មេរ សារណា និងនិក្ខេបបទ។ ជាទូទៅទំហំនៃការ និពន្ធ អាស្រ័យទៅលើការកំណត់របស់សាកលវិទ្យាល័យ ឬគ្រឹះស្ថានបណ្ដុះបណ្ដាល។ម្យ៉ាងទៀតទំហំនៃ ការនិពន្ធអាស្រ័យទៅលើខ្លឹមសារ លើប្រធាន

បទនិងជំនាញ។ ដើម្បីឱ្យមានការឯកភាពគ្នាជាមូលដ្ឋាន អ្នកនិពន្ធគួររៀបចំការនិពន្ធរបស់ខ្លួនដូចខាងក្រោម៖

- សារណាថ្នាក់បរិញ្ញាបត្រមានកម្រាស់ឬទំហំ ចាប់ពី ៦០ទៅ១០០ទំព័រ។
- សារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានកម្រាស់ ឬទំហំចាប់ពី១៥០ ទៅ ២០០ទំព័រ[5]។
- សារណាថ្នាក់បណ្ឌិតអាចមានកម្រាស់ចាប់ពី១៥០ទៅ ៣០០ទំព័រ ឬច្រើនជាងនេះ។

៣. គោលការណ៍សំខាន់ៗក្នុងការសរសេរសារណា

1. ទំហំក្រដាសអាកាត់ (A4)
2. ចោលគែមខាងឆ្វេង ១.២៥ Inch, ស្តាំ លើ និងក្រោម 0.៨0Inch
3. ដាក់លេខទំព័រនៅប៉ែកខាងក្រោមជ្រុងខាងស្តាំនៃទំព័រនីមួយៗ
4. ប្រើលេខរ៉ូម៉ាំងតូច(i.ii.iii...)សម្រាប់ដាក់លេខទំព័រដើមមុនចូលដល់សាច់អត្ថបទ
5. គម្លាតពីបន្ទាត់មួយទៅបន្ទាត់មួយ១.៥0
6. ប្រើ Tab 0.៥0 Inch
7. អត្ថបទតម្រូវឱ្យស្មើទាំងឆ្វេងទាំងស្តាំ
8. បោះពុម្ពទាំងសងខាងទំព័រ
9. ប្រើអក្សរ Khmer Os និង Khmer Muol light ១១
10. អង់គ្លេស Time New Roman ១២

ក. ការប្រើពុម្ពទំហំអក្សរខ្មែរនិងអង់គ្លេស

ក្នុងការសរសេរសារណា ឬនិពន្ធសៀវភៅជាធម្មតាស្ទេរ ឬអ្នកនិពន្ធ តែងតែប្រើប្រាស់អក្សរខ្មែរ និងអង់គ្លេសខ្លះៗខាងក្រោមនេះជាការណែនាំក្នុងការប្រើប្រាស់ពុម្ពអក្សរ និងទំហំអក្សរខ្មែរនិងអង់គ្លេសមានដូចតទៅ៖

ក.១ ការប្រើពុម្ពនិងទំហំអក្សរខ្មែរ យូនីកូដ (Khmer Unicord)

ប្រភេទ និងទំហំអក្សរ ក្នុងការសរសេរសារណាត្រូវបានកំណត់ដូចខាងក្រោម៖

- ចំណងជើងផ្នែក ឬជំពូកត្រូវប្រើ Khmer Muol Light ទំហំ១២។
- ចំណងជើងធំត្រូវប្រើ Khmer Muol Light ទំហំ១២។
- ចំណងជើងតូចត្រូវប្រើ Khmer Muol Light ទំហំ១១។

[5] ក្រសួងអប់រំ, សេចក្តីណែនាំស្តីពីការបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់.២០១១,១៧

- ខ្លឹមសារអត្ថបទត្រូវប្រើ Khmer Os ទំហំ ១១ ។
- ឯកសារយោងត្រូវប្រើ Khmer Os ទំហំ១១។

ក.២ ការប្រើពុម្ពនិងទំហំអក្សរអង់គ្លេស (**Times New Roman**)

- ចំណងជើងផ្នែក ឬជំពូកត្រូវប្រើ Times New Roman ទំហំ១៤ ។
- ចំណងជើងធំត្រូវប្រើ Times New Roman ទំហំ១២។
- ចំណងជើងតូចត្រូវប្រើ Times New Roman ទំហំ១២។
- ខ្លឹមសារអត្ថបទ ត្រូវប្រើ Times New Roman ទំហំ១២។
- ឯកសារយោងត្រូវប្រើ Times New Roman ទំហំ១២។

៤. ការចាប់ផ្តើមរៀបចំនិពន្ធសារណា

ដើម្បីរៀបចំនិពន្ធសារណាមានស្ថានភាពពីរដែលនិស្សិត ឬស្មេរត្រូវស្វែងយល់ឱ្យបានច្បាស់នោះ គឺពេលវេលារបស់និស្សិត និងពេលវេលាកំណត់ដោយសាកលវិទ្យាល័យ។ ក្នុងអំឡុងពេលនិពន្ធសារណា និស្សិតក៏ស្ថិតនៅក្នុងស្ថានភាពនៃការសិក្សាស្នាដៃផងដែរ ដែលជាហេតុធ្វើឱ្យពេលវេលាសម្រាប់ការសរសេរ និងការស្រាវជ្រាវរបស់និស្សិតតែងតែជួបនូវបញ្ហាលំបាកជាច្រើន។ រីឯម្យ៉ាងវិញទៀតការសិក្សាក៏ត្រូវបានសាកលវិទ្យាល័យជាអ្នកកំណត់ពេលវេលាយ៉ាងជាក់លាក់តាមកម្មវិធីរបស់ខ្លួនដែរ ដូចនេះហើយនិស្សិតត្រូវអនុវត្តពេលវេលាតាមគោលការណ៍របស់សាកលវិទ្យាល័យ ដើម្បីដោះស្រាយបញ្ហាទាំងពីរខាងលើនេះឱ្យទទួលបានជោគជ័យនិស្សិតត្រូវយល់ពីភាពចាំបាច់ប្រាំខាងក្រោមគឺ៖

- យល់ច្បាស់ពីអត្ថន័យ និងគោលបំណងនៃការសិក្សាស្រាវជ្រាវរបស់ខ្លួន។
- កំណត់ចំណេះដឹងឱ្យបានត្រឹមត្រូវច្បាស់លាស់សម្រាប់ការនិពន្ធអាចទទួលយកបាន។
- ធ្វើប្លង់លម្អិតនៃសកម្មភាពស្រាវជ្រាវឱ្យបានល្អ។
- មានបំណិនប្រសព្វខាងបច្ចេកទេស វិធីសាស្ត្រស្រាវជ្រាវ ដើម្បីប្រតិបត្តិឱ្យបានល្អ។
- មានសមត្ថភាពក្នុងការប្រើប្រាស់កុំព្យូទ័រ

៥. ការកំណត់ពេលវេលាស្រាវជ្រាវ

សកម្មភាពអ្វីក៏ដោយមានពេលវេលាចាប់ផ្តើម និងបញ្ចប់ នេះជាការកំណត់ពេលវេលាជាផែនការសកម្មភាពផ្ទាល់របស់អ្នកស្រាវជ្រាវ ដើម្បីធានាតាមប្លង់ការងាររបស់ខ្លួន។ ក្នុងការកំណត់ពេលវេលាស្មេរ គួរពិចារណាទៅលើគំរូនៃគម្រោងពេលវេលានិពន្ធឬជាការរៀបចំសរសេរសារណាដូចខាងក្រោម៖

ឈ្មោះនិស្សិត:........................កាលបរិច្ឆេទចាប់ផ្ដើមការស្រាវជ្រាវ.................			
ជំហាន	សកម្មភាព	ការប៉ាន់ស្មានពេលវេលា	កាលបរិច្ឆេទ
០១	ជ្រើសរើសសាស្ត្រាចារ្យណែនាំ		
០២	ដាក់ស្នើសក្ដានុពលនៃប្រធានបទជូនសាស្ត្រាចារ្យណែនាំ		
០៣	សាស្ត្រាចារ្យណែនាំយល់ព្រមនៃប្រធានបទ		
០៤	ព្រឹទ្ធបុរសមហាវិទ្យាល័យយល់ព្រមចំពោះសាស្ត្រាចារ្យណែនាំនិងប្រធានបទ		
០៥	កំណត់ជ្រើសរើសសមាជិកគណៈកម្មការវាយតម្លៃតាមដំណាក់កាលនៃសារណា (ក្រុមប្រឹក្សាមុខវិជ្ជា) យល់ព្រមតាមសំណើព្រឹទ្ធបុរសមហាវិទ្យាល័យ		
០៦	ធ្វើសេចក្ដីព្រាងនៃគម្រោងលម្អិតជូនសាស្ត្រាចារ្យណែនាំ		
០៧	គម្រោងនៃសេចក្ដីព្រាងដាក់លាក់យល់ព្រមដោយសាស្ត្រា		
០៨	បញ្ជូនគម្រោងលម្អិត ទៅគណៈកម្មការវាយតម្លៃកម្រិតមូលដ្ឋាន		
០៩	ពិធីការពារគម្រោងលម្អិតនៅចំពោះមុខគណៈកម្មការវាយតម្លៃ សារណា (Research Proposal)		
១០	យល់ព្រមឯកភាពលើគម្រោងលម្អិតដោយសាស្ត្រាចារ្យណែនាំឬក្រុមប្រឹក្សាមុខវិជ្ជា និងតម្កល់ទុកនៅមហាវិទ្យាល័យ		
១១	ការចាប់ផ្ដើមនិពន្ធសារណាសរសេរខ្លឹមសារពិស្ដានិងសកម្មភាព ស្រាវជ្រាវ (ស្រាវជ្រាវទ្រឹស្ដី ស្រាវជ្រាវរកទិន្នន័យ...)		
១២	ធ្វើរបាយការណ៍រាល់ដំណើរការអភិវឌ្ឍជូនសាស្ត្រចារ្យនិងគណៈកម្មការវាយតម្លៃទៀងទាត់		
១៣	សកម្មភាពស្រាវជ្រាវលម្អិតដូចជាចុះសម្ភាសន៍ ចុះអង្កេតដំណាក់កាលវិភាគទិន្នន័យ។ល។		
១៤	ផ្ដល់ជូនសាស្ត្រាចារ្យណែនាំពិនិត្យលើខ្លឹមសារការនិពន្ធទាំងមូល		
១៥	ថតចម្លងស្នាដៃនិពន្ធជូនគណៈកម្មការវាយតម្លៃការពារសាកល្បងកម្រិតមូលដ្ឋាន។		
១៦	ពិធីការងារសាកល្បងដោយគណៈកម្មការវាយតម្លៃកម្រិត		

	មូលដ្ឋាន		
១៧	កែលម្អរបំពេញការនិពន្ធទាំងមូល		
១៨	ផ្តល់ជូនសាស្ត្រាចារ្យណែនាំពិនិត្យជាចុងក្រោយនិងសម្រេចដើម្បីបោះពុម្ព		
១៩	ថតចម្លងស្នាដៃចំនួន១០ច្បាប់ (អាស្រ័យភាពជាក់ស្តែង) ជូនគណៈកម្មការវាយតម្លៃ		
២០	ពិធីការពារបញ្ចប់នៅចំពោះមុខគណៈកម្មការវាយតម្លៃសារណា		
២១	ការយល់ព្រមជាចុងក្រោយពីគណៈកម្មការវាយតម្លៃសម្រាប់ការបោះពុម្ពផ្សាយ		

៦. ការជ្រើសរើសសាស្ត្រាចារ្យណែនាំនិងប្រធានបទ

ក. ការជ្រើសរើសសាស្ត្រាចារ្យណែនាំ

សាស្ត្រាចារ្យណែនាំ គឺជាសាស្ត្រាចារ្យដែលមានជំនាញ ឯកទេសដែលត្រូវបានយល់ព្រមដោយព្រឹទ្ធបុរសមហាវិទ្យាល័យ ហើយត្រូវបានតែងតាំងជាផ្លូវការដោយសាកលវិទ្យាធិការ។ សាស្ត្រាចារ្យណែនាំមានការទទួលខុសត្រូវចំពោះនិស្សិត និងតាមគោលការណ៍ដែលសាកលវិទ្យាល័យបានកំណត់។ សាស្ត្រាចារ្យណែនាំជាមនុស្សដែលមានសារៈសំខាន់ណាស់ចំពោះការសិក្សាស្រាវជ្រាវរបស់និស្សិត ព្រោះសាស្ត្រាណែនាំជាមគ្គុទេសជាមនុស្សជំនិតនិងជាឧត្តមសហការីនៃការស្រាវជ្រាវជាមួយនិស្សិត។ តួនាទីរបស់សាស្ត្រាចារ្យណែនាំសារណាអាចកំណត់និយមន័យបានថា ជាអ្នកបង្ហាត់ឱ្យនិស្សិតចេះក្នុងការសិក្សាស្រាវជ្រាវដើម្បីដឹកនាំទៅរកភាពឯករាជ្យក្នុងការស្រាវជ្រាវ។ ជោគជ័យរបស់ស្មេរ និងសាស្ត្រាចារ្យណែនាំក្នុងការនិពន្ធសារណានៅត្រង់ការមានទំនាក់ទំនងល្អជាមួយស្មេរនិងសាស្ត្រាចារ្យណែនាំ។ ស្មេរត្រូវមានសេចក្តីគោរពនិងឱ្យតម្លៃយ៉ាងខ្ពស់ចំពោះសាស្ត្រាចារ្យណែនាំរបស់ខ្លួន។

ក្នុងផ្នត់គំនិតរបស់ស្មេរជាទូទៅ ស្មេរតែងនិយមទាក់ទងជាមួយ សាស្ត្រាចារ្យណាដែលមានបទពិសោធន៍យូរក្នុងការណែនាំសរសេរសារណា។ ស្មេរតែងគិតថា សាស្ត្រាចារ្យណែនាំនោះត្រូវមានចំណេះដឹងទូលំទូលាយ មានទស្សនៈវិស័យនិងការពិចារណាល្អិតល្អន់រាប់បញ្ចូលទាំងអំណាចផ្នែកឯកទេស និងអំណាចខាងការងាររដ្ឋបាលទៀតផង។ ប៉ុន្តែសាស្ត្រាចារ្យណែនាំនោះអាចនឹងមិនបានដឹកនាំ ឬណែនាំបានជិតដល់ផងដែរ ព្រោះគាត់មានភារកិច្ចមមាញឹកក្នុងការងាររដ្ឋបាលរបស់គាត់។

ខ. ការជ្រើសរើសប្រធានបទ

ការជ្រើសរើសប្រធានបទស្រាវជ្រាវ និងការជ្រើសរើសសាស្ត្រាចារ្យណែនាំវាត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ក្នុងកាលៈទេសៈខ្លះតម្រូវឱ្យស្មេរ ទទួលយកប្រធានបទសារណាមួយពីសាស្ត្រាចារ្យណែនាំឬពីមហាវិទ្យាល័យនោះតែម្តង។

ធម្មតាស្មេរត្រូវចំណាយពេលវេលាយ៉ាងច្រើនសប្តាហ៍ ក្នុងពេលជ្រើសរើសប្រធានបទស្រាវជ្រាវ។ ស្មេរសារណាត្រូវតែជ្រើសរើសប្រធានបទមួយឬពីររួចហើយពិចារណា ទៅលើដំណើរការនៃការស្រាវជ្រាវទៅលើផលប្រយោជន៍នៃប្រធានបទទាំងនោះ និងសិក្សាទៅការលំបាកដែលស្មេរនឹងអាចជួបប្រទះ។

គ. ទំនាក់ទំនងរវាងសាស្ត្រាចារ្យណែនាំជាមួយស្មេរសារណា

ជាទូទៅទំនាក់ទំនងរវាងសាស្ត្រាចារ្យណែនាំនិងស្មេរសារណា អាចបង្ហាញឡើងតាមរូបភាពជាគំរូដូចតទៅ៖

គ្រប់ស្មេរតែងតែចង់បានសាស្ត្រាចារ្យណែនាំណា ដែលមានឈ្មោះល្បីល្បាញនិងមានសមត្ថភាពមានសមានចិត្តមានភាពម៉ឺងម៉ាត់។ សាស្ត្រាចារ្យណែនាំតែងតែតាមសង្កេតមើលសកម្មភាពស្រាវជ្រាវរបស់ស្មេរជានិច្ច។ ស្មេរមានការព្រួយបារម្ភ ប្រសិនបើពុំបានជួបជាមួយសាស្ត្រាចារ្យណែនាំនិងពុំសូវ បានជួបទទួលការណែនាំឱ្យបានទៀងទាត់។ ស្មេរសារណាត្រូវការការណែនាំនិងការលើកទឹកចិត្តជាប្រចាំពីសាស្ត្រាចារ្យណែនាំ ហើយមានពេលខ្លះគេត្រូវការទាំងជំនួយសម្ភារៈទៀតផង។ តាមការសង្កេតឃើញថា ពាក្យមួយម៉ាត់របស់សាស្ត្រាចារ្យណែនាំអាចជួយដោះស្រាយបញ្ហាជាច្រើនដែលស្មេរមានក្តីកង្វល់ និងកំពុងជួបប្រទះដែលមិនអាចដោះស្រាយបាន។ ដូចនេះស្មេរត្រូវយកចិត្តទុកដាក់ឱ្យបានល្អ ចំពោះទំនាក់ទំនងជាមួយសាស្ត្រាចារ្យណែនាំជានិច្ច។ ស្មេរត្រូវបង្ហាញនូវសេចក្តីអង់អាចក្លាហាន ឧស្សាហ៍ព្យាយាមនិងការប្តេជ្ញាចិត្ត ដែលជាគុណធម៌យ៉ាងធំក្នុងការសរសេរសារណា។ គុណសម្បត្តិនេះនាំឱ្យមានការពេញចិត្តយ៉ាងខ្លាំងពីសាស្ត្រាចារ្យណែនាំ។ ស្មេរបន្ទាប់ពីទទួលបានការណែនាំផ្ទាល់ពីសាស្ត្រាចារ្យណែនាំរបស់ខ្លួន ត្រូវរកជំនួយពីក្រុមសាស្ត្រាចារ្យដទៃទៀត។ ក្នុងករណីខាងលើនេះស្មេរត្រូវមានការគោរព និងភក្តីភាពចំពោះសាស្ត្រាចារ្យណែនាំនិងសាស្ត្រាចារ្យដទៃទៀត។ម្យ៉ាងទៀត ស្មេរត្រូវសុំជួបជាមួយសាស្ត្រាចារ្យណែនាំ ទៅតាមកាលពេលវេលាដ៏សមរម្យដោយបង្ហាញឱ្យឃើញនូវការរីកចម្រើនជានិច្ចក្នុងការស្រាវជ្រាវហើយគម្រោង និងអត្ថបទត្រូវរៀបចំឱ្យបានលម្អិតច្បាស់លាស់។

ស្មេរសារណាត្រូវចងចាំថាការជួបសាស្ត្រាចារ្យ ញឹកញាប់និងពុំមានអ្វីថ្មីជាបន្តបន្ទាប់ ឬខ្លឹមសារដដែលៗ គឺជាការឥតប្រយោជន៍ និងធ្វើឱ្យសាស្ត្រាចារ្យណែនាំអស់ទឹកចិត្តផង។ ក្រៅ

អំពីទំនាក់ទំនងជាមួយសាស្ត្រាចារ្យណែនាំឬសាស្ត្រាចារ្យដទៃទៀត ស្មេរត្រូវមានទំនាក់ទំនងជាមួយរៀមច្បងនិងនិស្សិតរួមជំនាន់ផងដែរព្រោះអ្នកទាំងនេះ ក៏មានសារៈសំខាន់ខ្លាំងណាស់ដែរក្នុងការជួយដល់ការនិពន្ធសារណារបស់ស្មេរ។

ឃ. តួនាទីរបស់សាស្ត្រាចារ្យណែនាំនិងស្មេរ

ឃ.១. ភារកិច្ចរបស់សាស្ត្រាចារ្យណែនាំ

1. រៀបចំប្រជុំការដឹកនាំស្រាវជ្រាវជាមួយស្មេរតាមពេលវេលា និងទីកន្លែងសមស្របទាំងសងខាង។
2. ជួបជាមួយស្មេរ/បេក្ខជនជាមធ្យម២សប្តាហ៍ម្តង ហើយការប្រជុំម្តងៗមានរយៈពេល ពីរម៉ោង។ ចូលរួមប្រជុំការដឹកនាំស្រាវជ្រាវឱ្យបានទៀងទាត់។
3. ផ្តល់យោបល់សមរម្យក្នុងន័យស្ថាបនាដោយផ្ទាល់មាត់ និងដោយលាយលក្ខអក្សរលើគំនិតផ្តួចផ្តើមការស្រាវជ្រាវ។
4. សេចក្តីព្រាងជាបន្តបន្ទាប់នៃគម្រោងសំណើស្រាវជ្រាវ និងអត្ថបទស្រាវជ្រាវ របស់ស្មេរ/បេក្ខជន និងប្រគល់ទៅបេក្ខជនវិញយ៉ាងយូរពីរសប្តាហ៍បន្ទាប់ពីទទួលបានពីបេក្ខជន។
5. យកចិត្តទុកដាក់តម្រង់ស្មេរមិនឱ្យប្រាសចាកពីក្រមសីលធម៌ក្នុងសកម្មភាពស្រាវជ្រាវទាំងអស់
6. ពេលដែលដឹងថាជាប់រវល់ ឬមានបញ្ហាមិនអាចប្រជុំបានសាស្ត្រាចារ្យណែនាំត្រូវផ្តល់ដំណឹង ដល់បេក្ខជនឱ្យបានដឹងភ្លាម មិនឱ្យយឺតជាង២៤ម៉ោងមុនពេលប្រជុំម្តងៗ។
7. ការណែនាំស្មេរ គប្បីមានអមជាមួយនូវហេតុផលសមរម្យ។
8. សាស្ត្រាចារ្យដឹកនាំត្រូវតែផ្តល់ដំណឹងយ៉ាងតិចពីរសប្តាហ៍មុនដល់បេក្ខជន /ស្មេរស្រាវជ្រាវពេល ដែលដឹងថាខ្លួនអវត្តមានពីសាកលវិទ្យាល័យលើសពីមួយសប្តាហ៍ឡើង។
9. ប្រគល់របាយការណ៍ស្តីពីដំណើរវិវត្តន៍នៃការស្រាវជ្រាវជូនគណៈកម្មការសិក្សា /វិទ្យាសាស្ត្រនៅពេលត្រូវការ។ របាយការណ៍នេះត្រូវតែឱ្យស្មេរ បានដឹងនិងចុះហត្ថលេខាផង។
10. សាស្ត្រាចារ្យណែនាំ គប្បីរាយការណ៍អំពីការលំបាកក្នុងការដឹកនាំស្មេរស្រាវជ្រាវជូននាយក/អ្នកសម្របសម្រួលកម្មវិធីឬអនុគណៈកម្មការត្រួតពិនិត្យការស្រាវជ្រាវ ឬគណៈកម្មការស្រាវជ្រាវ ។
11. រំលឹកស្មេរ ឱ្យរក្សាទុកជានិច្ចនូវកំណត់ហេតុរាល់ការប្រជុំត្រួតពិនិត្យការស្រាវជ្រាវ។

កំណត់ហេតុ ទាំងនេះត្រូវចុះហត្ថលេខាដោយសាស្ត្រាចារ្យដឹកនាំ និងស្មេរ រួចថតចម្លងរក្សា រៀងៗខ្លួន។សូមធ្វើតាមគំរូក្នុងឧបសម្ព័ន្ធ១៣ហើយគំរូកំណត់ហេតុប្រជុំរវាងស្មេរស្រាវជ្រាវនិង សាស្ត្រាចារ្យណែនាំ។

12. ឱ្យស្មេរយកចិត្តទុកដាក់លើកាលបរិច្ឆេទផ្សេងៗដែលពាក់ព័ន្ធ លក្ខខណ្ឌនានា ការរំពឹង ទុកនិងការទទួលខុសត្រូវ និងក្រមសីលធម៌ជាដើម។

ឃ.២. ភារកិច្ចរបស់ស្មេរ

1. រៀបចំប្រជុំជាមួយសាស្ត្រាចារ្យណែនាំអំពីកិច្ចការស្រាវជ្រាវតាមពេល និងទីកន្លែងណា ដែលសមស្របទាំងសងខាង។
2. ជួបប្រជុំជាមួយសាស្ត្រាចារ្យណែនាំជាមធ្យមពីរដងក្នុងមួយខែ។ ប្រជុំម្តងៗប្រហែលពីរ ម៉ោង។
3. ចូលរួមប្រជុំឱ្យបានទៀងទាត់ជាមួយសាស្ត្រាចារ្យណែនាំ។
4. នៅពេលដែលដឹងថាខ្លួនជាប់រវល់ឬជួបបញ្ហាមិនអាចប្រជុំបាន ស្មេរ/បេក្ខជនត្រូវផ្តល់ ដំណឹង ដល់សាស្ត្រាចារ្យណែនាំឱ្យបានដឹងភ្លាម មិនឱ្យយឺតជាង២៤ម៉ោងមុនពេល ប្រជុំម្តងៗ។
5. ពេលដែលដឹងថាខ្លួនអវត្តមានពីសាកលវិទ្យាល័យឬពីប្រទេសស្មេរ/បេក្ខជនត្រូវជម្រាប សាស្ត្រាចារ្យណែនាំឱ្យបានដឹងជាងមួយសប្តាហ៍មុន។
6. ធ្វើកំណត់ហេតុរាល់ការប្រជុំជាមួយសាស្ត្រាប្យណែនាំ។ កំណត់ហេតុនេះត្រូវប្រគល់ ជូនសាស្ត្រាចារ្យណែនាំនៅពេលប្រជុំលើកក្រោយ។ បើពិនិត្យឃើញថា កំណត់ហេតុ នោះត្រឹមត្រូវសាស្ត្រាចារ្យណែនាំគប្បីដាក់ថ្ងៃខែនិងចុះហត្ថលេខា រួចប្រគល់មួយច្បាប់ ជូនស្មេរ /បេក្ខជនវិញ
7. ស្មេរ/បេក្ខជនគប្បីរាយការណ៍ជូននាយក/ អ្នកសម្របសម្រួលកម្មវិធីអំពីការលំបាកក្នុង ការទំនាក់ ទំនងការស្រាវជ្រាវជាមួយសាស្ត្រាចារ្យណែនាំ។
8. បញ្ចប់ឱ្យបានទាន់ពេលវេលានូវកិច្ចការដែលសាស្ត្រាចារ្យណែនាំដាក់ឱ្យធ្វើ។
9. ក្នុងអំឡុង៦០ថ្ងៃបន្ទាប់ពីថ្ងៃការពារសម្រេចស្មេរ /បេក្ខជនត្រូវកែតម្រូវអត្ថបទ/សារណា ទាំងនោះតាមកំណត់ហេតុពេលការពារឱ្យបានសព្វគ្រប់។ បើសិនលើសពី៦០ថ្ងៃនឹង ត្រូវធ្លាក់ពីកម្មវិធីឬត្រូវការពារសារណា/ អត្ថបទស្រាវជ្រាវរបស់ខ្លួនសាជាថ្មីបានតែម្តង គត់តាមពេលកំណត់របស់អ្នកគ្រប់គ្រងកម្មវិធី ហើយត្រូវបង់ចំណាយផ្សេងៗ សម្រាប់ ការការពារនេះផងដែរ។

10. ចំពោះករណីដែលពុំមានចែងក្នុងប្រការទាំងឡាយខាងលើនេះស្មេរ/បេក្ខជនត្រូវទទួលខុសត្រូវសព្វបែបយ៉ាងចំពោះសារណាឬអត្ថបទស្រាវជ្រាវ។

៧. ការវាយតម្លៃពេលការពារសារណា

ក. គណៈកម្មការវាយតម្លៃ

ក្នុងការវាយតម្លៃនៅពេលការពារសារណា ត្រូវមានគណៈកម្មការចំនួន៣រូប សម្រាប់វាយតម្លៃដាក់ពិន្ទុ ហើយគណៈកម្មការទាំង៣រូបត្រូវតែជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឯកភាព្យ។ គណៈកម្មការម្នាក់ៗត្រូវវាយតម្លៃទៅលើគុណភាពលើការស្រាវជ្រាវច្នេកទេសលទ្ធផលនៃការស្រាវជ្រាវឆ្លើយតបទៅនឹងប្រធានបទនិងវាយតម្លៃទៅលើអក្ខរាវិរុទ្ធផងដែរ។សាស្ត្រាចារ្យណែនាំមិនអាចជាគណៈកម្មការវាយតម្លៃរបស់ស្មេរសារណាបានឡើយ។

ខ. គោលការណ៍ក្នុងការដាក់ពិន្ទុ

គណៈកម្មការវាយតម្លៃសារណាទាំង៣រូប ត្រូវគោរពតាមគោលការណ៍ក្នុងការដាក់ពិន្ទុដូចមានតារាងខាងក្រោម៖

ពិន្ទុជាភាគរយ	ពិន្ទុជាអក្សរ	ពិន្ទុជាលេខ	និទ្ទេស
៨៥-១០០	A	៤,០០	Excellent ល្អប្រសើរ
៨០-៨៤	B+	៣,៥០	Very good ល្អណាស់
៧០-៧៩	B	៣,០០	Good ល្អ
៦៥-៦៩	C+	២,២៥	Faily good ល្អបង្គួរ
៥០-៦៤	C	២,០០	Satisfactory មធ្យម
‹៥០	F	០,០០	Fail ធ្លាក់

ពិន្ទុជាលេខ មានន័យថា ជា CGPA = Cumulative Grade Point Average = មធ្យមភាគសរុប (យកតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីសម្រេចរបស់ ACC លេខ ០៤/០៤)

៨. ការបរិយាយរចនាសម្ព័ន្ធលម្អិតសារណា

ក. ទំព័រក្របមុខ

ក្របមុខជាផ្នែកខាងមុខដែលប្រាប់ពីព័ត៌មានសំខាន់ៗ ទម្រង់ក្រប ទំហំពណ៌អាស្រ័យដោយគោលការណ៍កំណត់នៃសាកលវិទ្យាល័យឬគ្រឹះស្ថានអប់រំ ។

- អក្សរត្រូវមានលក្ខណៈងាយស្រួលអានច្បាស់ៗ

- ត្រូវប្រើក្រដាស់រឹង
- ត្រូវប្រើតួអក្សរពុម្ព
- ត្រូវមានឈ្មោះអ្នកនិពន្ធនិងឈ្មោះសាស្ត្រាចារ្យណែនាំឬដឹកនាំ

ខ. ចំណងជើងក្នុង

ទំព័រចំណងជើងក្នុងនេះដូចទំព័រក្រៅដែរតែត្រូវបន្ថែមគណៈកម្មការវាយតម្លៃ។

- គណៈកម្មការវាយតម្លៃ(សូមមើលគំរូឧបសម្ព័ន្ធ)
- សេចក្ដីអំណះអំណាងរបស់សាមីជន(សូមមើលគំរូឧបសម្ពន្ធ័)

គ. សេចក្ដីថ្លែងអំណរគុណ

ការថ្លែងអំណរគុណគួរធ្វើចំពោះអ្នកដែលបានជួយឱ្យស្នាដៃស្រាវជ្រាវឬសារណានេះសម្រេចឡើងមានដូចជា៖

- ចំពោះបុគ្គលដែលពាក់ព័ន្ធអ្នកជួយឱ្យស្នាដៃនេះសម្រេចបានជោគជ័យ។
- ស្ថាប័នដែលបានបណ្ដុះបណ្ដាល។
- អ្នកគ្រប់គ្រងបណ្ណាល័យនិងអ្នកផ្ដល់ឯកសារជាដើម។

ឃ. ការឧទ្ទិស

គឺជាការបង្ហាញអំពីមនោសញ្ចេតនាដឹងគុណរបស់អ្នកនិពន្ធ ចំពោះសាច់ញាតិបុព្វបុរសវីរជនដែលមានការពាក់ព័ន្ធនិងការស្រាវជ្រាវ អ្នកដែលបានជួយខ្លួនអ្នកប្រាជ្ញដែលបានបន្សល់ទុកឯកសារ ។

ង. មូលន័យសង្ខេប

ជាទំព័រសង្ខេបនូវខ្លឹមសារសំខាន់ៗនៃសារណា។ ទំព័រនេះអាចសរសេរជាពីរភាសាគឺភាសាជាតិនិងភាសាបរទេស។

ច. ការប្រើអក្សរកាត់

ការប្រើអក្សរកាត់ ត្រូវបង្ហាញអំពីខ្លឹមសារនៃអក្សរពេញលេញជាមុនសិនទាំងភាសាខ្មែរនិងភាសាបរទេស។

ឧទាហរណ៍

ជាភាសាខ្មែរៈ គណៈកម្មការជាតិរៀបចំការបោះឆ្នោតអក្សរកាត់ (គ.ជ.ប)។

ជាភាសាអង់គ្លេសៈ Statistical Pacckage for the Social Siences (SPSS)។

ឆ. មាតិកា

គឺជាការបរិយាយចំណងជើងខ្លឹមសារនីមួយៗ ដែលមានផ្នែក ជំពូកនិងចំណងជើងរង តូចៗនៅក្នុងស្នាដៃសារណារបស់យើង។

៩. ផ្នែកខ្លឹមសារ

ក. លំនាំដើម

គឺជាទម្រង់ដែលអ្នកស្រាវជ្រាវចង់រៀបរាប់ប្រាប់អ្នកអានអំពី:

- លក្ខណៈពិសេសនានានៃប្រធានបទ
- ការលំបាកផ្សេងៗជុំវិញការស្រាវជ្រាវ
- រំលឹកអំពីទំនាក់ទំនងរបស់អ្នកស្រាវជ្រាវការសម្រេចចិត្តជ្រើសរើសប្រធានបទ

ខ. សេចក្តីផ្តើម

សេចក្តីផ្តើមមិនត្រឹមតែជាការពិចារណា ទូទៅជុំវិញការស្រាវជ្រាវរបស់ខ្លួនប៉ុណ្ណោះទេ សេចក្តីផ្តើមថែមទាំងមានភារកិច្ចច្បាស់លាស់ដូចខាងក្រោម៖

- បង្ហាញអំពីសារសំខាន់ ឬផលប្រយោជន៍បច្ចុប្បន្នរបស់ប្រធានបទ
- បង្ហាញអំពីមូលហេតុនៃការស្រាវជ្រាវ
- បង្ហាញប្រាប់អំពីគោលបំណង វត្ថុបំណង
- បង្ហាញអំពីចំណោទបញ្ហា និងដំណោះស្រាយ
- កំណត់អំពីព្រំដែននៃការស្រាវជ្រាវ
- បង្ហាញប្រាប់អំពីអថេរ និងសម្មតិកម្មវិទ្យាសាស្ត្រ
- បង្ហាញអំពីគោលធំៗ នៃគម្រោងសារណា

គ. តួសេចក្តី

គ.១. ផ្នែកទ្រឹស្តី ផ្នែកទ្រឹស្តីរួមមានដូចជា៖

- ពន្យល់ពាក្យ
- ខ្លឹមសារទ្រឹស្តី
- ការបង្ហាញនូវស្នាដៃពាក់ព័ន្ធ

គ.២. ផ្នែកវិធីសាស្ត្រ

- បង្ហាញប្រាប់អំពីវិធីសាស្ត្រស្រាវជ្រាវ(គុណវិស័យ បរិមាណវិស័យ ...)

- បង្ហាញប្រាប់អំពីវិធីបញ្ចូល និងវិភាគទិន្នន័យ (SPSS)
- បង្ហាញប្រាប់គំរូតាងសិក្សា
- បង្ហាញប្រាប់អំពីសំណួរសម្ភាសន៍

គ.៣. ផ្នែកលទ្ធផល

បង្ហាញលទ្ធផលតាមរយៈតារាង និងក្រាហ្វិចក្នុងការវិភាគ

ឃ. សេចក្តីសន្និដ្ឋាននិងអនុសាសន៍

សេចក្តីសន្និដ្ឋាន គឺជាសេចក្តីបញ្ចប់ផ្នែកការវិភាគលើវិទ្យាសាស្ត្រទាំងឡាយដែលមានក្នុងផ្នែកតួសេចក្តី។ ក្នុងនេះអ្នកស្រាវជ្រាវបានបញ្ជាក់ផងដែរអំពីសំណូមពររបស់ខ្លួន។

ឯកសារយោង ឬឯកសារគន្ថនិទ្ទេស

- ឯកសារយោង
- ឧបសម្ព័ន្ធ

ជំពូកទី៦

ដំណាក់កាលនៃការស្រាវជ្រាវឯកសារ

Stage of Researchtation Document

ស្មេរត្រូវស្វែងយល់ថាការស្រាវជ្រាវឯកសារ គឺជាកិច្ចការដែលសំខាន់បំផុតក្នុងការនិពន្ធសារណា ឬស្នាដៃស្រាវជ្រាវផ្សេងៗ។ ដើម្បីឱ្យការស្រាវជ្រាវទទួលបានជោគជ័យស្មេរត្រូវរចេះរៀបចំឯកសារដូចតទៅៈ

១. ការរៀបចំនិពន្ធ (Preparation Writing)

ជាទូទៅក្នុងការផលិតស្នាដៃស្រាវជ្រាវថ្មី ស្មេរត្រូវប្រមូលឯកសារស្នាដៃល្បីៗក្នុងពេលកន្លងមក ដែលមានការទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវរបស់ខ្លួនឱ្យបានច្រើន។ ជាមួយគ្នានេះការនិពន្ធសារណា តម្រូវឱ្យមានការពិនិត្យពិច័យយ៉ាងហ្មត់ចត់ ទៅលើអក្ខរាវិរុទ្ធពាក្យដែលមិនច្បាស់ត្រូវចេះប្រើវចនានុក្រមសម្រាប់ផ្ទៀងផ្ទាត់ពាក្យទាំងនោះ ជៀសវាងការប្រថុយប្រថានឱ្យសោះ។ ចំពោះនៅប្រទេសកម្ពុជាយើង បច្ចុប្បន្នភាសាខ្មែរគួរប្រើតាមវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត បើសិនមានការណែនាំថ្មីទើបមានការប្រែប្រួល។ ស្មេរសារណាតែងតែគិតថា ការស្រាវជ្រាវរបស់ខ្លួនទទួលបានជោគជ័យហើយ ព្រោះបានឆ្លើយតបទៅនឹងប្រធានបទ ប៉ុន្តែស្មេរត្រូវគិតថា បើអក្ខរាវិរុទ្ធក្នុងស្នាដៃស្រាវជ្រាវរបស់ខ្លួនមានការសរសេរខុសពាក្យពេចន៍ច្រើនធ្វើឱ្យអ្នកអានបាត់បង់សេចក្ដីទុកចិត្តទៅលើអ្នកនិពន្ធ ហើយស្នាដៃរបស់អ្នកក៏នឹងចុះតម្លៃទៅតាមនោះផងដែរ។

២. ការរៀបចំឧបករណ៍បច្ចេកទេស

រាល់ការសិក្សាស្រាវជ្រាវមិនដូចគ្នាទាំងអស់ទេ ការស្រាវជ្រាវខ្លះត្រូវការប្រើសម្ភារៈចាំបាច់មួយចំនួនដូចជា ម៉ាស៊ីនថតរូប ម៉ាស៊ីនថតសម្លេងសម្ភារៈទំនើបៗសម្រាប់ការពិសោធន៍ជាដើម។ ដូច្នេះស្មេរសារណាត្រូវស្វែងយល់ថា តើប្រធានបទស្រាវជ្រាវរបស់ខ្លួនទាក់ទងទៅនឹងសម្ភារៈអ្វីខ្លះ? ក្នុងការស្រាវជ្រាវឱ្យបានលទ្ធផល ស្មេរឬអ្នកស្រាវជ្រាវត្រូវត្រិះរិះពិចារណាឱ្យបានល្អិតល្អន់ក្នុងការប្រើប្រាស់សម្ភារៈ និងឧបករណ៍បច្ចេកទេសតើសម្ភារៈណាដែលមានហើយនិងសម្ភារៈណាដែលត្រូវទិញ។

៣. ការប្រមូលឯកសារនិងការអង្កេត

ក. ការប្រមូលឯកសារ

ស្មេរត្រូវតែគិតថាការសិក្សាឯកសារ វាជាផ្នែកមួយយ៉ាងសំខាន់ក្នុងការស្រាវជ្រាវ។ ការប្រមូលឯកសារ មានគោលបំណងពិនិត្យមើលស្ថានភាពនៃប្រធានបទ។ក្នុងការស្រាវជ្រាវឯក-សារនេះអ្នកស្រាវជ្រាវត្រូវធ្វើបញ្ជីពិស្ដារតាមលំដាប់ដូចជា ឯកសារសំខាន់ ឯកសារមធ្យម និងឯកសារបន្ទាប់បន្សំ។

ខ. ការអង្កេតឯកសារ

ស្មេរគួរសិក្សាថា ការអង្កេតឯកសារជាការផ្ទៀងផ្ទាត់អត្ថបទបោះពុម្ពថ្មី ជាមួយអត្ថបទបោះពុម្ពចាស់ ឬជាមួយឯកសារដើម។ នៅពេលស្មេរអង្កេតដល់ទីកន្លែងតម្កល់ទុកឯកសារអ្នកស្រាវជ្រាវមានការខកចិត្តប្រសិនបើអត្ថបទថ្មីនោះខុសពីឯកសារដើម។ ជាទូទៅការស្រាវជ្រាវឯកសារត្រូវធ្វើមុនការអង្កេតឯកសារ។ អ្នកនិពន្ធត្រូវប្រមូលចំណេះដឹង ជាពិសេសឯកសារចាំបាច់ជាមុនសិន។ ស្មេរត្រូវអានឯកសារ និងប្រមូលឯកសារឱ្យបានច្រើនជាពិសេសឯកសារដែលជាប់ទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវរបស់ខ្លួន។

នៅពេលបច្ចុប្បន្ននេះឯកសារបោះពុម្ពផ្សាយមានច្រើន។ ស្មេរត្រូវស្គាល់កន្លែងរក្សាទុកឯកសារសំខាន់ៗ និងប្រភេទឯកសារដែលយើងអាចទៅរកបាន រកឱ្យឃើញឯកសារសំខាន់ៗដែលទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវរបស់យើង ហើយធ្វើការចម្រាញ់យកខ្លឹមសារពីឯកសារទាំងនោះ។

៤. ការកំណត់ប្រភេទឯកសារ

ក. ប្រភេទឯកសារជាអក្សរ

- ប្រភេទឯកសារមានអ្នកនិពន្ធច្បាស់លាស់
- ប្រភេទឯកសារជាព្រឹត្តិបត្រ ទស្សនាវដ្ដី និងសារព័ត៌មាន
- ប្រភេទឯកសារជារបាយការណ៍ សុន្ទរកថា ឯកសារអង្គប្រជុំ
- ប្រភេទឯកសារជាជីវប្រវត្តិ និងឯកសារគ្រួសារ។ល។

ខ. ឯកសារជារូបភាព

- ក្រាហ្វិក រូបបំព្រួញ គំនូរ តារាង
- រូបថត ផែនទី ភូមិសាស្ត្រ ផែនទីផ្លូវថ្នល់ ។ល។

គ. ឯកសារជាសម្លេង

- ខ្សែភាពយន្ត កាសែត ថាស VCD DVD Face BookTape ។ល។

៥. ការស្រាវជ្រាវតាមបណ្ណាល័យ និងមជ្ឈមណ្ឌលឯកសារ

នៅតាមបណ្ណាល័យឬមជ្ឈមណ្ឌលឯកសារ មានផ្ទុកឯកសារជាច្រើនប្រភេទទៅតាមឯកទេសនិងតាមធនធានដែលមាន។ ចំពោះការស្រាវជ្រាវឯកសារ អ្នកស្រាវជ្រាវពុំត្រូវមើលតែមួយកន្លែងឬមួយបណ្ណាល័យទេ ទោះបីជាកន្លែងនោះ ឬបណ្ណាល័យនោះមានផ្ទុកឯកសារច្រើនយ៉ាងណាក៏ដោយ។ នៅក្នុងដំណាក់កាលស្រាវជ្រាវ ជួនកាលស្មេរប្រទះឃើញឯកសារជាមូលដ្ឋានឬជាឯកសារដែលមានភាពងាយស្រួលដល់ការនិពន្ធសារណា ។ ដើម្បីគ្រប់គ្រងព័ត៌មានឱ្យបានល្អអ្នកស្រាវជ្រាវគួរត្រូវរៀបចំឯកសារដូចតទៅៈ

- ធ្វើបញ្ជីឈ្មោះបណ្ណាល័យឬមជ្ឈមណ្ឌលឯកសារ ដោយធ្វើការកត់សម្គាល់នូវអាសយដ្ឋានពេលម៉ោងធ្វើការ និងបទបញ្ជានៃការអានជាដើម។
- ធ្វើការកត់សម្គាល់ប្រភេទផ្សេងៗនៃមជ្ឈមណ្ឌលឯកសារដូចជា:
  - ០ បណ្ណាល័យដែលមានឈ្មោះល្បីជាអន្តរជាតិ
  - ០ បណ្ណាល័យថ្នាក់ជាតិដូចជាបណ្ណាល័យសម្តេច ហ៊ុន សែន បណ្ណាល័យជាតិ ។ល។

៦. យុទ្ធសាស្ត្រក្នុងការស្វែងរកឯកសារ

- ស្មេរសារណាកុំភ្លេចថាបណ្ណារក្ស និងអ្នកតម្កល់ឯកសារជាទីប្រឹក្សាដ៏មានប្រសិទ្ធភាពសម្រាប់ស្មេរ ក្នុងការស្រាវជ្រាវឯកសារ ។
- ស្មេរត្រូវមានយុទ្ធសាស្ត្រក្នុងការស្វែងរកឯកសារ និងចំណេះដឹងខាងការរកឯកសារ។
- នៅក្នុងករណីខ្លះ ស្មេរត្រូវរកឯកសារតាមប្រព័ន្ធអេឡិចត្រូនិច (Internet, web site Youtoube)

៧. ការចម្រាញ់យកខ្លឹមសារឯកសារ

ដើម្បីចម្រាញ់យកខ្លឹមសារឯកសារឱ្យបានល្អ ស្មេរត្រូវធ្វើការយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ៗ មួយចំនួនដូចជា៖

- ត្រូវរកឯកសារណាដែលចាំបាច់ក្នុងការសរសេរសារណា សម្រាប់ជួយពង្រឹងសារណារបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធិភាព។
- នៅក្នុងការស្វែងរកឯកសារស្មេរមិនគួរប្រើពេលវេលា ច្រើនហួសហេតុពេកនោះទេ។
- ករណីរកឯកសារបានហើយត្រូវបង្កើនការអានឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន

ដើម្បីងាយស្រួលអ្នកស្រាវជ្រាវត្រូវរៀបចំឯកសារទាំងឡាយតាមលំនាំដូចជា:

- ០ កត់ឈ្មោះមជ្ឈមណ្ឌលឯកសារកត់លេខកូតឯកសារ ក្រែងត្រូវការមើលម្តងទៀត។
- ០ កត់គ្រានូវខ្លឹមសារមួយចំនួន ដូចជា ដកស្រង់ឃ្លា លេខទំព័រ ជាដើម។

៨.វិធីសាស្ត្រស្រាវជ្រាវជាមួយមុខសញ្ញាមនុស្ស

ក. ប្រសិទ្ធភាពនៃការពិគ្រោះយោបល់

ធម្មតាការស្រាវជ្រាវជួយបង្រៀនយើងឱ្យមានចំណេះធ្វើនិងសុជីវធម៌។ ការជួបសន្ទនាផ្ទាល់ជាមួយសាស្ត្រាចារ្យដែលមានសមត្ថភាពពិត ឬអ្នកមានជំនាញ បានជួយលើការអភិវឌ្ឍលក្ខណ:សម្បត្តិរបស់អ្នកស្រាវជ្រាវ។ រីឯការជួបជាមួយបណ្ដាជនមានសមត្ថភាពពិសេសនៅក្នុងដែននៃការស្រាវជ្រាវរបស់អ្នក គឺជាការចាំបាច់ខ្លាំងណាស់។ ដូច្នេះស្មេរសារណាត្រូវស្គាល់មនុស្សដែលត្រូវជួបនិងស្វែងរកឱកាសឱ្យបានជួបជាចាំបាច់។មនុស្សសំខាន់ៗ ដែលបានរៀបរាប់ខាងលើនេះអាចនិយាយបានថា ជាទិន្នន័យរស់ ហើយអាចជួយស្មេរដូចតទៅ៖

- ជាឯកសារដែលមិនងាយរកបាន។
- ស្មេរនឹងដឹងឈ្មោះ និងអាសយដ្ឋានមនុស្សផ្សេងៗទៀត ដែលអ្នកត្រូវទៅជួបបន្ត។
- ស្មេរនឹងដឹងឈ្មោះស្ថាប័នដែលអ្នកត្រូវទៅជួប និងបណ្ណាល័យនានាដែលអ្នកត្រូវទៅស្រាវជ្រាវ បន្ថែមទៀត។

ចំណាំ:

មុននឹងស្មេរស្នើសុំយោបល់ ឬពិគ្រោះយោបល់ជាមួយមនុស្សសំខាន់ៗទាំងនោះ ស្មេរត្រូវប្រមូលឯកសារឱ្យបានចំនួនច្រើន និងចម្រាញ់យកខ្លឹមសារជាមុនសិន ព្រមទាំងធ្វើការឱ្យបានហ្មត់ចត់ទៅលើចំណុចនានា ដែលត្រូវពិគ្រោះយោបល់ ឬរៀបចំសំណួរមួយចំនួនដែលត្រូវពិភាក្សាបើមិនបានរៀបចំរបៀបនេះទេ ស្មេរអាចនឹងជួបនូវការមិនបានលទ្ធផលក្នុងការជួបឬទទួលនូវការបដិសេធក្នុងការផ្តល់ព័ត៌មាន។

ស្មេរត្រូវចេះធ្វើយ៉ាងណា ផ្តល់ការយកចិត្តទុកដាក់ ការគោរពនិងការឱ្យតម្លៃដល់គូរសន្ទនាកុំឱ្យគូរសន្ទនាមានអារម្មណ៍គិតថា គាត់ជាមនុស្សមានកម្រិតទន់ខ្សោយតាមការប្រៀបធៀបជាមួយអ្នកផ្សេងដែលមានសមត្ថភាពខ្ពស់ជាង។

ការជួបសន្ទនាជាមួយអ្នកមានសមត្ថភាពអាចបន្តជាលើកទីពីរ ឬទីបី ប្រសិនបើការជួបនោះនៅមានផលប្រយោជន៍។ ការជួបសន្ទនាមិនមែនចេះតែងាយស្រួលនោះទេ អ្នកត្រូវចេះស្គាល់ដោយយកចិត្តទុកដាក់ទោះបីជាគូរសន្ទនាជាមនុស្សដែលមានសម្តីច្រើន ឬជាអ្នកសម្តីតិចក៏ដោយ។

ខ. ផលប្រយោជន៍នៃការពិគ្រោះយោបល់

ការស្រាវជ្រាវតាមរយៈការពិគ្រោះយោបល់ ផ្តល់ផលប្រយោជន៍ដល់អ្នកស្រាវជ្រាវឬស្មេរសារណាមួយចំនួនដូចខាងក្រោម៖

- ការបង្កើនបរិមាណព័ត៌មាន ដែលអាចយកមកប្រើដោយផ្ទាល់ក្នុងការរៀបចំសារណា។
- ការបង្កើនទំនាក់ទំនងថ្មីជាមួយមនុស្សផ្សេងៗទៀត។
- ការទទួលបាននូវគំនិតថ្មីជួនកាលផ្ទុយនឹងគំនិតរបស់ស្មេរ ដែលជួយឱ្យស្មេរត្រូវធ្វើការផ្ទៀងផ្ទាត់ឡើងវិញ។ បទពិសោធន៍និងសមត្ថភាពរបស់បណ្ឌិតជនដែលយើងបានជួបអាចផ្តល់ផលប្រយោជន៍ដល់ការពិគ្រោះយោបល់។ ស្មេរត្រូវខិតខំរកព័ត៌មានណាដែលមានប្រយោជន៍ទាក់ទងទៅ នឹងប្រធានបទសារណារបស់ខ្លួនឱ្យបានច្រើនពីអ្នកដែលបានពិគ្រោះយោបល់។ ការសន្ទនា ឬការពិគ្រោះយោបល់ដែលរៀបចំបានល្អពិតជានាំមកនូវការត្រិះរិះពិចារណាថ្មីក្នុងការបង្កើតចំណេះដឹងរបស់ស្មេរ។

ក្រោយពីការជួបពិគ្រោះយោបល់ឬសន្ទនាម្ដងឬជាច្រើនដងស្មេរឬអ្នកស្រាវជ្រាវត្រូវសរសេរលិខិតថ្លែងអំណរគុណ ជូនទៅដល់អ្នកដែលបានផ្ដល់ការសន្ទនា និងអ្នកផ្ដល់ការពិគ្រោះយោបល់ឬអញ្ជើញគាត់ឱ្យចូលរួមនៅថ្ងៃការពារសារណា និងអាចផ្ដល់ជូនសារណាមួយច្បាប់ក្រោយពេលធ្វើការការពារចប់ប្រសិនបើមានលទ្ធភាព។

គ. ការណាត់ជួបមុខសញ្ញាស្រាវជ្រាវ

ការសុំណាត់ជួបជនមុខសញ្ញាស្រាវជ្រាវ មិនមែនចេះតែនឹកឃើញចង់ជួបតាមតែចិត្តរបស់អ្នកស្រាវជ្រាវឬស្មេរនោះទេ គឺត្រូវធ្វើការសុំជួបតាមរយៈលិខិតរដ្ឋបាលជាមុនសិន ព្រមទាំងមានគម្រោងភ្ជាប់ទៅជាមួយផង ស្មេរថែមទាំងត្រូវរៀបចំឱ្យបានល្អ ដោយមានយោបល់ពីសាស្ត្រាចារ្យជាមុនសិន បើមានការអនុញ្ញាតឱ្យចូលជួបហើយអ្នកត្រូវចេះគោរពម៉ោងពេលឱ្យបានត្រឹមត្រូវព្រមទាំងត្រូវរៀបចំខ្លួនឱ្យបានត្រឹមត្រូវនិងសមរម្យ (សម្លៀកបំពាក់ជាដើម)។

ឃ.ការកត់ត្រាមុខសញ្ញាមនុស្ស

ជាទូទៅមនុស្សដែលយើងបានជួបសន្ទនា ឬពិគ្រោះយោបល់មានមិនច្រើនប៉ុន្មានទេ តែព័ត៌មានដែលយើងបានទទួលពីបណ្ដាជនសំខាន់ៗទាំងនោះ មានច្រើន ដូចនេះស្មេរឬអ្នកស្រាវជ្រាវត្រូវកត់ត្រាព័ត៌មាន និងមុខសញ្ញារបស់បណ្ដាជនទាំងនោះឱ្យបានច្បាស់លាស់ដូចតទៅ៖

- នាមត្រកូលនាមខ្លួនរបស់បណ្ដាជនដែលយើងបានជួបសន្ទនាឬពិគ្រោះយោបល់
- មុខងារ តួនាទី និងអាសយដ្ឋាន
- កាលបរិច្ឆេទ ទីកន្លែង និងម៉ោងសន្ទនា
- ចំណុចពិសេសៗដែលស្មេរកត់ចំណាំ (គាត់រៀបរាប់ប្រាប់ស្មេរ)
- សេចក្ដីសង្ខេបនៃការសន្ទនាលើកទីមួយ លើកទីពីរជាបន្តបន្ទាប់(បើសិនជាមាន)
- នាម មុខងារ និងអាសយដ្ឋានរបស់បណ្ដាជនសំខាន់ៗដែលគាត់ប្រាប់ឱ្យជួបបន្ត

ង.កិច្ចការដែលត្រូវធ្វើបន្ត

ក្រោយពេលជួបសន្ទនាម្ដងរួចហើយ ស្មេរត្រូវពិចារណាថា តើនឹងធ្វើអ្វីទៀត ណាត់ជួបគាត់ម្ដងទៀតឬយ៉ាងណា។ ខាងក្រោមនេះជាចំណុចដែលស្មេរគួរពិចារណា៖

- នឹងសុំសេចក្ដីបញ្ជាក់លើចំណុចអ្វី ?
- នឹងជួបគាត់ម្ដងទៀតនៅពេលណា ?
- ធ្វើលិខិតថ្លែងអំណរគុណ
- អញ្ជើញឱ្យចូលរួមក្នុងពេលការពារសារណា

ជំពូក៦

ការរៀបចំខ្លឹមសារស្រាវជ្រាវ

១. ការតម្រង់ទិសការស្រាវជ្រាវ

អ្នកនិពន្ធសារណាជាធម្មតាតែងតែគិតអំពីប្រធានបទ សម្រាប់ការស្រាវជ្រាវរបស់ខ្លួន។ ស្មេរត្រូវធ្វើការពិចារណាអំពីបញ្ហាលំបាកនិងផលប្រយោជន៍សម្រាប់រយៈពេលខ្លី និងមធ្យមនៃប្រធានបទ ស្មេរត្រូវបង្ហាញដល់សាស្ត្រាចារ្យណែនាំនូវគម្រោងព្រាងនូវផលប្រយោជន៍នៃកិច្ចការស្រាវជ្រាវ ព្រមទាំងរបៀបនៃដំណើរការងាយស្រួលនិងបញ្ហាលំបាកដែលវាជាប់ពាក់ព័ន្ធទាំងផ្នែកសម្ភារៈទាំងលទ្ធភាពទៅកាន់កន្លែងស្រាវជ្រាវឬមជ្ឈមណ្ឌលឯកសារ ទាំងរបៀបនៃការប្រមូលឯកសារ និងការបន្តការសិក្សារបស់អ្នកក្នុងពេលអនាគតផងដែរ។

ការជួបពិភាក្សាជាមួយសាស្ត្រាចារ្យណែនាំ ក្នុងពេលដំបូងអាចជួយតម្រង់ទិសស្មេរឬអ្នកនិពន្ធឱ្យដើរទៅចំគោលដៅបានល្អមិនខាតបង់ពេលវេលា។ ជាទូទៅប្រធានបទមួយដែលស្មេរនឹងយកមកធ្វើការសិក្សាស្រាវជ្រាវត្រូវមានការយល់ព្រមពីសាស្ត្រាចារ្យណែនាំ និងគណៈកម្មាការជំនាញទើបអាចនិពន្ធបាន។ បើមានការយល់ព្រមហើយសូមកុំនៅបង្អង់យូរឱ្យសោះ ព្រោះកិច្ចការនេះត្រូវការពេលវេលាច្រើនណាស់សម្រាប់ការរៀបចំអត្ថបទ និងការកែសម្រួលជាច្រើនលើកច្រើនសារ។ ម្យ៉ាងទៀតក្នុងដំណើរការងារនេះស្មេរជាទូទៅតែងតែជួបប្រទះនឹងការលំបាកផ្នែកពេលវេលាថវិកាសម្ភារៈ និងបញ្ហាសុខភាពជាដើម ហើយជាពិសេសបញ្ហារៀបចំគំនិតតាមលំដាប់លំដោយនៃសារណា។ ក្នុងការរៀបចំគម្រោងនេះគឺជាគន្លឹះសំខាន់បំផុតនៃកិច្ចការស្រាវជ្រាវរបស់អ្នកនិពន្ធ និងជាកិច្ចសន្យារវាងអ្នកនិពន្ធនិងសាស្ត្រាចារ្យណែនាំជាមួយនិងគណៈកម្មការបច្ចេកទេសផងដែរ។

២. ការរៀបចំប្លង់និងសមាសធាតុសំខាន់ៗនៃគម្រោងស្រាវជ្រាវ

វាជាការពិតក្នុងដំណាក់កាលដំបូងៗ កិច្ចការមិនទាន់មានការរៀបរយល្អនៅឡើយទេ ប្រៀបដូចជាផ្លូវច្រើនដែលស្មេរទើបជួបលើកដំបូង តែក្រោយមកទើបស្មេររកឃើញផ្លូវល្អមួយដែលត្រូវដើរ។ដំណាក់កាលដំបូងនេះ ស្មេរត្រូវការពេលវេលាសមល្មមយ៉ាងតិចក្នុងរយៈពេលមួយខែដែរ។ នៅក្នុងដំណាក់កាលនេះ ស្មេរត្រូវរៀបចំឱ្យបាននូវសមាសធាតុទាំង៦នៃគម្រោងស្រាវជ្រាវរបស់ស្មេរដែលមានខ្លឹមសារដូចតទៅ៖

- ចំណងជើងបណ្ដោះអាសន្ន
- ចំណោទបញ្ហា

- ការតម្រង់ទិសនៃឯកសារគន្ថនិទ្ទេស/ឯកសារយោង
- វិធីសាស្ត្រស្រាវជ្រាវ
- ប្លង់នៃកិច្ចការបណ្ដោះអាសន្ន
- ប្រតិទិននៃដំណាក់កាលស្រាវជ្រាវ

៣. ចំណោទបញ្ហា

ចំងល់នៃការស្រាវជ្រាវទៅលើប្រធានបទណាមួយនោះ វាគឺជាចំណោទបញ្ហាដែលអ្នកស្រាវជ្រាវមានបំណងដោះស្រាយ ហើយដើម្បីដោះឱ្យបានទទួលជោគជ័យលើបញ្ហានេះអ្នកស្រាវជ្រាវត្រូវសិក្សាឱ្យបានច្បាស់លាស់ការសិក្សាស្រាវជ្រាវ ត្រូវបញ្ជាក់អំពីដែនកំណត់ព្រមទាំងកំណត់នូវប្រភេទឬទំហំនិងបញ្ហានានា ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវផលប្រយោជន៍ផ្នែកវិទ្យាសាស្ត្រ។ ស្មេរសារណាត្រូវទាញបញ្ចេញនូវបណ្ដាអត្ថន័យបង្កប់ដែលមានអំណះអំណាងបន្ថែមឱ្យបានល្អតាមដែលអាចធ្វើបាន។

នៅក្នុងដំណាក់កាលដំបូងនៃការបំផុសចំណោទបញ្ហា ស្មេរត្រូវតែចែកឱ្យដាច់ជាពីរនូវបញ្ហាសំខាន់និងបញ្ហាបន្ទាប់បន្សំ។ បញ្ហាសំខាន់នោះដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកស្ថិតនៅជុំវិញបញ្ហាស្នូលមួយដែលជាឆ្អឹងខ្នងនៃការស្រាវជ្រាវរបស់ស្មេរ។

៤. ការតម្រង់ទិសឯកសារ

ការស្រាវជ្រាវរកឯកសារជាការសំខាន់ណាស់ក្នុងការសរសេរសារណា ព្រោះវាបាននាំមកនូវព័ត៌មានយ៉ាងសំខាន់សម្រាប់អ្នកស្រាវជ្រាវ។ មានស្ថានភាពពីរអាចលេចឡើងក្នុងពេលស្រាវជ្រាវគឺៈ

ក. ស្រាវជ្រាវរកឃើញឯកសារពាក់ព័ន្ធច្រើន

ស្មេរអាចរកឃើញកស្តុតាងច្បាស់លាស់ច្រើន ដែលមានរួចស្រេចទៅហើយនិងមានលក្ខណៈទូលំទូលាយថែមទាំងត្រឹមត្រូវទៀតផង។ ករណីនេះប្រធានបទរបស់យើងអាចនឹងត្រូវបោះបង់ចោល ព្រោះបើមិនដូច្នេះទេ អាចមានន័យថាជាការនិពន្ធជាន់គ្នា ។

អ្នកនិពន្ធបានរៀបចំឯកសារទាំងនោះតាមលំដាប់លំដោយ សម្រាប់ធ្វើការវិភាគនិងបង្ហាញទៅតាមលក្ខណៈប្រាកដនិយម ហើយសម្លឹងទៅរកការបកស្រាយមួយថ្មីសន្លាង។

ខ. ស្រាវជ្រាវរកឃើញឯកសារពាក់ព័ន្ធតិច

ក្នុងករណីនេះអ្នកស្រាវជ្រាវសារណា ត្រូវតែខិតខំសិក្សាទៅលើឯកសារដែលមានទាំងនោះមុននឹងប្រមូលទិន្នន័យផ្សេងៗទៀតតាមរយៈការស្រាវជ្រាវរបស់ស្មេរ។ ស្មេរត្រូវតម្រង់ទិសឯកសារគន្ថនិទ្ទេស ធ្វើការខំប្រឹងប្រមូលឱ្យអស់ពីលទ្ធភាពនូវឯកសារសំខាន់ៗនិងបន្ទាប់

បន្សំ និងរៀបចំទៅតាមក្បួនខ្នាតនៃការស្រាវជ្រាវ។ នៅក្នុងពេលនេះដែរស្មេរត្រូវទៅកាន់មជ្ឈមណ្ឌលឯកសារនានាស្ថាប័នផ្សេងៗ និងបណ្ណាជនដែលមានសមត្ថភាព។

៥. វិធីស្រាវជ្រាវ

នៅក្នុងវិធីស្រាវជ្រាវ ស្មេរត្រូវតែគិតទុកជាមុននូវបច្ចេកទេស និងវិធីសាស្ត្រស្រាវជ្រាវដែលស្មេរប្រើវាអាចខុសគ្នារវាងមុខវិជ្ជាមួយ ទៅមុខវិជ្ជាមួយទៀត និងពីប្រធានបទមួយទៅប្រធានបទមួយទៀត។

ស្មេរសារណា ជាអ្នកពូកែស្រាវជ្រាវនិងបង្កើតបច្ចេកទេសថ្មីៗជាដំបូងស្មេរគេអាចយកទៅពិសោធន៍ត្រឹមកម្រិតដំបូងសិន (Pilot test) ដើម្បីពិនិត្យមើលប្រសិទ្ធិភាពមុននឹងយកទៅប្រើប្រាស់ជាទម្រង់ពេញលេញ។

វិធីសាស្ត្រស្រាវជ្រាវ មិនមែនគ្រាន់តែជាការរៀបរាប់អំពីបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែត្រូវបញ្ជាក់អំពីលំដាប់ឬឋានានុក្រម(Order)កម្មវត្ថុ(Object) គោលដៅ (Goal)និងលក្ខខ័ណ្ឌជាក់ស្តែងដើម្បីធ្វើឱ្យសម្រេចមានដូចជា:ទីកន្លែងពេលវេលា មនុស្ស និងស្ថាប័នដែលទាក់ទងមធ្យោបាយនិងសម្ភារ:ដែលប្រើប្រាស់ជាដើម។

៦. ចំណងជើងបណ្តោះអាសន្ន

គម្រោងក្នុងការសិក្សាស្រាវជ្រាវ ត្រូវដាក់ចំណងជើងបណ្តោះអាសន្នមួយសិនសម្រាប់កំណត់កម្មវត្ថុនិងទិសដៅទូទៅក្នុងការស្រាវជ្រាវសារណា ចំណងជើងបណ្តោះអាសន្នវាអាចរក្សាឬក៏ប្តូរតាមការយល់ឃើញរបស់ស្មេរនិងសាស្ត្រាចារ្យណែនាំ។

៧. រចនាសម្ព័ន្ធទូទៅនៃសារណា

គឺជាផ្នែកនៃការនិពន្ធសារណាឬនិក្ខេបបទ ដែលមានលក្ខណ:ពេញលេញក្រោយពីអ្នកស្រាវជ្រាវបានរៀបចំនិងធ្វើបទបង្ហាញ ការពារគម្រោងប្លង់លម្អិតរបស់ខ្លួនដោយជោគជ័យរួចមក។ ក្នុងការនិពន្ធសារណា ឬនិក្ខេបបទ អ្នកស្រាវជ្រាវគប្បីអនុវត្តតាមទម្រង់ដូចខាងក្រោម៖

ក. ទំព័រចាប់ផ្តើម

ទំព័រចាប់ផ្តើម គឺជាទំព័រសំដៅទៅរកអត្ថបទស្រាវជ្រាវដែលគេពុំទាន់រាប់ចូលនូវចំនួនទំព័រខ្លឹមសារនោះទេ។ ទំព័រចាប់ផ្តើមរួមមាន៖

ក.១- ក្របមុខ

ក.២- ទំព័រចំណងជើងក្នុង

ក.៣- គណ:កម្មការវាយតម្លៃ

ក.៤- ទំព័រអំណ:អំណាងរបស់សាមីជន

ក.៥- ការថ្លែងអំណរគុណ

ក.៦- ការឧទ្ទិសស្នាដៃ

ក.៧- ទំព័រអក្សរកាត់ និងពាក្យបច្ចេកទេស

ក.៨- មាតិកា

ចំណាំ: ចាប់ពីចំណុច ក៥ ដល់ក៨ ត្រូវសរសេរលេខទំព័រជាអក្សរ រ៉ូម៉ាំង។ ទំព័រនៃសារណាឬ និក្ខេបបទត្រូវរាប់លេខរៀងទី១ នៃទំព័រ ចាប់ពីលំនាំដើមរហូតដល់ទំព័រឯកសារគន្ថនិទ្ទេស ។ ចំពោះ ឧបសម្ព័ន្ធការពន្យល់ពាក្យនិងតារាងរូបភាពត្រូវចុះលេខរៀងតាមលំដាប់របស់ខ្លួនៗ។

ខ.ទំព័រខ្លឹមសារសារណា

គឺជាផ្នែកនៃសារណាទាំងស្រុង អំពីស្នាដៃហើយផ្នែកនេះជាផ្នែកដ៏រឹងមាំនៃគ្រោងឆ្អឹងខ្នងសារណា។ ចំណុចសំខាន់ទាំងនោះរួមមាន:

ខ.១- លំនាំដើម

ខ.២- សេចក្តីផ្តើម

ខ.៣- តួសេចក្តី

ខ.៤- សេចក្តីសន្និដ្ឋាននិងអនុសាសន៍

គ. ទំព័រឯកសារយោង

ក្នុងផ្នែកនេះរួមមាន:

គ.១- ឯកសារយោង ឬឯកសារគន្ថនិទ្ទេស

គ.២- ឧបសម្ព័ន្ធ

ឃ. តារាងរូបភាពលម្អ

ជំពូក ៨

វិធីសាស្ត្រក្នុងការផ្តល់ឯកសារប្រភព

នៅក្នុងពិភពអ្នកសិក្សាស្រាវជ្រាវ អ្នកនិពន្ធ និងអ្នកសរសេរអត្ថបទផ្សេងៗ ការផ្តល់ឯកសារប្រភពឬឯកសារដើមនេះមានសារៈសំខាន់ណាស់។ ការផ្តល់ឯកសារប្រភពបានធ្វើឱ្យអ្នកអានមានភាពទុកចិត្តទៅលើស្នាដៃរបស់ខ្លួនថែមទៀតផង។ ស្មេរសារណាត្រូវស្វែងយល់ឱ្យបានច្បាស់ពីរបៀបសរសេរឯកសារប្រភព។ ស្មេរសារណាគួរដឹងថា មានរបៀបសរសេរជាច្រើននៅក្នុងពិភពសិក្សា គឺវាអាស្រ័យទៅតាមតម្រូវការរបស់សាកលវិទ្យាល័យ ឬគ្រឹះស្ថានសិក្សាតម្រូវឱ្យ។ របៀបសរសេរធំៗមានដូចជា៖ របៀបជីការហ្គោ (Chicago Style) របៀបសមាគមចិត្តវិទ្យាអាមេរិកាំង (APA Style: American Psychological Association Style) របៀបសមាគមភាសាទំនើប (MLA Style: Modern Language Association Style) និងរបៀបសៀវភៅខៀវ(Bluebook Style)ជាដើម។ការសរសេរយោងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញតម្រូវឱ្យ មានការយកតាមរបៀបសមាគមចិត្តវិទ្យាអាមេរិកកាំង (APA Style: Publication Manual of the American Psychological Association Style)(ម៉ែន សារ៉ាវុធ, ២០០៨, ២០)។

១. អ្វីជាឯកសារប្រភព?

ឯកសារប្រភពគឺជាទិន្នន័យដែលអ្នកស្រាវជ្រាវ ដកស្រង់ដើម្បីធ្វើការអះអាងគាំទ្រលើស្នាដៃរបស់ខ្លួនឱ្យមានលក្ខណៈរឹងមាំនិងធ្វើឱ្យស្នាដៃនេះរិតតែមានលក្ខណៈវិទ្យាសាស្ត្រ។ រីឯឯកសារប្រភពគឺជាអាយុជីវិតក្នុងការស្រាវជ្រាវទាំមូល។ ស្នាដៃស្រាវជ្រាវដែលប្រើប្រាស់ឯកសារប្រភពកាន់តែច្រើនគឺរិតតែមានតម្លៃ និងរិតតែមានការចាប់អារម្មណ៍។អ្នកស្រាវជ្រាវជាអ្នកអានដ៏ប៉ិនប្រសប់ និងពូកែច្បិចខ្លឹមសារសំខាន់ៗយកមកបំពេញការស្រាវជ្រាវរបស់ខ្លួន។

២. ប្រភេទនៃឯកសារប្រភពឬឯកសារយោង

ដើម្បីឱ្យស្នាដៃការសិក្សាស្រាវជ្រាវមានលក្ខណៈរឹងមាំ គេបានបែងចែកឯកសារប្រភពជាពីរគឺ៖

ក. ឯកសារបច្ចេកទេស

- អ៊ីនធឺណែត,អ៊ីម៉ែល - ប្រាសាទបុរាណ - ប្រព័ន្ធកុំព្យូទ័រ - វត្ថុបុរាណ - ស៊ីឌីរ៉ូម
- ទីតាំងភូមិសាស្ត្រ - ភាពយន្ត វីដេអូ - ឆ្អឹង ឈាម - ទូរទស្សន៍ - វិទ្យុ
- កំណាយ - សិលាចារឹក - ប្រសាសន៍ថ្នាក់ដឹកនាំ
- សំដីព្រឹទ្ធាចារ្យ - សាស្ត្រាស្លឹករឹត។ល។

ខ. ឯកសារសំណេរ

- សៀវភៅចាស់ៗ - ទស្សនាវដ្តី - អត្ថបទស្រាវជ្រាវ - កាសែត

- ស្នាដៃចាស់ៗ - លិខិតស្នាមផ្សេងៗ - ព្រឹត្តិបត្រ។ល។

ចំពោះការយោងនូវខ្លឹមសារទាំងស្រុង ឧទាហរណ៍ដូចជាសម្តីអ្នកប្រាជ្ញប្រសាសន៍អ្នកដឹកនាំដែលមានលក្ខណៈល្អពន់ពេក ហើយដែលធ្វើឱ្យយើងអ្នកស្រាវជ្រាវជំនាន់ក្រោយមិនអាចកែពាក្យពេចន៍បាន។ ការយោងបែបនេះអ្នកស្រាវជ្រាវត្រូវចូលពាក់កណ្តាលទំព័រសរសេរដាក់ក្នុងប្រអប់ប្តូរទំហំអក្សរឱ្យតូចជាងមុន និងប្តូរម៉ូតអក្សរជាដើម។ សូមពិនិត្យមើលឧទាហរណ៍ខាងក្រោម៖

ឧទាហរណ៍

នៅប្រទេសកម្ពុជាមានប្រជាពលរដ្ឋប្រមាណ១៤លាននាក់។ កស្រាវជ្រាវបានរកឃើញ

នៅប្រទេសកម្ពុជាមានប្រជាពលរដ្ឋប្រមាណ១៤លាននាក់។អ្នកស្រាវជ្រាវបានរកឃើញនៅប្រទេសកម្ពុជាមានប្រជាពលរដ្ឋប្រមាណ១៤លាននាក់។ អ្នកស្រាវជ្រាវបានរកឃើញ «ខាងលើនេះជាអត្ថបទធម្មតា»

លោកព្រឹទ្ធាចារ្យ ឆេង ផុន បានឱ្យដឹងកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ថា វិស័យវប្បធម៌ សិល្បៈនៅប្រទេសកម្ពុជា នឹងមានភាពល្អឡើងវិញ..។

គ. ចំណាត់ថ្នាក់នៃឯកសារប្រភព (ឯកសាររាក់ៗ, ឯកសារជ្រៅជ្រះ, ឯកសារតំកល់)

គ.១ ឯកសាររាក់ៗ

គឺជាឯកសារដែលមិនទាន់បានឆ្លងកាត់ការត្រួតពិនិត្យត្រឹមត្រូវ ពីគណៈកម្មការជំនាញ ឬជាឯកសារដែលមិនទាន់បានបោះពុម្ពផ្សាយ ជាផ្លូវការនៅឡើយ។

គ.២ ឯកសារជ្រៅជ្រះ

គឺជាឯកសារដែលបានឆ្លងកាត់ការត្រួតពិនិត្យឬបានបោះពុម្ពជាផ្លូវការ ។

គ.៣ ឯកសារតម្កល់

គឺជាឯកសារប្រភពដែលមានលក្ខណៈឯកជនបុគ្គល ក្នុងទម្រង់ដូចជាលិខិតស្នាមផ្សេងៗសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណៈភាព បណ្តាំមរតក លិខិតលែងលះ និងប័ណ្ណកម្មសិទ្ធិជាដើម។

ឃ. សទិសន័យនៃឯកសារប្រភព

គេអាចប្រើពាក្យថាឯកសាប្រភពដូចជាពាក្យខាងក្រោម៖

- ឯកសារយោង - ឯកសារសំអាង - ឯកសារពិគ្រោះ

- បណ្ណាសាស្ត្រ - បុព្វបទទិន្នន័យ - គន្ថនិទ្ទេស

ដើម្បីសម្រួលដល់ភាពស៊ីសង្វាក់គ្នា រវាងការផ្តល់ប្រភពជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងសៀវភៅនេះខ្ញុំនឹងប្រើសញ្ញាវណ្ណយុត្តមួយចំនួនរបស់ខ្មែរដូចជាសញ្ញាចុចពីរ ":" ប្រើជាសញ្ញាភ្នែកមាន់"៖" សញ្ញាចុចមួយចុងក្រោមគេ "." ប្រើជាសញ្ញាខណ្ឌខ្មែរ "។" វិញ។ ប៉ុន្តែមានសញ្ញាវណ្ណយុត្តមួយចំនួនទៀត មិនត្រូវបានផ្លាស់ប្តូរទេ ដូចជាសញ្ញាក្បៀស "," សញ្ញាចុចមួយ "." ក្រៅពីសញ្ញាចុចមួយខាងលើ។ ការធ្វើបែបនេះនឹងផ្តល់ភាពងាយស្រួល ព្រោះថានៅពេលគេបកប្រែវាជាភាសាអង់គ្លេស វានឹងមិនមានការផ្លាស់ប្តូរខ្លាំងឬប្រែប្រួលខ្លាំងទេ។

សម្គាល់ក្រោមទំព័រ)Foot-note = N) ឬសម្គាល់ចុងអត្ថបទ)End-note = N) គឺជាការផ្តល់ប្រភពឯកសារដែលមានព័ត៌មានលម្អិត។ គេប្រើសម្គាល់ក្រោមទំព័រ នៅគ្រប់ទំព័រនីមួយៗដែលមានវាដើម្បីសម្រួលដល់អ្នកអានអាចពិនិត្យមើលប្រភពភ្លាមៗ ដោយមិនចាំបាច់បើកទៅទំព័រណាផ្សេង។រីឯសម្គាល់ចុងអត្ថបទវិញក៏ដូចគ្នានឹងសម្គាល់ក្រោមទំព័រដែរ គ្រាន់តែគេសរសេរវានៅខាងចុងអត្ថបទវិញ។ បើគេចង់អានព័ត៌មានទាក់ទងទៅនឹងសម្គាល់ចុងអត្ថបទនេះ គេត្រូវទៅមើលវានៅខាងក្រោយអត្ថបទ។ ការសរសេរសម្គាល់ចុងអត្ថបទអាចមាននៅខាងចុងផ្នែក ចុងជំពូកចុងមេរៀន ឬចុងសៀវភៅតែម្តង។ សម្គាល់ ម្យ៉ាងទៀតគឺសម្គាល់ក្នុងអត្ថបទ)Text-note = T,= Citation)។ ជាទូទៅគេសរសេរកាត់បំផុត ពីព្រោះវាឋិតនៅក្នុងកថាខណ្ឌជាមួយអត្ថបទតែមួយ។ នៅពេលគេប្រើសម្គាល់ជាទម្រង់សម្គាល់ក្នុងអត្ថបទ គេតម្រូវដាច់ខាតឱ្យមានគន្ថនិទ្ទេសឬឯកសារយោង។ ចំណុចសំខាន់របស់សម្គាល់ក្រោមទំព័រ និងសម្គាល់ចុងអត្ថបទគឺថាគ្រប់សម្គាល់ទាំងពីរនេះ មិនមែនសុទ្ធតែជាការផ្តល់ប្រភពឯកសារទេ។ វាអាចជាការផ្តល់ព័ត៌មានបន្ថែម ការពន្យល់ចំណុចណាមួយលម្អិត ឬការសម្រាយអក្សរកាត់ជាដើម។ ប៉ុន្តែគ្រប់សម្គាល់ក្នុងអត្ថបទសុទ្ធតែជាការផ្តល់ប្រភពឯកសារ។ នៅក្នុងការសរសេរជាទម្រង់សម្គាល់ក្នុងអត្ថបទក៏អាចមានសម្គាល់ក្រោមទំព័រ ឬសម្គាល់ចុងអត្ថបទដែរប៉ុន្តែសម្គាល់ទាំងពីរនេះមិនមែនជាការផ្តល់ប្រភពឯកសារទេ ពោលគឺវាគ្រាន់តែជាការពន្យល់បន្ថែមឬការផ្តល់ព័ត៌មានបន្ថែមតែប៉ុណ្ណោះ។

គន្ថនិទ្ទេស)Bibliography = B) ឬឯកសារយោង/ឯកសារពិគ្រោះ)Reference = R) ជាការសរុបប្រភពឯកសារយោងទាំងអស់ដែលបានយោងនៅក្នុងការពិភាក្សាខាងលើ។ វាមិនមានព័ត៌មានលំអិត ពីទំព័រយោងឬមាត្រាយោងទេ។ ក្នុងចំណោមការសរុបប្រភពឯកសារយោងទាំងពីរនេះគេអាចជ្រើសរើសយកប្រភេទនៃការសរសេរមួយណាក៏បាន មិនមានភាព

ខុសគ្នាទេគ្រាន់តែបើជ្រើសរើសប្រភេទមួយណា ត្រូវសរសេរទៅតាមទម្រង់របស់វាតាំងពីដើមរហូតដល់ចប់ដើម្បីឱ្យមានភាពដូចគ្នា។

៣. របៀបផ្តល់ឯកសារយោងតាមសៀវភៅ

ក. សៀវភៅដែលមានអ្នកនិពន្ធម្នាក់

ស្នាដៃដែលមានអ្នកនិពន្ធតែម្នាក់ នៅក្នុងសម្គាល់ក្រោមទំព័រគេត្រូវសរសេរឈ្មោះអ្នកនិពន្ធភ្ជាប់ដោយក្បៀសខាងក្រោយ បន្ទាប់មកគឺចំណងជើងសៀវភៅ ដោយប្រើអក្សរទ្រេត ហើយដាក់ក្នុងរង្វង់ក្រចកកន្លែងបោះពុម្ព ភ្ជាប់ដោយសញ្ញាភ្នែកមាន់ "៖" និងឈ្មោះរោងពុម្ព រួចក្បៀសដោយដាក់ឆ្នាំបោះ ពុម្ពបន្ទាប់ពីរង្វង់ក្រចកបិទមក ត្រូវដាក់ក្បៀសមួយ និងលេខទំព័ររបស់វារួចបញ្ចប់ដោយសញ្ញាខណ្ឌ "។"។

ចំពោះគន្ថនិទ្ទេសនិងឯកសារយោងវិញ មិនមានរង្វង់ក្រចកទេហើយគ្រប់ក្បៀសដែលកាត់ផ្តាច់ផ្នែកនីមួយៗត្រូវដូរជាសញ្ញាចុចវិញលើកលែងតែក្បៀសបញ្ជាក់ទៅលើផ្នែកណាមួយតែប៉ុណ្ណោះ។

ការស្រង់ជាភាសាអង់គ្លេស ឈ្មោះអ្នកនិពន្ធត្រូវសរសេររបៀបបច្ចឹមប្រទេស។ នៅក្នុងសម្គាល់ក្រោមទំព័រ គេសរសេរឈ្មោះអ្នកនិពន្ធដោយផ្តើមនូវនាមខ្លួនរបស់អ្នកនិពន្ធ និងបញ្ចប់ដោយនាមត្រកូល។ រីឯនៅក្នុងគន្ថនិទ្ទេសវិញ ឈ្មោះអ្នកនិពន្ធត្រូវផ្តើមដោយនាមត្រកូលរួចក្បៀស និងចុងក្រោយនាមខ្លួនអ្នកនិពន្ធ ហើយបញ្ចប់ដោយសញ្ញាខណ្ឌ "។" តែម្តង។ ចូរកត់សម្គាល់ថាមិនមានសញ្ញារង្វង់ក្រចកទេ ចំពោះឯកសារយោងនិងគន្ថនិទ្ទេស។

N: សាយ បូរី, វិទ្យាសាស្ត្ររដ្ឋបាល. ភ្នំពេញ បណ្ណាគារអង្គរ, ២០០៧, ១៥៣

T: (សាយ បូរី ២០០៧, ១៥៣)

B: សាយ បូរី. វិទ្យាសាស្ត្ររដ្ឋបាល. ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧។

R: សាយ បូរី. (២០០៧). *វិទ្យាសាស្ត្ររដ្ឋបាល.* បណ្ណាគារអង្គរ.ភ្នំពេញ។

សៀវភៅដែលមានចំណងជើងធំ និងចំណងជើងរងសៀវភៅខ្លះមានចំណងជើងពីរគឺមួយជាចំណងជើងចម្បងនិងមួយ (ចំណងជើងមេឬចំណងជើងធំ)ទៀតជាចំណងជើងរង ឬចំណងជើងតូច។ ក្នុងករណីនេះចំណងជើងទាំងពីរត្រូវខណ្ឌចែកដាច់ពីគ្នាដោយសញ្ញា "៖" ដើម្បីងាយស្រួលមើលឱ្យឃើញច្បាស់ថាមួយជាចំណងជើងធំនិងមួយទៀតជាចំណងជើងរង។

ចំណងជើងធំ	ចំណងជើងរងត្រូវសរសេរទាំងអស់ បើមានរង្វង់ក្រចកត្រូវសរសេរចូលដែរ

N: សារិន ឆាក, ព្រំដែននៃប្រទេសកម្ពុជា៖ ជាមួយបណ្ដា ប្រទេសនៃអតីតសហព័ន្ធ ឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម កូសាំងស៊ីន)និងអណ្ណាម(ភ្នំពេញ. ឥន្ទ្រទេវី, ២០០៤, ៣៣។

T: (សារិន ឆាគ ២០០៤, ៣៣)

B: សារិន ឆាក. ព្រំដែននៃប្រទេសកម្ពុជា, ជាមួយបណ្ដាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិនប្រទេសកម្ពុជា ឡាវ និងវៀតណាម(កូសាំងស៊ីន និងអណ្ណាម). ភ្នំពេញ, ឥន្ទ្រទេវី, ២០០៤។

R:សារិន ឆាក.(២០០៧). *ព្រំដែននៃប្រទេសកម្ពុជា.* ជាមួយបណ្ដាប្រទេស នៃអតីតសហព័ន្ធឥណ្ឌូចិន ប្រទេសកម្ពុជា ឡាវ និងវៀតណាម (កូសាំងស៊ីន និងអណ្ណាម). ឥន្ទ្រទេវី ភ្នំពេញ។

សៀវភៅដែលមិនមានឈ្មោះរោងពុម្ព សៀវភៅខ្លះមិនមានឈ្មោះរោងពុម្ពទេ តែមានឈ្មោះ កន្លែងបោះពុម្ពផ្សាយក្នុងករណីនេះគេអាចសរសេរតែឈ្មោះកន្លែងបោះពុម្ពផ្សាយ និងឆ្នាំបោះពុម្ពផ្សាយនៅក្នុងសញ្ញារង្វង់ក្រចកក៏បាន។ គួរកត់សម្គាល់ថាគេត្រូវប្រើសញ្ញាក្បៀសដើម្បីផ្ដាច់ឈ្មោះកន្លែងបោះពុម្ពផ្សាយ និងឆ្នាំបោះពុម្ពផ្សាយ។

មានតែកន្លែងបោះពុម្ព តែមិនមានរោងពុម្ព

N:ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរ, ពីដើមដល់ការបោះបង់ក្រុងអង្គរ ភ្នំពេញ. ១៩៧៣, ១០។

T: (ត្រឹង ងា ១៩៧៤, ១០)

B: ត្រឹង ងា. ប្រវត្តិសាស្ត្រខ្មែរ, ពីដើមដល់ការបោះបង់ក្រុងអង្គរ. ភ្នំពេញ, ១៩៧៣។

R: ត្រឹង ងា. (១៩៧៣). *ប្រវត្តិសាស្ត្រខ្មែរ.* ពីដើមដល់ការបោះបង់ក្រុងអង្គរ. ភ្នំពេញ។

ខ. សៀវភៅដែលមិនមានឈ្មោះអ្នកនិពន្ធ និងកន្លែងបោះពុម្ពផ្សាយ

ក្នុងករណីសៀវភៅខ្លះដែលមិនមានទាំងឈ្មោះអ្នកនិពន្ធ និងកន្លែងបោះពុម្ពផ្សាយគេ គេត្រូវសរសេរតែឆ្នាំបោះពុម្ពផ្សាយនៅក្នុងរង្វង់ក្រចកតែម្តងជាការស្រេច។

មានតែឆ្នាំបោះពុម្ព ហើយមិនមានឈ្មោះ រោងពុម្ព និងកន្លែងបោះពុម្ពទេ

N: ជា សំ, ប្រវត្តិសាស្ត្រខ្មែរ និងការធ្លាក់ចុះនៃអរិយធម៌អង្គរ. ២០០៤, ២០៣។

T: (ជា សំ ២០០៤, ២០៣)

B: ជា សំ. ប្រវត្តិសាស្ត្រខ្មែរ និងការធ្លាក់ចុះនៃអរិយធម៌អង្គរ. ២០០៤។

R: ជា សំ. (២០០៤). *ប្រវត្តិសាស្ត្រខ្មែរ និងការធ្លាក់ចុះនៃអរិយធម៌អង្គរ។*

គ. សៀវភៅដែលមានអ្នកនិពន្ធពីរនាក់

ដូចគ្នានឹងអ្នកនិពន្ធម្នាក់ដែរ ឯកសារដែលមានអ្នកនិពន្ធពីរនាក់ ត្រូវសរសេរឈ្មោះអ្នកនិពន្ធទាំងពីរដោយភ្ជាប់នឹងឈ្នាប់ "និង"។

N: ប៉ែន សុវណ្ណ និងនាង សាវុន, ជីវប្រវត្តិ និងបុព្វហេតុជាតិមាតុភូមិកម្ពុជាភ៍ស៊ីង) គោន. ចក្ខុវិស័យខ្មែរ, ២០០២(, ១៩៧។

T: (ប៉ែន សុវណ្ណ និង នាង សាវុន ២០០២, ១៩៧)

B: ប៉ែន .សុវណ្ណ និងនាង សាវុន, ជីវប្រវត្តិ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា. ភ៍ស៊ីនគោន. ចក្ខុវិស័យខ្មែរ, ២០០២។

R: ប៉ែន សុវណ្ណនិងនាង សាវុនៈ(២០០២).*ជីវប្រវត្តិនិងបុព្វហេតុជាតិមាតុភូមិកម្ពុជា.* ភ៍ស៊ីង គោន. ចក្ខុវិស័យខ្មែរ។

ឃ. សៀវភៅដែលមានអ្នកនិពន្ធបីនាក់

ដូចគ្នានឹងអ្នកនិពន្ធពីរនាក់ដែរ ឯកសារដែលមានអ្នកនិពន្ធបីនាក់ ត្រូវសរសេរឈ្មោះអ្នកនិពន្ធទាំងបីរៀង គ្នាដោយមានសញ្ញាក្បៀស និងចុងក្រោយភ្ជាប់នឹងឈ្នាប់ "និង"។

N: សោម វាសនា, សំណាង ផាន់ណា និងសួស សាលី, នយោបាយខ្មែរ. ភ្នំពេញ បណ្ណាគារអង្គរ, ២០០២,៦៧។

T: (សោម វាសនា, សំណាង ផាន់ណា និងសួស សាលី ២០០២, ៦៧)

B:សោមវាសនា, សំណាង ផាន់ណា និងសួស សាលី. នយោបាយខ្មែរ. ភ្នំពេញបណ្ណាគារអង្គរ, ២០០២។

R:សោម វាសនា,សំណាង ផាន់ណានិងសូស សាលី. (២០០២).*នយោបាយខ្មែរ*. ភ្នំពេញ. បណ្ណាគារ អង្គរ។

ង. សៀវភៅដែលមានអ្នកនិពន្ធច្រើនជាងបីនាក់

ចំពោះសៀវភៅដែលមានអ្នកនិពន្ធច្រើនជាងបីនាក់ ត្រូវសរសេរឈ្មោះអ្នកនិពន្ធទីមួយ និងភ្ជាប់ដោយកន្សោមពាក្យ"និងផ្សេងទៀត"។ប៉ុន្តែចំពោះគន្ថនិទ្ទេស និងឯកសារយោងត្រូវសរសេរពាយឈ្មោះអ្នកនិពន្ធទាំង អស់រៀងគ្នាដោយមានក្បៀស និងចុងក្រោយមានសញ្ញាខណ្ឌ "។" សម្រាប់បញ្ចប់។

ប្រើពាក្យ "និងផ្សេងទៀត" ដោយមិនចាំបាច់រៀបរាប់ឈ្មោះអ្នកនិពន្ធផ្សេងទៀតទេនៅក្នុងគ្រប់ទម្រង់នៃសម្គាល់ទាំងអស់

N: អ៊ុន លាង និងផ្សេងទៀត, គ្រឹះរបស់ទស្សនវិជ្ជា. ភ្នំពេញ. ២០០៦, ៥០

T: (អ៊ុន លាងនិងផ្សេងទៀត, ២០០៦,៥០)

B: អ៊ុន លាង, ប៉ាន់ វុត្ថា, ខ្មៅ សាវន, ឈត ប៊ុនថង និងឈុន ផាវ៉េង.គ្រឹះរបស់ទស្សនវិជ្ជា. ភ្នំពេញ, ២០០៦។

R: អ៊ុន លាង, ប៉ាន់ វុត្ថា, ខ្មៅ សាវន, ឈត ប៊ុនថង និងឈុន ផាវ៉េង. (២០០៦). *គ្រឹះរបស់ទស្សនវិជ្ជា*. ភ្នំពេញ។

ត្រូវរៀបរាប់ឈ្មោះអ្នកនិពន្ធទាំងអស់នៅក្នុងគន្ថនិទ្ទេស និងឯកសារយោង

ច. សៀវភៅឥតមានឈ្មោះអ្នកនិពន្ធ (មិនស្គាល់ឈ្មោះអ្នកនិពន្ធ)

ចំពោះសៀវភៅដែលមិនមានឈ្មោះអ្នកនិពន្ធ ឬអ្នកនិពន្ធអនាមិកនៅគន្ថនិទ្ទេសនិងឯកសារយោងត្រូវសរសេរនៅត្រង់ឈ្មោះអ្នកនិពន្ធនូវពាក្យ "អ្នកនិពន្ធអនាមិក"។ បើអ្នកនិពន្ធអនាមិកច្រើនតៗគ្នា ត្រូវឆូតបន្ទាត់ជំនួសកន្លែងអ្នកនិពន្ធអនាមិកផ្សេងរៀងគ្នាពោលគឺដូចគ្នាទៅនឹងឈ្មោះអ្នកនិពន្ធដូចគ្នាជាច្រើនដែរ។ ប៉ុន្តែចំពោះសម្គាល់នៅក្រោមទំព័រវិញ មិនចាំបាច់សរសេរ "អ្នកនិពន្ធអនាមិក" ទេ។

ឧទាហរណ៍ ទី១

N: ជីវិតឆ្ពោះទៅរកជោគជ័យ. ភ្នំពេញ. ២០០១, ៨០

T: (អ្នកនិពន្ធអនាមិក, ២០០១,៨០)

B: អ្នកនិពន្ធអនាមិក. ជីវិតឆ្ពោះទៅរកជោគជ័យ. ភ្នំពេញ. ២០០១។

R: អ្នកនិពន្ធអនាមិក. (២០០១). *ជីវិតឆ្ពោះទៅរកជោគជ័យ.* ភ្នំពេញ។

ឧទាហរណ៍ ទី២

N: ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ. ភ្នំពេញ. ២០១១, ១៥៩។

T: (អ្នកនិពន្ធអនាមិក, ២០០១,១៥៩)

B: អ្នកនិពន្ធអនាមិក. ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ. ភ្នំពេញ.២០១១។

R: អ្នកនិពន្ធអនាមិក. (២០០១). *ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ. ភ្នំពេញ*។

ឧទាហរណ៍ ទី៣

N: វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ. ភ្នំពេញ. ២០០៣, ៤៣។

T: (អ្នកនិពន្ធអនាមិក, ២០០៣,៤៣)

B: អ្នកនិពន្ធអនាមិក. វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ. ភ្នំពេញ, ២០០៣។

R:អ្នកនិពន្ធអនាមិក. (២០០៣). *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ.* ភ្នំពេញ។

រណីសរសេរក្នុងគន្ថនិទ្ទេស ឬឯកសាក្នុងករយោងដែលមានអ្នកនិពន្ធអនាមិកច្រើនត្រូវឆ្វេតបន្ទាត់មួយពីក្រោមអ្នកនិពន្ធអនាមិកខាងលើ 1 tap រួចប្រើសញ្ញាចុច "."។ ការតម្រៀបលំដាប់អក្ខរក្រមនៅពេលនេះ គឺផ្អែក តាមតួអក្សរនៃចំណងជើងសៀវភៅ។

ស ឧទាហរណ៍នៃការសរុបបញ្ជីប្រភពឯកសារនៅក្នុងគន្ថនិទ្ទេ ពាក់ព័ន្ធនឹងសៀវភៅដែលមានអ្នកនិពន្ធ អនាមិកច្រើន។

គន្ថនិទ្ទេស

អ្នកនិពន្ធអនាមិក. ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ.ភ្នំពេញ, ២០១១។

__________. ជីវិតឆ្ពោះទៅរកជោគជ័យ. ភ្នំពេញ, ២០០១។

__________.វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ. ភ្នំពេញ, ២០០៣។

↑

បន្ទាត់នេះបញ្ជាក់ថាអ្នកនិពន្ធអនាមិកដូចខាងលើដែរប៉ុន្តែលំដាប់នៃការដាក់តម្រៀបគ្នានេះគឺតាមលំដាប់អក្សរដែលត្រូវផ្តើមចេញពី "ចំណង = ច" បន្ទាប់ មក "ជីវិត = ជ" និងចុងក្រោយគឺ "វិស័យ = វ" រៀងគ្នា។

ឧទាហរណ៍នៃការសរុបបញ្ជីប្រភពឯកសារ នៅក្នុងឯកសារយោងពាក់ព័ន្ធនឹងសៀវភៅដែលមានអ្នកនិពន្ធអនាមិកច្រើន។

ឯកសារយោង

អ្នកនិពន្ធអនាមិក. ២០១១. *ចំណងមិត្តភាពកម្ពុជា វៀតណាម និងឡាវ.* ភ្នំពេញ។

____________. ២០០១. *ជីវិតឆ្ពោះទៅរកជោគជ័យ.* ភ្នំពេញ។

____________. ២០០៣. *វិស័យការងារនៅកម្ពុជា និងការកើនឡើងនៃសេដ្ឋកិច្ចជាតិ.* ភ្នំពេញ។

លំដាប់នៃការដាក់តម្រៀបគ្នានេះ គឺតាមលំដាប់អក្សរដែលត្រូវផ្ដើមចេញពី "ចំណង = ច" បន្ទាប់មក "ជីវិត = ជ" និងចុងក្រោយគឺ "វិស័យ = វ" ពោលគឺវាមិនអាស្រ័យនឹងលំដាប់នៃឆ្នាំបោះពុម្ពទេ។

ឆ. សៀវភៅមិនមានឈ្មោះអ្នកនិពន្ធ ឈ្មោះអ្នកនិពន្ធ)ត្រូវបានគេស្គាល់(

ប្រសិនបើសៀវភៅដែលត្រូវយកមកយោង មិនមានសរសេរឈ្មោះអ្នកនិពន្ធ ឬឈ្មោះអ្នកនិពន្ធត្រូវបានគេលុបចោល ប៉ុន្តែឈ្មោះអ្នកនិពន្ធនោះត្រូវបានគេស្គាល់ ឬប៉ាន់ស្មានបានត្រូវសរសេរឈ្មោះអ្នកនិពន្ធនោះនៅ ក្នុងសញ្ញាឃ្នាប "[ ]"។

ឧទាហរណ៍ឈ្មោះអ្នកនិពន្ធដែលត្រូវបានគេស្គាល់

ឃ្នាបនេះមានន័យថាឈ្មោះអ្នកនិពន្ធនៃឯកសារយោងត្រូវបានអ្នកយោងស្គាល់។

N: [ពៅ សុក], ការអប់រំ និងអភិវឌ្ឍនៅកម្ពុជា. ភ្នំពេញ, ២០០៩, ៩៣

T: ([ពៅ សុក] ២០០៩, ៩៣)

B: [ពៅ សុក]. ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា. ភ្នំពេញ. ២០០៩

R: [ពៅ សុក]. (២០០៩). *ការអប់រំ និងការអភិវឌ្ឍនៅកម្ពុជា.* ភ្នំពេញ។

ឧទាហរណ៍ឈ្មោះអ្នកនិពន្ធដែលត្រូវបានគេស្មាន

ឃ្លាបដោយមានសញ្ញាសួរនេះមានន័យថាឈ្មោះអ្នកនិពន្ធនៃឯកសារយោងត្រូវបានអ្នកយោងស្មាន

N: [ពៅ សៅ?], ការរីកដុះដាលសណ្ឋាគារនៅកម្ពុជា. ភ្នំពេញ. ២០០៦, ៧៦

T: ([ពៅ សៅ?] ២០០៦, ៧៦)

B: [ពៅ សៅ?]. ការរីកដុះដាលសណ្ឋាគារនៅកម្ពុជា. ភ្នំពេញ. ២០០៦។

R: [ពៅ សៅ?]. (២០០៦). *រីកដុះដាលសណ្ឋាគារនៅកម្ពុជា*. ភ្នំពេញ។

ជ. សៀវភៅដែលមិនមានឈ្មោះអ្នកនិពន្ធ តែមានឈ្មោះអ្នកប្រែសម្រួល

ពេលគ្មានឈ្មោះអ្នកនិពន្ធនៅលើក្របមុខសៀវភៅ ប៉ុន្តែមានតែឈ្មោះអ្នកប្រែសម្រួល អ្នករៀបរៀងអ្នកកែសម្រួល អ្នកចងក្រង ឬអ្នកបកប្រែនៅលើក្របនៃសៀវភៅនេះ យើងត្រូវសរសេរឈ្មោះអ្នកទាំងនោះជំនួសឈ្មោះអ្នកនិពន្ធដោយគ្រាន់តែប្រើពាក្យថា "ប្រែសម្រួល" "កែសម្រួល" "ចងក្រង" ឬ"បកប្រែ" នៅពីក្រោមឈ្មោះ។ ប៉ុន្តែចំពោះសម្គាល់ក្នុងអត្ថបទមិនចាំបាច់ប្រើពាក្យទាំងនេះទេ។

ឧទាហរណ៍ សៀវភៅដែលមានឈ្មោះអ្នកប្រែសម្រួល

N:គឹមចាន់ណា,ប្រែសម្រួល,បញ្ញាញាណរបស់អែនស្តែន. ភ្នំពេញ. ឥន្ទ្រីមាស. ២០០៨, ២៧

T: (គឹម ចាន់ណា, ២០០៣,៤៣)

B: គឹម ចាន់ណា, ប្រែសម្រួល. បញ្ញាញាណរបស់អែនស្តែន. ភ្នំពេញ. ឥន្ទ្រីមាស. ២០០៨។

R: គឹន ចាន់ណា, ប្រែសម្រួល. (២០០៨). *បញ្ញាញាណរបស់អែនស្តែន*. ភ្នំពេញ. ឥន្ទ្រីមាស។

ឧទាហរណ៍ សៀវភៅដែលមានឈ្មោះអ្នករៀបរៀង

N:កៅ មុលថង, មុនី វីរៈ និងភ័ន់ ច័ន្ទតារា, រៀបរៀង, សេចក្តីផ្តើមនៃនីតិខ្មែរ. ភ្នំពេញ. បណ្ណាគារអង្គរ, ២០០៧, ៦១

T: (កៅ មុលថង,មុនី វីរៈ និងភ័ន់ ចន្ទតារា ២០០៧,៦១)

B:កៅ មុលថង, មុនី វីរៈ និងភ័ន់ ច័ន្ទតារា, រៀបរៀង. សេចក្តីផ្តើមនៃនីតិខ្មែរ. ភ្នំពេញ. បណ្ណាគារអង្គរ, ២០០៧។

R: កៅ មុលថង, មុនី វីរៈ និងភ័ន់ ច័ន្ទតារា, រៀបរៀង. (២០០៧). *សេចក្តីផ្តើមនៃនីតិខ្មែរ*. ភ្នំពេញ. បណ្ណាគារអង្គរ។

ឧទាហរណ៍ សៀវភៅដែលមានឈ្មោះអ្នកកែសម្រួល

N: កុល ចំណាន, កែសម្រួល, សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសេដ្ឋកិច្ចតំបន់. ភ្នំពេញ. ឥន្ទ្រទេវី.២០១១, ៣០៨

T: (កុយ ចំណាន, ២០០៣,៥៣)

B: កុយ ចំណាន, កែសម្រួល. សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសេដ្ឋកិច្ចតំបន់. ភ្នំពេញ. ឥន្ទ្រទេវី, ២០១១។

R: កុយ ចំណាន, កែសម្រួល. (២០១១). *សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសេដ្ឋកិច្ចតំបន់.* ភ្នំពេញ. ឥន្ទ្រទេវី។

ឧទាហរណ៍ សៀវភៅដែលមានឈ្មោះអ្នកចងក្រង

N:ជារតនៈ,ចងក្រង,ប្រវត្តិសង្ខេបតំណាងរាស្ត្រពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨.ភ្នំពេញ. សុខលាប , ២០១០, ៨០

T: (ជា រតនៈ, ២០១០,៨០)

B:ជារតនៈ,ចងក្រង.ប្រវត្តិសង្ខេបតំណាងរាស្ត្រពីឆ្នាំ១៩៩៣ដល់ឆ្នាំ២០០៨. ភ្នំពេញ. សុខលាប , ២០១០។

R: ជា រតនៈ, ចងក្រង. (២០១០). *ប្រវត្តិសង្ខេបតំណាងរាស្ត្រពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨.* ភ្នំពេញ. សុខលាប។

ឧទាហរណ៍ សៀវភៅដែលមានឈ្មោះអ្នកបកប្រែ

N: ជា វិសុទ្ធ, បកប្រែ, ប្រព័ន្ធបោះឆ្នោតពិភពលោក. ភ្នំពេញ. បណ្ណាគារអង្គរធំ, ២០០១, ៩៨

T: (ជា វិសុទ្ធ ២០០១, ៩៨)

B:ជាវិសុទ្ធ, បកប្រែ. ប្រព័ន្ធបោះឆ្នោតពិភពលោក. ភ្នំពេញ. បណ្ណាគារអង្គរធំ, ២០០១។

R:ជាវិសុទ្ធ,បកប្រែ. (២០០១). *ប្រព័ន្ធបោះឆ្នោតពិភពលោក.* ភ្នំពេញ. បណ្ណាគារអង្គរធំ។

ឈ. អ្នកកែសម្រួល ឬអ្នកបកប្រែបន្ថែមទៅលើឈ្មោះអ្នកនិពន្ធ

ចំពោះស្នាដៃកែសម្រួល ចងក្រង ឬបកប្រែរបស់អ្នកនិពន្ធណាមួយត្រូវសរសេរឈ្មោះអ្នកនិពន្ធមុនរួចចំណងជើង បន្ទាប់មកត្រូវសរសេរពាក្យថា "កែសម្រួល" "ចងក្រង" ឬ "បកប្រែ" ពីមុខឈ្មោះអ្នកកែសម្រួលចងក្រង ឬបកប្រែ។ ប៉ុន្តែនៅក្នុងគន្ថនិទ្ទេសវិញ ត្រូវសរសេរ "កែសម្រួលដោយ" "ចងក្រងដោយ" ឬ"បកប្រែដោយ"នៅពីមុខឈ្មោះវិញ។ ប្រសិនបើមានទាំងឈ្មោះអ្នកកែសម្រួលផង និងឈ្មោះអ្នកបកប្រែផងត្រូវសរសេរទៅតាមលំដាប់ ដូចគ្នានឹងទំព័រ

ក្របខាងមុខគេបង្អស់។ គួរកត់សម្គាល់ថាឈ្មោះអ្នកបកប្រែត្រូវបានសរសេរទាំងអស់ទោះបីជាមានចំនួនប៉ុន្មាននាក់ក៏ដោយ។

ឧទាហរណ៍ សៀវភៅដែលមានឈ្មោះអ្នកកែសម្រួល បន្ថែមលើឈ្មោះអ្នកនិពន្ធ

N: ចៅ វាសនា, ជំបូន្មានខ្មែរ, កែសម្រួល ទេព សំណាង, ភ្នំពេញ. សុខលាប. ២០០០, ៩៩

នៅក្នុងសម្គាល់ប្រើតែពាក្យ "កែសម្រួល" រួចឈ្មោះអ្នកកែសម្រួល

T: (ចៅ វាសនា, ២០០០,៩៩)

B: ចៅ វាសនា. ជំបូន្មានខ្មែរ. កែសម្រួលដោយ ទេព សំណាង. ភ្នំពេញ. សុខ លាប, ២០០០។

នៅក្នុងគន្ថនិទ្ទេសប្រើពាក្យ "កែសម្រួលដោយ" រួចឈ្មោះអ្នកកែសម្រួល

R: ចៅ វាសនា. (២០០០). *ជំបូន្មានខ្មែរ.* កែសម្រួល ទេព សំណាង. ភ្នំពេញ. សុខ លាប។

ខុសពីគន្ថនិទ្ទេស នៅក្នុងឯកសារយោងប្រើពាក្យ "កែសម្រួល" រួចឈ្មោះអ្នកកែសម្រួល

៤. របៀបផ្តល់ឯកសារយោង (Referience) **ដែលដកស្រង់ចេញពី អ៊ីនធឺណេត** (Internet)

ឯកសារប្រភពដែលអ្នកស្រាវជ្រាវដកស្រង់យកមកធ្វើជាអំណះអំណាង ក្នុងការស្រាវជ្រាវមាន ច្រើនប្រភេទខាងក្រោមនេះជារបៀបដកស្រង់តាមពីប្រព័ន្ធអ៊ីនធឺណេត(Internet) ឬប្រព័ន្ធអេឡិចត្រូនិច។

១. ដកស្រង់ចេញពី វែបសាយ (Website)

1. Kenneth, I . A (2000). A Buddist Respone to the nature of human rights, Journal of Buddist Ethics,(4) ទាញយកខែកុម្ភៈ ទី២០,ឆ្នាំ២០០១, ពីhttp:// www.cac.psu.edu./two cont.html

2.Giancola, P.R.(2004). Ecucutive functioning and alcohol- relative aggression Amercan. Psychologist, 59(2),5-7. ទាញមកពី httl: www.apa.org.Journal/amp

២. ដកស្រង់ចេញពីកាសែតអង់គ្លេស

1.Borown, P.L.(1999,September 5).Tiffany glass and other tales from the ,crypt.the new York Time, pp.1,5 .ទាញមកពី http: www.nytimes .com/

2. Ebert, R.(2009,May 6).[Review of the motion picture.Star trec, produced by paramount, 2009].gicago. Sun-Times ទាញមកពី http: rogcre.bert.suntimes.com

ជំពូក ៩ គំរូគំរោងសំណើស្រាវជ្រាវ

LOGO **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
ROYAL UNIVERSITY OF PHNOM PENH
មហាវិទ្យាល័យសង្គមសាស្ត្រមនុស្សសាស្ត្រ
ដេប៉ាតឺម៉ង់ អក្សរសាស្ត្រខ្មែរ

ការប្រើប្រាស់គ្រឿងញៀនឡើងវិញរបស់យុវជននៅ
មជ្ឈមណ្ឌលឱកាសខ្ញុំ

សាស្ត្រាចារ្យដឹកនាំ ....

ស្នេរសារណា ....

មិថុនា ២០១៤

មាតិកា

ចំណងជើង ទំព័រ

ជំពូក១ សេចក្តីផ្តើម

១.១ គោលបំណង....................

១.២ ចំណោទបញ្ហា....................

១.៣ សារៈសំខាន់នៃការស្រាវជ្រាវ....................

១.៤ ដែនកំណត់នៃការស្រាវជ្រាវ....................

ជំពូក២ រំលឹកទ្រឹស្តី

២.១ ការឱ្យនិយមន័យប្រត្តិបត្ត....................

២.២ ការស្រាវជ្រាវស្ទាដៃពាក់ពន្ធ....................

ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ

៣.១ ការកំណត់អថេរនិងសម្មតិកម្ម....................

៣.២ការជ្រើសរើសទីកន្លែង....................

៣.៣ការជ្រើសរើសសំណាក....................

៣.៤ដំណើរការនៃការស្រាវជ្រាវ....................

៣.៥ កម្រងសំណួរ....................

៣.៦ វិធីសាស្ត្រនៃការវិភាគ....................

ជំពូក៤ លទ្ធផលរំពឹងទុក

៤.១. លទ្ធផលដែលទទួលបាន....................

៤.២. ប្រើប្រាស់ដើម្បី....................

ជំពូក៥ ផែនការសកម្មភាពនិងផែនការថវិកា

៥.១. ផែនការសកម្មភាព....................

៥.២. ផែនការថវិកា....................

៥.៣ ឯកសារយោង....................

ឧបសម្ព័ន្ធ....................

ជំពូក១ សេចក្តីផ្តើម

នៅក្នុងការរស់នៅនិងទង្វើរបស់យុវជនសម័យបច្ចុប្បន្ន បានធ្វើឱ្យសង្គមមានកង្វល់ជាច្រើនដូចជាការសេពគប់មិត្តភក្តិការវក់វី និងល្បែងពាលារហូតដល់ការប្រើប្រាស់គ្រឿងញៀនរបស់យុវជនជាដើម។ ទាំងនេះជាបញ្ហាចម្បងមួយរបស់សង្គមហើយត្រូវតែរកដំណោះស្រាយបើយុវជនមិនព្រម បញ្ឈប់ហើយនៅតែបន្តប្រើប្រាស់សារធាតុញៀននោះសុខភាពផ្លូវកាយផ្លូវចិត្តនិងស្មារតីនិងជីវិតរបស់ពួកគេនឹង ទទួលផលប៉ះពាល់ហើយវាក៏ជះឥទ្ធិពលអាក្រក់មកលើគ្រួសារ សង្គមនិងប្រទេសជាតិទាំងមូលផងដែរ។ ប្រការដែលយុវជនមួយចំនួនឈានទៅរកការប្រើប្រាស់គ្រឿងញៀន ម្តងហើយម្តងទៀតនោះ គឺជាការយល់ឃើញរបស់បុគ្គលការជឿជាក់ការឱ្យតម្លៃខ្លួនឯងការមានទំនុកចិត្តលើខ្លួនឯងមានកម្រិតទាប ក្រុមគ្រួសារឬអាណាព្យាបាលមិនយល់ពីទឹកចិត្តរបស់ពួកគេការអូសទាញពីមិត្តភក្តិអាក្រក់ និងអាចបណ្តាលមកពីកត្តាឥទ្ធិពលសង្គមនៃការរើសអើងជាពិសេសភាពងាយរកទិញគ្រឿងញៀនផងដែរ។

ជាមួយគ្នានេះនៅក្នុងរាជធានីភ្នំពេញ មានមជ្ឈមណ្ឌលមួយឈ្មោះថា "មជ្ឈមណ្ឌលឱកាសខ្ញុំ" ដែលជាអង្គការមិនមែនរដ្ឋាភិបាលចំណុះឱ្យស្ថាប័នរដ្ឋ មានតួនាទីទទួលយកយុវជនប្រើប្រាស់គ្រឿងញៀនមកស្នាក់នៅជាបណ្តោះអាសន្នក្នុងរយៈពេលមួយកំណត់ ដើម្បីធ្វើការអប់រំព្យាបាលស្តារនីតិសម្បទានិងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ពួកគេ។ ការបណ្តុះបណ្តាលនេះក្នុងគោលបំណងកែប្រែពួកគេ និងចង់ឱ្យពួកគេរស់នៅឱ្យឆ្ងាយពីគ្រឿងញៀន។ ក្រោយពីការចុះស្រាវជ្រាវស្វែងយល់មួយរយៈពេលមកឃើញថា ទោះបីរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់គេមានលក្ខណៈល្អប្រសើរនិងបានបញ្ចូលទាំងកម្មវិធីនានា របស់មជ្ឈមណ្ឌលឱកាសខ្ញុំច្បាស់លាស់យ៉ាងណាក៏ដោយ ក៏នៅមានយុវជនមួយចំនួនធំបរាជ័យក្នុងការផ្តាច់គ្រឿងញៀនដែរត្រង់នេះមានន័យថា ពួកគេនៅតែបន្តប្រើប្រាស់គ្រឿងញៀនដដែល ហើយបានវិលចូលក្នុងមជ្ឈមណ្ឌលឱកាសខ្ញុំម្តងទៀត ទោះបីពួកគេទទួលបានការបន្សាបសារធាតុញៀនបានជាសះស្បើយយ៉ាងណាក៏ដោយ។

កត្តាដែលធ្វើឱ្យយុវជនលាប់ឡើងវិញ ក្នុងការប្រើប្រាស់គ្រឿងញៀន គឺមានទាក់ទងទៅនឹងបញ្ហាមួយចំនួន ហើយការរកឃើញមូលហេតុនៃបញ្ហា ជាគន្លឹះដើម្បីជួយដល់ពួកគេឱ្យចៀសផុតពី ទាសករនៃគ្រឿងញៀន ក៏ដូចជាការរួមចំណែកក្នុងការជួយដោះស្រាយបញ្ហា និងកង្វល់របស់សង្គមជាតិទៀតផង។

អាស្រ័យដូចបានជម្រាបជូនខាងលើ ទើបយើងសម្រេចចិត្ត ជ្រើសរើសប្រធានបទ "ការ

ប្រើប្រាស់ គ្រឿងញៀនឡើងវិញរបស់យុវជននៅក្នុងមជ្ឈមណ្ឌលនិកាសខ្ញុំ" យកមកធ្វើការសិក្សា និងវិភាគដើម្បីដោះស្រាយនៅចម្ងល់ដែលវាមាននៅក្នុងចិត្ត និងរួមចំណែកជួយដោះស្រាយបញ្ហារបស់សង្គម ជាតិយើងទាំងមូលឱ្យរួចផុតពីការប្រើប្រាស់គ្រឿងញៀន។

១.១.ការកំណត់បញ្ហាស្រាវជ្រាវ

១.២. គោលបំណង

"ចង់ស្វែងរកពីកត្តាចម្បងដែលធ្វើឱ្យយុវជនធ្លាក់ខ្លួនប្រើគ្រឿងញៀនផ្ដាំម្ដងហើយម្ដងទៀត"

១.៣. វត្ថុបំណង

- សិក្សាពីស្ថានភាពគ្រួសាររបស់ពួកគេ
- សិក្សាពីកម្រិតវប្បធម៌របស់ពួកគេ
- សិក្សាពីបរិស្ថាននៅជុំវិញផ្ទះដែលពួកគេរស់នៅ (អ្នកជិតខាង មិត្តភក្តិ។ល។)
- សិក្សាពីបញ្ហាប្រឈមនឹងសង្គមដែលពួកគេរស់នៅ(ការឱ្យតម្លៃរបស់សង្គម)
- សិក្សាពីការឱ្យតម្លៃខ្លួនឯង
- សិក្សាពីមុខរបររបស់ពួកគេ ក្រោយពីចេញពីមជ្ឈមណ្ឌលនិកាសខ្ញុំ

១.៤.ចំណោទបញ្ហា

យុវជន គឺជាកម្លាំងធនធានមនុស្សដ៏សំខាន់សម្រាប់ប្រទេសជាតិ ព្រោះពួកគេគឺជាអ្នកធ្វើឱ្យសេដ្ឋកិច្ចប្រទេសជាតិមានការរីកចម្រើនបានល្អ។ ប៉ុន្តែដោយសារតែឥទ្ធិពល នៃការប្រើគ្រឿងញៀនបានធ្វើឱ្យពួកគេមានការបាត់បង់ស្មារតី ការសិក្សារៀនសូត្រ ការចងចាំសុខភាពផ្លូវកាយផ្លូវចិត្ត។ បើទោះបីជា ពួកគេបានទទួលការព្យាបាលផ្ដាច់គ្រឿងញៀនហើយក៏ដោយក៏យើងសង្កេតឃើញថាមានយុវជនមួយចំនួន បានធ្លាក់ក្នុងអន្ទាក់គ្រឿងញៀនដដែល។ ហេតុនេះហើយទើបយើងខ្ញុំចង់សិក្សាស្វែងយល់ឱ្យ កាន់តែច្បាស់ហើយបានចោទនូវសំណួរមួយចំនួនដូចជា៖

- តើយើងមានដំណោះស្រាយជាក់លក្ខឬទេលើបញ្ហានេះ?
- តើអ្នកណាខ្លះត្រូវចូលរួមដោះស្រាយលើបញ្ហាដ៏ស្មុគស្មាញនេះ?
- តើការស្រាវជ្រាវរបស់យើងទៅលើប្រធានបទនេះ មានភាពជោគជ័យដែរឬទេ?
- តើអ្វីជាឧបសគ្គក្នុងការស្រាវជ្រាវលើប្រធានបទនេះ?
- តើក្រុមគោលដៅរបស់យើងពេញចិត្តចូលរួមក្នុងការងារនេះជាមួយយើងដែរឬទេ?

ជំពូក២

រំលឹកទ្រឹស្តី

ជាទូទៅគេសង្កេតឃើញថាការប្រើប្រាស់គ្រឿងញៀនចាប់ផ្តើមពីយុវវ័យ ហើយការប្រើប្រាស់នេះមានហេតុផលមួយចំនួនដូចជា បណ្តាលពីសម្ពាធមិត្តភក្តិ ការចង់សាកល្បងចង់ស្គាល់ចង់ដឹងចង់ដោះស្រាយបញ្ហាមួយចំនួននិងភាពគ្មានការងារធ្វើជាដើម។ មនុស្សដែលញៀនពួកគេប្រើប្រាស់គ្រឿងញៀនជាប្រចាំរៀងរាល់ថ្ងៃ។ ប្រសិនបើពួកគេមិនបានប្រើប្រាស់គ្រឿងញៀនទេពួកគេប្រឈមមុខនឹងការលំបាកក្នុងខ្លួនយ៉ាងខ្លាំង ហើយកើតមានរោគសញ្ញាចម្រុះមួយចំនួន លើរាងកាយដូចជាសម្រាន មិនលក់ ហៀរសំបោរ តែងតែចេញទឹកភ្នែក ជួនកាលមានរាគរូសទៀតផង ហើយរោគសញ្ញា ទាំងអស់នេះហៅថាជារោគសញ្ញានៃការផ្តាច់គ្រឿងញៀន ។

ដំណើរវិវឌ្ឍន៍នៃការប្រើប្រាស់គ្រឿងញៀន ដំបូងចាប់ផ្តើមនៅពេលដែលបុគ្គលមានមិត្តភក្តិប្រើប្រាស់គ្រឿងញៀន បន្ទាប់មកគាត់អាចត្រឹមតែសាកល្បង ដើម្បីចង់ដឹងប៉ុណ្ណោះក្រោមយមកទៀតគាត់មានការរីករាយជាមួយគ្រឿងញៀន ហើយបន្តការប្រើច្រើនឡើងៗជារហូតដល់កម្រិតមួយគឺញៀននៅពេលដែលបុគ្គល មានអារម្មណ៍ដូចជាមានជម្ងឺនៅពេលដែលគាត់មិនប្រើគ្រឿងញៀន ដូចនេះគាត់ត្រូវតែប្រើវាជាទៀងទាត់ដើម្បីបំបាត់អារម្មណ៍ដូចជាមានជម្ងឺ (មិនស្រឡះក្នុងខ្លួន)។

វាជាប្រការសំខាន់ណាស់ ក្នុងការកត់សម្គាល់ពីអត្រានៃការត្រឡប់ទៅប្រើគ្រឿងញៀនវិញបន្ទាប់ពីការព្យាបាលនិងការស្តារនីតិសម្បទាវិញនោះ ជាពិសេសថ្នាំឆ្កួត គឺមានកម្រិតខ្ពស់។ កត្តាមួយក្នុងចំណោមកត្តាសំខាន់ៗនោះគឺថា កោសិកាខួរក្បាល ដូផាមីន បានងាប់ដោយការប្រើថ្នាំឆ្កួតជាបន្ត បន្ទាប់ ហើយកោសិកាទាំងនេះ ជាផ្នែកយ៉ាងសំខាន់បំផុត ចំពោះប្រព័ន្ធត្រូវការក្នុងការលើកទឹកចិត្ត និងរក្សាចំណាប់អារម្មណ៍ទាំងឡាយដែលកោសិកាទាំងនេះត្រូវចំណាយពេលពីពីរទៅបីឆ្នាំ បន្ទាប់ពីការឈប់ប្រើប្រាស់គ្រឿងញៀន។ លើសពីនេះទៅទៀតដោយសារកង្វះខាតនៃបរិយាកាសសង្គមដែលបង្កឱ្យមានការគាំទ្រចំពោះការប្រើគ្រឿងញៀនធ្វើឱ្យមានការលំបាកយ៉ាងខ្លាំងសម្រាប់អ្នកធ្លាប់ប្រើគ្រឿងញៀនក្នុងការប្រព្រឹត្តខុសពីអ្នកកំពុងប្រើគ្រឿងញៀនដែលជាមិត្តភក្តិរបស់ពួកគេនិងបរិយាកាសនៅជុំវិញគេ។

២.១ ការឱ្យនិយមន័យប្រតិបត្តិ

មនុស្សដែលធ្លាប់តែប្រើគ្រឿងញៀនហើយ ធ្លាក់ខ្លួនមកប្រើគ្រឿងញៀនម្តងទៀតនេះ វាមានកត្តាជាច្រើនដូចជា៖

.មិត្តភ័ក្រ

.គ្រួសារ

.សង្គម

២.២ ការស្រាវជ្រាវស្នាដៃដែលពាក់ព័ន្ធ

មានឯកសារឬស្នាដៃពាក់ព័ន្ធជាច្រើនដែលដែលអ្នកស្រាវជ្រាវបានរកឃើញ តាមអង្គការ ស្ថាប័ន្ត ក្រសួងមន្ទីរ សមាគមន៍ មជ្ឈមណ្ឌលដើម្បីផ្តាច់គ្រឿងញៀន។

ជំពូក៣

វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ យើងបានប្រើប្រាស់តែវិធី សាស្ត្រស្រាវជ្រាវតាមបែប គុណវិស័យ និងបរិមាណវិស័យ។

៣.១ ការកំណត់អថេរនិងសម្មតិកម្ម

៣.១.១ ការកំណត់អថេរ

- អថេរអាស្រ័យ: យុវជនដែលមានអាយុចាប់ពី ១៨ឆ្នាំទៅ៣០ឆ្នាំ ដែលត្រឡប់មកប្រើប្រាស់គ្រឿងញៀនឡើងវិញ។ គឺមានន័យថា ពួកគេត្រូវទទួលការព្យាបាលឱ្យជាម្តងហើយ តែពួកគេនៅតែ ប្រើគ្រឿងញៀនម្តងទៀត។
- អថេរមិនអាស្រ័យទីមួយ: កត្តាខ្លួនឯងគឺការគិតការឱ្យតម្លៃលើខ្លួនឯងនិងការជំរុញពីរាងកាយៈការបាត់បង់កោសិកាដូជាមីនៈ។
- អថេរមិនអាស្រ័យទីពីរ: កត្តាគ្រួសារមានឪពុកម្តាយសាច់ញាតិ ឬបងប្អូនដែលជិតជិតបំផុត ដោយផ្តោតលើទំនាក់ទំនងរបៀបរស់នៅ ការយកចិត្តទុកដាក់និងការអប់រំនៅក្នុងគ្រួសារ។
- អថេរមិនអាស្រ័យទីបី: កត្តាសង្គម មានអ្នកជិតខាង កន្លែងធ្វើការ និងមិត្តភក្តិជាដើម។

៣.១.២ ការកំណត់សម្មតិកម្ម

.ដោយសារតែការជម្រុញពីខ្លួនឯងមានកម្រិតខ្លាំង ទើបធ្វើឱ្យយុវជនប្រើប្រាស់គ្រឿងញៀនម្តងទៀត។

.កត្តាគ្រួសារ និងសង្គមគ្រាន់តែជាកត្តារួមចំណែក ធ្វើឱ្យយុវជនប្រើគ្រឿងញៀនម្តង ហើយម្តងទៀតតែប៉ុណ្ណោះ។

៣.២ ការជ្រើសរើសទីកន្លែង

ក្នុងការស្រាវជ្រាវប្រធានបទខាងលើនេះយើងបានជ្រើសរើសទីកន្លែងនៅមជ្ឈមណ្ឌលឱកាសខ្ញុំ ដែលមានទីតាំងស្ថិតនៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៣.៣ ការជ្រើសរើសសំណាក

- សិក្សាលើយុវជនដែលមាននៅក្នុងមជ្ឈមណ្ឌលឱកាសខ្ញុំ
- ធ្វើការសម្ភាសន៍ជាមួយគណៈគ្រប់គ្រងមណ្ឌលចំនួន១៣នាក់
- សម្ភាសន៍យុវជនចំនួន៥០នាក់ និងធ្វើការទំនាក់ទំនងជាមួយអាណាព្យាបាលគេ
- ជ្រើសរើសយុវជនដែលមានអាយុចាប់ពី១៨ឆ្នាំ ដល់៣០ឆ្នាំ

៣.៤. ដំណើរការនៃការស្រាវជ្រាវ

- សុំការអនុញ្ញាតពីសាលា
- សុំការអនុញ្ញាតពីមជ្ឈមណ្ឌលឱកាសខ្ញុំ
- ជ្រើសរើសពេលវេលាដើម្បីណាត់ជួប Sample
- ផ្តល់វត្ថុលើកទឹកចិត្ត
- ជួបជាលក្ខណៈបុគ្គល
- ធ្វើការណែនាំខ្លួន
- និយាយប្រាប់ពីគោលបំណងរបស់យើង
- ចាប់ផ្តើមធ្វើការសម្ភាសន៍ដោយប្រាប់គេជាមុនពីរយៈពេលសម្ភាសន៍
- ថ្លែងអំណរគុណពេលសម្ភាសន៍ចប់

៣.៥ កម្រងសំណួរ (សូមមើលឧបសម្ពន្ធ)

សម្រាប់បុគ្គលដែលញៀនថ្នាំម្តងហើយម្តងទៀត

- ស្ថានភាពផ្ទាល់ខ្លួន ៨ សំណួរ
- កត្តាជម្រុញពីរាងកាយ និងការឱ្យតម្លៃខ្លួនឯង ១៧ សំណួរ

សម្រាប់ក្រុមគ្រួសារ

- ស្ថានភាពគ្រួសារ ៥ សំណួរ
- កត្តាគ្រួសារ ១៥ សំណួរ

សម្រាប់គណៈគ្រប់គ្រងមជ្ឈមណ្ឌលឱកាសខ្ញុំ ២០ សំណួរ

៣.៥. វិធីសាស្ត្រនៃការវិភាគ

- ធ្វើការសម្អាស និងពិភាក្សាហើយបញ្ចូលទិន្នន័យតាមកម្មវិធី SPSS16

ជំពូក៤
លទ្ធផលរំពឹងទុក

ការស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ អ្នកស្រាវជ្រាវសង្ឃឹមទុកថា ក្រុមគោលដៅ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់មានការចូលរួម។

. ទទួលបានលទ្ធផលដូចសម្មតិកម្ម

. ប្រើប្រាស់លទ្ធផលទាំងនេះ...

ជំពូក៥
ផែនការសកម្មភាពនិងផែនការថវិកា

៥.១ ផែនការសកម្មភាព (Activities Plan)

នៅក្នុងផែនការសកម្មភាព ត្រូវបង្ហាញប្រាប់ពីការចាប់ផ្តើមនិងរយៈពេលនៃការបញ្ចប់នៃការស្រាវជ្រាវទាំងមូលខាងក្រោមនេះជាគំរូផែនការសកម្មភាព។

ល.រ	សកម្មភាព	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
១	កំណត់ប្រធានបទ	✓										
២	ជ្រើសរើសសាស្ត្រាចារ្យណែនាំ		✓									
៣	ស្វែងរកឯកសារពាក់ព័ន្ធ			✓								
៤	រៀបចំទ្រឹស្តីឱ្យត្រូវនឹងប្រធានបទ				✓							
៥	រៀបចំកម្រងសំណួរចុះស្រាវជ្រាវ					✓						
៦	សម្ភាសន៍សាកល្បង						✓					
៧	កែសម្រួលកម្រងសំណួរសាជាថ្មី							✓				
៨	សម្ភាសន៍ផ្លូវការឬប្រមូលទិន្នន័យ								✓			
៩	បញ្ចូលនិងវិភាគទិន្នន័យ									✓		
១០	បកស្រាយទិន្នន័យ										✓	
១១	រៀបចំលទ្ធផលនៃការស្រាវជ្រាវ											✓
១២	ការពារលទ្ធផល											✓

៥.២ ផែនការថវិកា(Budget Plan)

ផែនការថវិការអ្នកស្រាវជ្រាវត្រូវធ្វើតារាងបញ្ជីលម្អិត អំពីចំណាយក្នុងរយៈពេលស្រាវជ្រាវសរសេរសារណាទាំងមូល។

ល.រ	ធនធានប្រើប្រាស់	តម្លៃ១ឯកតា	ចំណាយសរុប	ផ្សេងៗ
១	សម្ភារៈ	៤០ ដុល្លា	៤០ ដុល្លា	
២	វត្ថុអនុស្សាវរីយ៍	០.៥ ដុល្លា	៦០ ដុល្លា	
៣	ប្រធានផ្នែកប្រមូលទិន្នន័យ	១០ ដុល្លា	១០០ ដុល្លា	
៤	អ្នកប្រមូលទិន្នន័យ ៥នាក់	៨ ដុល្លា	៣៦០ ដុល្លា	
៥	អ្នកបញ្ចូលទិន្នន័យ ២នាក់	៨ ដុល្លា	៤៨ ដុល្លា	
៦	អ្នកវិភាគទិន្នន័យ	១០ ដុល្លា	៣០ ដុល្លា	
	សរុប = ៦៣៨ ដុល្លា			

៦ឯកសារយោង

១. ក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, (២០០៧), *កម្រងកម្មវិធីស្ដីពីការប្រើប្រាស់គ្រឿងញៀន និងមេរោគអេដស៍ជម្ងឺអេដស៍របស់អង្គការសុខភាពពិភពលោកលេខ៥ ស្វែងយល់អំពីថ្នាំ ឆ្កួត.* ភ្នំពេញ

២.TPO , (២០០៤), *សុខភាពផ្លូវចិត្តសហគមន៍នៅកម្ពុជា.* បោះពុម្ពលើកទី២. ភ្នំពេញ

៣.TPO, (២០០៥), *ទីណាគ្មានវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា.* បោះពុម្ពលើកទី១. ភ្នំពេញ

៤.ADI, (២០០៤), *ការប្រើប្រាស់គ្រឿងញៀន ជាបញ្ហា.* ភ្នំពេញ

